សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការរំលាយកិច្ចសន្យា

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ឡៅ គីមលី**
**ណាន បញ្ញា**

សាស្ត្រាចារ្យណែនាំ
លោក **កេត សុជាតិ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការរំលាយកិច្ចសន្យា

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ឡៅ គីមលី**
**ណាន បញ្ញា**

សាស្ត្រាចារ្យណែនាំ
លោក **កេត សុជាតិ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

## **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំ **ឡៅ គឹមលី** និង **ណាន បញ្ញា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** ជំនាន់ទី ១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៥~២០១៩។

**សូមគោរពលំឱនកាយវាចាចិត្ត សម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ៖**

| | |
|---|---|
| **លោកឪពុក ឡៅ ឃុនសេង** | **លោកឪពុក វ៉ា ខួនស្រេង** |
| **អ្នកម្តាយ ឈៀវ ជ្រុយ** | **អ្នកម្តាយ ខួន គឹមស្រ៊ាន** |

ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សាទូន្មានប្រៀនប្រដៅជួយទំនុកបម្រុងដល់រូបកូនៗទាំងស្មារតី និងសម្ភារៈគ្រប់បែបយ៉ាង ជាពិសេសរួមទាំងការផ្តល់នូវដំបូន្មានដ៏ល្អៗរបស់លោកដល់រូបកូនចាប់តាំងពីពេលកូននៅជាកុមារភាព រហូតដល់កូនធំពេញវ័យ និងបានទទួលការបណ្តុះបណ្តាលតាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។ លោកទាំងពីរបានព្យាយាមប្រឹងប្រែងអស់ពីកំលាំងកាយចិត្តរបស់ខ្លួនក្នុងការជួយទំនុកបម្រុងតម្រង់ទិសឱ្យកូនៗ មានអនាគតភ្លឺស្វាងរីកចម្រើនទៅមុខ និងអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាសិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គមជាតិ។

ឯកឧត្តម **លុយ ចន្ធា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក-លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងបានជួយតម្រង់ទិសយើងខ្ញុំ តាំងពីឆ្នាំសិក្សាមូលដ្ឋានរហូតដល់បញ្ចប់ថ្នាក់-បរិញ្ញាបត្រប្រកបដោយក្រមវិជ្ជាជីវៈ។

លោកសាស្ត្រាចារ្យ **កេត សុជាតិ** ដែលលោកបានដឹកនាំបង្ហាត់បង្ហាញនូវគំនិត និងវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទ រួមទាំងបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោក តាំងពីដើមរហូតដល់បញ្ចប់ការស្រាវជ្រាវមួយនេះ។ ស្នាដៃដែលកើតចេញពីការស្រាវជ្រាវនេះ ពិតជាមិនអាចមានអត្ថិភាពឡើយ ប្រសិនបើគ្មានការជ្រោមជ្រែងពីលោក។

លោក **ឈិន ដារិត**, លោក **អៀ ហាំងឡេង**, លោក **រិន វិសាល** និងលោក **សេង សុផាត** ដែលជាសិស្សច្បងតែងតែបង្ហាត់បង្រៀនរូបខ្ញុំទាំងពីរកន្លងមកចំណាយទាំងពេលវេលា កម្លាំងកាយកម្លាំងចិត្តមិនខ្លាចនឿយហត់។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមធ្វើការអរគុណ និងដឹងគុណម្តងទៀតដល់អ្នកមានគុណទាំងពួងដែលបានរៀបរាប់ខាងលើ សូមបានប្រកបតែនឹងពុទ្ធពរទាំង៤ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

បន្ទាប់ពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិ-សាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល៤ឆ្នាំកន្លងមក ដោយកិច្ចខិតខំប្រឹងប្រែងក្នុងការរៀនសូត្រដើម្បីទទួលបាននូវចំពោះដឹងពីលោក-លោកស្រីសាស្ត្រាចារ្យនៅក្នុងសាកលវិទ្យាល័យ យើងខ្ញុំទាំងពីររូបត្រូវបានលើកទឹកចិត្ត និងទទួលការអនុញ្ញាតិពីសាកលវិទ្យាល័យដើម្បីសសេរសារណា-បញ្ចប់ការសិក្សាក្រោមប្រធានបទ "**ការរំលាយកិច្ចសន្យា**"។

ប្រធានបទមួយនេះ គឺកើតឡើងចេញពីចម្ងល់ និងការចង់ដឹងឱ្យកាន់តែស៊ីជម្រៅរបស់យើងខ្ញុំទៅលើកិច្ចការរំលាយកិច្ចសន្យា។ សារណាបញ្ចប់ការសិក្សាមួយនេះ ផ្តោតទៅលើដំណើរនៃការ-រំលាយកិច្ចសន្យា ព្រមជាមួយនឹងនីតិវិធីនៃការរំលាយកិច្ចសន្យា ដែលធ្វើយ៉ាងណាធានាដល់នូវ-ឧត្តមប្រយោជន៍នៃសិទ្ធិរបស់គូភាគីនៃកិច្ចសន្យា។ លើសពីនេះទៀត សារណាមួយនេះអាចលេចចេញជារូបរាងឡើងដោយសារមានការជួយជ្រោមជ្រែងណែនាំ តម្រង់ទិសពីសំណាក់លោកសាស្ត្រាចារ្យ **កេត សុជាតិ** ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការចែករំលែកចំណេះដឹងបទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់យើងខ្ញុំ។

ក្នុងនាមយើងខ្ញុំជាអ្នករៀបរៀងសារណានេះ ក៏សង្ឃឹមថាឯកសារនេះនឹងក្លាយជាប្រយោជន៍និងជាវិភាគទាន ព្រមទាំងផ្តល់ជាចំណេះដឹងបន្ថែម សម្រាប់ជាគន្លឹះ និងជាជំនួយស្មារតីដល់ប្អូនៗជំនាន់ក្រោយៗទៀតអាចធ្វើសិក្សាស្រាវជ្រាវបន្តបាន។ ហើយយើងខ្ញុំទាំងពីររូបក៏ជឿជាក់ដែរថាក្នុងសារណាមួយនេះប្រាកដជាមានកំហុសខុសឆ្គង ដោយប្រការណាមួយជាក់ជាពុំខាន ដូច្នេះយើងខ្ញុំទាំងពីររូបសូមទទួលយកការរិះគន់បែបក្នុងន័យស្ថាបនា ដើម្បីធ្វើឱ្យសារណាមួយនេះកាន់តែល្អប្រសើរជាងមុន។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីររូបសូមជូនពរដល់អស់លោក-លោកស្រីដែលកំពុងអានសៀវភៅនេះ សូមជួបប្រទះតែពុទ្ធពរទាំង៤ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១**

**ទិដ្ឋភាពគតិយុត្តនៃការរំលាយកិច្ចសន្យា**

១.១ ខ្លឹមសារនៃការរំលាយកិច្ចសន្យា ........ ៣

១.១.១ អត្ថន័យ ........ ៣

១.១.២ គោលបំណង ........ ៤

១.១.៣ ប្រភេទនៃការរំលាយកិច្ចសន្យា ........ ៤

១.១.៣.១ ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់ ........ ៥

១.១.៣.២ ការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា ........ ៦

១.១.៣.៣ ការរំលាយកិច្ចសន្យាដោយផ្អែកទៅលើការព្រមព្រៀង ........ ៧

១.២ ល័ក្ខខ័ណ្ឌនៅក្នុងការរំលាយកិច្ចសន្យា ........ **៧**

១.២.១ ល័ក្ខខ័ណ្ឌដែលជាមូលហេតុទូទៅ ........ ៧

១.២.១.១ កិច្ចសន្យាអញ្ញមញ្ញ ........ ៨

១.២.១.២ ភាគីម្ខាងទៀតបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ........ ៩

១.២.២ ល័ក្ខខ័ណ្ឌដែលជាមូលហេតុពិសេស ........ ១៦

**ជំពូកទី ២**

**នីតិវិធីនៃការអនុវត្តន៍សិទ្ធិរំលាយកិច្ចសន្យា**

២.១ នីតិវិធីនៃការរំលាយកិច្ចសន្យា ........ ១៨

២.១.១ ការរំលាយតាមផ្លូវតុលាការ ........ ១៩

២.១.២ ការរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ ........ ២២

២.២ ការរលត់សិទ្ធិរំលាយកិច្ចសន្យា ........ ២៣

២.២.១ មូលហេតុនៃការរំលត់សិទ្ធិរលាយកិច្ចសន្យា ......................................................... ២៤
២.២.១.១ ការរលត់សិទ្ធិរំលាយដោយសកម្មភាពរបស់ភាគី ............................................ ២៤
២.២.១.២ អាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយកិច្ចសន្យា............................................ ២៦
២.២.២ អានុភាពនៃការរលត់សិទ្ធិរំលាយកិច្ចសន្យារបស់ភាគី............................................ ២៧

## ជំពូកទី ៣

## អានុភាពនៃការរំលាយកិច្ចសន្យា

៣.១ វិបាកទាក់ទងទៅនឹងអានុភាពនៃការរំលាយកិច្ចសន្យា .................................................. **២៩**
៣.១.១ អានុភាពប្រតិសកម្ម........................................................................................ ២៩
៣.១.២ អានុភាពមិនប្រតិសកម្ម .................................................................................. ២៩
៣.២ អានុភាពចំពោះភាគី ........................................................................................... ២៩
៣.២.១ ការរលត់នូវករណីយកិច្ចនៃកិច្ចសន្យា ................................................................ ៣០
៣.២.១.១ ការធ្វើបដិទាននៃការផ្ទេរកម្មសិទ្ធ.................................................................. ៣១
៣.២.១.២ ការធ្វើបដិទានទៅស្ថានភាពដើម.................................................................. ៣១
៣.២.២ ករណីយកិច្ចសងសំណងការខូចខាត ................................................................ ៣៣
៣.៣ អានុភាពចំពោះតតិយជន.................................................................................... ៣៣
៣.៣.១ តតិយជនក្នុងគោលការណ៍ប្រតិសកម្ម ................................................................ ៣៤
៣.៣.២ តតិយជនក្នុងគោលការណ៍មិនប្រតិសកម្ម........................................................... ៣៥
**សេចក្តីសន្និដ្ឋាន**.................................................................................................... ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. បុព្វហេតុនៃការស្រាវជ្រាវ

នៅក្នុងការរស់នៅប្រចាំថ្ងៃកិច្ចសន្យាដើរតួយ៉ាងសំខាន់ក្នុងការជួយឱ្យកិច្ចការជំនួញមានស្ថិរភាព និងមានការជឿទុកចិត្តគ្នាទៅវិញទៅមក។ ដូច្នេះហើយ ទើបនៅក្នុងសង្គមតែងតែប្រើប្រាស់កិច្ចសន្យាសំរាប់ជីវភាពប្រចាំថ្ងៃ ដោយពួកគេបង្កើតកិច្ចសន្យាជាច្រើនដូចជា កិច្ចសន្យាលក់ទិញ ភតិសន្យា កិច្ចសន្យាខ្ចីបរិភោគជាដើម។ការបង្កើតកិច្ចសន្យាមិនចាំបាច់ត្រូវតែធ្វើជាលាយលក្ខ័អក្សរនោះទេ ពោល-គឺអាចធ្វើដោយផ្ទាល់មាត់បាន វាអាស្រ័យទៅលើល័ក្ខខ័ណ្ឌទម្រង់ក្នុងការបង្កើតកិច្ចសន្យានីមួយៗ។ យ៉ាងណាក៏ដោយភាគីនៃកិច្ចសន្យាមិនអាចជឿជាក់បានទាំងស្រុងទេ ថាគ្មានភាគីណាម្ខាងនឹងបំពានកិច្ចសន្យាដោយមូលហេតុណាមួយ មិនថាដោយចេតនា ឬ អចេតនានោះទេ ។ ទោះបីជាពេលខ្លះភាគីនៃកិច្ចសន្យាមានឆន្ទៈចង់អនុវត្តកាតព្វកិច្ចក៏ដោយ ក៏អាចមាននូវហេតុណាមួយដែលធ្វើឱ្យភាគីនោះមិនអាចអនុវត្តកាតព្វកិច្ចបានដែរ ។ ហេតុនេះហើយទើបក្រមរដ្ឋប្បវេណីកម្ពុជាបានផ្តល់សិទ្ធិទៅឱ្យភាគីដែលត្រូវបានគេបំពានអាចមានសិទ្ធិទទួលបាននូវការសង្គ្រោះតាមរយៈវិធានបីគឺ ការអនុវត្តដោយបង្ខំ ការរំលាយកិច្ចសន្យា និងសំណងការខូចខាត ។ ប៉ុន្តែនៅក្នុងសារណាមួយនេះនឹងផ្តោតសំខាន់តែទៅលើការរំលាយកិច្ចសន្យាតែប៉ុណ្ណោះ។ ការរំលាយកិច្ចសន្យាគឺជាវិធានមួយដែលអាចឱ្យភាគីនៃកិច្ចសន្យារួចផុតពីចំណងកាតព្វកិច្ចដែលមាននៅក្នុងកិច្ចសន្យា និងអាចទទួលបាននូវសំណងការខូចខាតដែលកើតឡើងពីការរំលោភបំពាន ។

## ២.ចំណោទបញ្ហានៃការដោះស្រាយ

មូលហេតុអ្វីខ្លះដែលនាំឱ្យឈានទៅដល់ការរំលាយកិច្ចសន្យា ហើយដើម្បីអាចរំលាយកិច្ចសន្យាបានតើគូភាគីនៃកិច្ចសន្យាត្រូវធ្វើនីតិវិធីដូចម្តេចខ្លះ ម្យ៉ាងទៀតក្រោយពេលរំលាយកិច្ចសន្យាតើនឹងមានអានុភាពដូចម្តេច?

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវ និងការរៀបចំតាក់តែងនូវឯកសារ ដែលជាកិច្ចការស្រាវជ្រាវនេះឡើងក្នុងគោលបំណងសិក្សាស្រាវជ្រាវ ដើម្បីធ្វើការពង្រឹងនូវសមត្ថភាពបន្ថែមនៃចំណេះដឹងផ្ទាល់ខ្លួន និងក៏ជាទុនមួយសម្រាប់ទុកជាឯកសារសំរាប់ធ្វើការស្វែងយល់ និងជាចំណេះដឹងបន្ថែមមួយផ្នែកនៅក្នុងការស្រាវជ្រាវឱ្យមានការយល់ដឹងបន្ថែមអំពីប្រព័ន្ធនៃការរំលាយកិច្ចសន្យា ក៏ដូចជាស្រាយនូវចម្ងល់ថាតើធ្វើដូចម្តេចដើម្បីឱ្យការរំលាយកិច្ចសន្យាមានអានុភាពតាមផ្លូវច្បាប់ ព្រមទាំងទទួលស្គាល់ និងការពារដោយច្បាប់។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តខាងលើខ្ញុំបាទខិតខំធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារជាមូលដ្ឋាន គឺក្រមរដ្ឋប្បវេណីនិងឯកសាររួមផ្សំដែលពាក់ព័ន្ធទាំងឡាយដែលបានលើកឡើងនៅក្នុងឯកសារពិគ្រោះស្រាប់។

នៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ គឺខ្ញុំសរសេរផ្តោតតែអំពីដំណើរនៃការរំលាយ-កិច្ចសន្យាជាទូទៅតែប៉ុណ្ណោះដោយមិនបានសិក្សាទៅលើប្រភេទនៃកិច្ចសន្យានីមួយៗឡើយ។ ក្រៅពីនេះខ្ញុំក៏បានដកចេញនូវអត្ថន័យល្អៗងាយយល់ពីលោកសាស្ត្រាចារ្យជាច្រើន ដែលកំពុងបំពេញការងារបង្រៀននៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អ្នកអនុវត្តច្បាប់ដូចជាចៅក្រមមេធាវីជាច្រើនរូបផងដែរសំរាប់ជំនួយដល់ខ្លឹមសារនៃអត្ថន័យខ្លះដែលមានភាពសាំញ៉ាំផងដែរ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសរសេរកិច្ចការនេះ រូបខ្ញុំបាទទាំងពីរបានធ្វើការសិក្សាបែបពន្យល់ទ្រឹស្តី និង វិភាគ ព្រម-ទាំងលើកឧទាហរណ៍មកអមជាមួយផង។ ការសិក្សាស្រាវជ្រាវត្រូវបានតាមធ្វើតាមរយៈ ការប្រមូលនូវពត៌មានទាំងឡាយ ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃកិច្ចការនេះដើម្បីឱ្យសារណាមួយនេះមានភាពត្រឹមត្រូវ និងមានប្រសិទ្ធភាព ។ មិនតែប៉ុណ្ណោះ ខ្ញុំក៏បានដកស្រង់នូវពត៌មានមួយចំនួនដូចជា ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៧) សេចក្តីកំណត់ចំពោះមាត្រា-នីមួយៗ និងការបកស្រាយរបស់សាស្ត្រចារ្យគាត់តែងច្បាប់មួយចំនួន ព្រមទាំងឯកសារមួយចំនួនទៀតផងដែរ។ ហើយចំណុចសំខាន់មួយទៀតនោះក៏មានបង្ហាញនូវគំរូនៃការរំលាយកិច្ចសន្យាសម្រាប់ធ្វើជាឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងទ្រឹស្តីផងដែរ។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

សមិទ្ធផលនៃការស្រាវជ្រាវនេះនឹងអាចនាំឱ្យ បង ប្អូនក៏ដូចមិត្តនិស្សិតដទៃទៀតទុកជាដើមទុនសម្រាប់ជំនួយស្មារតីដល់ការសិក្សាស្រាវជ្រាវរបស់ខ្លួន បានយល់ដឹងនូវដំណើរការរំលាយកិច្ចសន្យាឱ្យមានភាពត្រឹមត្រូវ ច្បាស់លាស់ និងមានប្រសិទ្ធិភាពខ្ពស់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- ជំពូកទី១ ទិដ្ឋភាពគតិយុត្តនៃការរំលាយកិច្ចសន្យា
- ជំពូកទី២ នីតិវិធីនៃការអនុវត្តន៍សិទ្ធិរំលាយកិច្ចសន្យា
- ជំពូកទី៣ អានុភាពនៃការរំលាយកិច្ចសន្យា

# ជំពូកទី ១
# ទិដ្ឋភាពគតិយុត្ត
# នៃការរំលាយកិច្ចសន្យា

# ជំពូកទី ១
# និដ្ឋភាពគតិយុត្តនៃការរំលាយកិច្ចសន្យា

កិច្ចសន្យាគឺជាកិរិយាររបស់បុគ្គលពីរនាក់ ឬច្រើននាក់ដែលមានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងកាតព្វកិច្ច[1]។ ក្នុងន័យនេះ កិច្ចសន្យាគឺជាការត្រូវគ្នានៃឆន្ទៈដែលចង់បង្កើត កែប្រែ និងរំលត់កាតព្វកិច្ច។ កិច្ចសន្យាដែលបង្កើតឡើងគឺដើម្បីបម្រើផលប្រយោជន៍បុគ្គលនិងបុគ្គល និង ផលប្រយោជន៍សេដ្ឋកិច្ចហើយភាគីនៃកិច្ចសន្យាគប្បីអនុវត្តកិច្ចសន្យាដោយសុចរិត និង ភាពស្មោះត្រង់ ដើម្បីឱ្យការធ្វើជំនួញកាន់តែមានការជឿទុកចិត្តគ្នាទៅវិញទៅមក។ មិនតែប៉ុណ្ណោះ កិច្ចសន្យាដែល បង្កើតឡើង គឺផ្អែកទៅលើគោលការណ៍ស្វ័យភាពរបស់បុគ្គលឯកជនដោយគោរពនូវសេរីភាពនៃឆន្ទៈ របស់បុគ្គល និងបញ្ញត្តិអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជនដោយរួម បញ្ចូលទាំងនីតិបុគ្គល[2]។ សេរីភាពនៃការបង្ហាញឆន្ទៈក្នុងការកំណត់អំពីផលប្រយោជន៍របស់ខ្លួន បង្កើត ទំនាក់ទំនងគតិយុត្ត កំណត់ទម្រង់នៃកិច្ចសន្យា កំណត់ខ្លឹមសារនៃកិច្ចសន្យា ឬសកម្មភាពរបស់ខ្លួន។ នៅពេលដែលកិច្ចសន្យាត្រូវបានបង្កើតនោះសិទ្ធិ និងកាតព្វកិច្ចក៏ត្រូវបានបង្កើតឡើងរវាងភាគីទាំង សងខាងផងដែរ ប៉ុន្តែទោះបីជាកិច្ចសន្យាត្រូវបានបង្កើតឡើងតាមឆន្ទៈត្រូវគ្នាក៏ដោយក៏កិច្ចសន្យានោះ អាចត្រូវបានរំលាយចោលវិញដែរ ដោយសារតែការមិនអនុវត្តន៍កាតព្វកិច្ចរបស់ភាគីម្ខាងប្ញករួមទាំង ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរហើយភាគីម្ខាងទៀតមិនមានឆន្ទៈក្នុងការបន្តអានុភាពភាពនៃកិច្ចសន្យា នេះតទៅទៀត។

តើអ្វីទៅជាការរំលាយកិច្ចសន្យាហើយដើម្បីអាចរំលាយកិច្ចសន្យាបានតើត្រូវបំពេញល័ក្ខខ័ណ្ឌ យ៉ាងដូចម្តេចខ្លះ?

មុននឹងឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តខាងលើ យើងត្រូវសិក្សាទៅលើខ្លឹមសារនៃ-ការរំលាយកិច្ចសន្យា (១.១) និងល័ក្ខខ័ណ្ឌនៃការរំលាយកិច្ចសន្យា (១.២) ជាមុនសិន។

## ១.១ ខ្លឹមសារនៃការរំលាយកិច្ចសន្យា

### ១.១.១ អត្ថន័យ

ការរំលាយកិច្ចសន្យា គឺជាមធ្យោបាយចុងក្រោយសម្រាប់ធ្វើការដោះស្រាយនៅពេលដែល ភាគីម្ខាងមិនព្រមអនុវត្តនូវកាតព្វកិច្ច។ ការរំលាយកិច្ចសន្យាគឺជារបបដែលត្រូវបានបង្កើតឡើង

[1] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧ មាត្រា ៣១១។

[2] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ៨ ធ្នូ ២០០៧ មាត្រា ៣។

ដោយសារភាគីម្ខាងបានបំពាននូវកាតព្វកិច្ចនៃកិច្ចសន្យាចំពោះភាគីម្ខាងទៀតនៃកិច្ចសន្យាអញ្ញមញ្ញ[3]។

ការរំលាយកិច្ចសន្យា ជាវិធីសង្គ្រោះផលប្រយោជន៍របស់ម្ចាស់បំណុលដោយរំលត់កាតព្វកិច្ចក្នុងករណីដែលកូនបំណុលបានបំពានកិច្ចសន្យា ដែលត្រង់ចំណុចនេះមានល័ក្ខខ័ណ្ឌខុសគ្នានឹងការលុបចោលដែលកិច្ចសន្យាមានវិការៈនាពេលបង្កើត។ ពោលគឺមូលហេតុនៃការរំលាយគឺការមិនអនុវត្តន៍កាតព្វកិច្ចក្រោយបង្កើត ចំណែកឯមូលហេតុនៃការលុបចោលគឺវិការៈនៃការបង្ហាញឆន្ទៈ និងអសមត្ថភាពនាពេលបង្កើតកិច្ចសន្យា[4]។

ន័យម្យ៉ាងទៀត ការរំលាយកិច្ចសន្យាគឺជាការបង្ហាញឆន្ទៈលុបចោលនូវអានុភាពនៃកិច្ចសន្យាដោយភាគីម្ខាង ដោយផ្អែកទៅលើមូលហេតុកំណត់មួយដែលកើតឡើងក្រោយពេលធ្វើកិច្ចសន្យា[5]។

### ១.១.២ គោលបំណង

ការផ្តល់សិទ្ធិក្នុងការរំលាយដល់គូភាគីនៃកិច្ចសន្យា ដែលទទួលស្គាល់ដោយក្រមរដ្ឋប្បវេណីគឺជាការបើកឱកាសឱ្យភាគីនៃកិច្ចសន្យាឱ្យមានសិទ្ធិក្នុងការរំលាយចោលនូវកិច្ចសន្យា ដើម្បីទប់ស្កាត់នូវហានិភ័យដែលកំពុងកើតឡើងក៏ដូចជាដែលនឹងបម្រុងនឹងកើតឡើងនាពេលអនាគត និងជាការជួសជុលព្យសនកម្មដែលបានកើតឡើង ដោយសារការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងររបស់ភាគីម្ខាងទៀត។

ការរំលាយកិច្ចសន្យា មិនមែនជាការដាក់ទណ្ឌកម្មប្រឆាំងទៅនឹងភាគីជាដៃគូដែលខកខានក្នុងការអនុវត្តន៍នូវកាតព្វកិច្ចរបស់ខ្លួនទេ ប៉ុន្តែគឺជាប្រព័ន្ធដែលផ្តាច់ចំណងនៃកិច្ចសន្យាអញ្ញមញ្ញនៅពេលដែលគោលបំណងនៃកិច្ចសន្យានោះ មិនអាចសម្រេចបានដោយសារមានការមិនអនុវត្តន៍កាតព្វកិច្ចរបស់ភាគីម្ខាងហើយ ដែលយល់ឃើញថាការបន្តឱ្យមានចំណងនៃកិច្ចសន្យាអញ្ញមញ្ញនោះគ្មានភាពសមហេតុផល[6]។

### ១.១.៣ ប្រភេទនៃការរំលាយកិច្ចសន្យា

ការរំលាយកិច្ចសន្យាសំដៅទៅលើសកម្មភាពឯកតោភាគីដែលធ្វើឱ្យភាគីម្ខាង ឬទាំងសងខាងរួចផុតពីកាតព្វកិច្ចរបស់ខ្លួននៅក្នុងកិច្ចសន្យា លើកលែងតែសំណងការខូចខាត។ ការរំលាយកិច្ចសន្យាមិនចាំបាច់មានការព្រមព្រៀងពីភាគីម្ខាងទៀតទេ ព្រោះវាជាសកម្មភាពឯកតោភាគី។

[3] សាស្ត្រាចារ្យ អៀង សំណាង, ច្បាប់កិច្ចសន្យា, ឆ្នាំ ២០១៤, ទំព័រ ៧៨។

[4] សាស្ត្រាចារ្យ គង់ សុភ័ក្រ, សញ្ញាណទូទៅនៃកាតព្វកិច្ច, ឆ្នាំ ២០១៨-២០១៩, ទំព័រទី ១៥។

[5] សមិទ្ធផលរបស់គម្រោងនៃប្រព័ន្ធច្បាប់ និងតុលាការ, ក្រមរដ្ឋប្បវេណី, និងក្រមនីតិវិធីរដ្ឋប្បវេណី, ភាគ ១ (ភ្នំពេញ ៖ ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី ១ ខែ ធ្នូ ឆ្នាំ ២០១៥)។

[6] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់-មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្លឹះទី ៤, (ភ្នំពេញ៖ ក្រសួងយុត្តិធម៌, ២០១០), ទំព័រទី ២១៤។

មានប្រភេទមួយចំនួនសម្រាប់ការរំលាយកិច្ចសន្យាមានដូចជា ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់ (១.១.៣.១) ការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា (១.១.៣.២) និងការរំលាយកិច្ចសន្យាដោយផ្អែកទៅតាមការព្រមព្រៀង (១.១.៣.៣)។

### ១.១.៣.១ ការរំលាយកិច្ចសន្យាដែលកំណត់ដោយច្បាប់

ការរំលាយដោយកំណត់ច្បាប់គឺជាការការរំលាយកិច្ចសន្យាផ្អែកទៅតាមមូលហេតុណាមួយដែលមានកំណត់នៅក្នុងច្បាប់ ហេតុនេះ ក្នុងករណីមូលហេតុណាមួយដែលមានបញ្ញត្តិនៅក្នុងច្បាប់ត្រូវបានបំពេញ ភាគីនោះអាចរំលាយកិច្ចសន្យាបាន។

មូលហេតុដែលកំណត់ដោយច្បាប់ត្រូវបានបែងចែកជា ២ គឺមូលហេតុទូទៅ និងមូលហេតុពិសេស។ មូលហេតុទូទៅត្រូវបានកំណត់នៅក្នុងមាត្រា ៤០៨ ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរនៅក្នុងក្រមរដ្ឋប្បវេណី។

ឧទាហរណ៍ ៖ កញ្ញា ក បានឱ្យ កញ្ញា ខ (ជាងកាត់ដេរ) ដេររ៉ូបអាពាហ៍ពិពាហ៍ក្នុងតម្លៃ ១០០០ ដុល្លារសម្រាប់ស្លៀកក្នុងថ្ងៃអាពាហ៍ពិពាហ៍របស់លោក គ គឺថ្ងៃទី ០១.០៥.២០១៩។ កាលបរិច្ឆេទប្រគល់រ៉ូបនៅថ្ងៃទី ០១.០៥.២០១៩ ប៉ុន្តែ កញ្ញា ខ មិនបានប្រគល់រ៉ូបឱ្យកញ្ញា ក នៅថ្ងៃកំណត់ទេ[7]។ បើទោះបីជាកញ្ញា ខ បានប្រគល់រ៉ូបឱ្យកញ្ញា ក នៅថ្ងៃបន្ទាប់ក៏ដោយក៏គ្មានន័យដែរ ព្រោះអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ហើយ។ ដោយសារតែពេលវេលានៃការរៀបអាពាហ៍ពិពាហ៍គឺជាចំណុចសំខាន់ហើយ កញ្ញា ខ មិនអាចអនុវត្តកាតព្វកិច្ចប្រគល់ឱ្យទាន់ពេល នោះកញ្ញា ក អាចរំលាយកិច្ចសន្យាតាមមាត្រា ៤០៨ ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរបាន។

ចំណែកឯមូលហេតុពិសេសត្រូវបានកំណត់ទៅតាមកិច្ចសន្យាសំខាន់នីមួយៗដូចជាកិច្ចសន្យាលក់ទិញ ភតិសន្យាជាដើម -ល-។

ឧទាហរណ៍ ៖ មាត្រា ៦២០ នៃក្រមរដ្ឋប្បវេណី ២០០៧ បានបញ្ញត្តថា ប្រសិនបើគ្មានបំណងចង់បន្តភតិសន្យាតទៅទៀតទេ សន្តតិជនរបស់ភតិក:អាចរំលាយកិច្ចសន្យានោះបាន។

ក្នុងករណីណាមួយដែល***ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ*** បានកើតឡើងចំពោះភាគីម្ខាង នោះភាគីដែលត្រូវបានបំពានអាចប្រើសិទ្ធិរំលាយកិច្ចសន្យាបាន នេះគឺដោយសារច្បាប់បានកំណត់ និងផ្តល់សិទ្ធិក្នុងការទប់ស្កាត់ចំពោះការមិនអនុវត្តន៍កាតព្វកិច្ចរបស់ភាគីម្ខាង ដែលបណ្តាលឱ្យភាគីម្ខាងត្រូវបាត់បង់នូវផលប្រយោជន៍ដែលមិនគួរបាត់បង់។

ឧទាហរណ៍ ៖ ក្នុងកិច្ចសន្យាលក់ទិញ លោក ក មិនបានប្រគល់នូវម៉ូតូនៅក្នុងអំឡុងពេលសមរម្យ

[7] មេធាវី ទេព បូផល, លោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយ៖ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), ទំព័រទី ១២។

នៅក្រោយកាលបរិច្ឆេទទេ ទោះបីជាមានការដាស់តឿនរបស់ ខ ក៏ដោយ នោះ ខ អាចលើកឡើងនូវ-ការរំលាយកិច្ចសន្យាបាន។ នៅក្នុងករណីនេះ ការរំលាយកិច្ចសន្យារបស់ ខ ត្រូវបានអនុវត្តដោយផ្អែកទៅលើការមិនអនុវត្តន៍កាតព្វកិច្ចក្នុងអំឡុងពេលសមរម្យ ដែលកំណត់ដោយម្ចាស់បំណុលដែលបានដាស់តឿនហើយកូនបំណុលមិនអនុវត្តកាតព្វកិច្ចក្នុងអំឡុងពេលនោះ។

### ១.១.៣.២ ការរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យា

ដូចដែលបានរៀបរាប់ខាងលើ កិច្ចសន្យាគឺជាកិរិយាររបស់បុគ្គលពីរនាក់ ឬច្រើននាក់ដែល-មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងកាតព្វកិច្ច។ ក្នុងករណីដែលភាគីព្រមព្រៀងគ្នានោះគ្មានវិវាទកើតឡើងនោះទេ ដូច្នេះក៏គ្មានបញ្ហាស្មុគស្មាញដែរដោយសារតែឆន្ទៈ និងស្វ័យភាពរបស់បុគ្គលឯកជន។

ការរំលាយកិច្ចសន្យាដែលមានកំណត់នៅក្នុងកិច្ចសន្យា គឺជាការរំលាយដោយមូលហេតុដែលភាគី ***បានកំណត់ជាមុននៅក្នុងកិច្ចសន្យា***មានន័យថា ភាគីអាចរំលាយកិច្ចសន្យាបានក្នុងករណីមូលហេតុដែលមានកំណត់ជាមុននៅក្នុងកិច្ចសន្យាត្រូវបានបំពេញ ដោយនៅក្នុងចំណុចនេះមិនពិចារណាអំពីមូលហេតុដែលមានបញ្ញត្តិនៅក្នុងច្បាប់ឡើយ។

ឧទាហរណ៍ ៖ នៅក្នុងកិច្ចសន្យាជួលរវាងលោក ក និងកញ្ញា ខ ដែលមានអំឡុងពេល ០២ ឆ្នាំ គូភាគីបានព្រមព្រៀងគ្នា ក្នុងករណី ***"ភតិកៈមិនបង់ថ្លៃឈ្នួល ០២ ខែជាប់គ្នា ភតិបតីមានសិទ្ធិរំលាយកិច្ចសន្យា"*** ។

ដូច្នេះ ក្នុងករណីដែលមិនបង់ថ្លៃឈ្នួលផ្ទះក្នុងរយៈពេល ២ ខែជាប់គ្នាទេ ភតិបតីនឹងរំលាយ-កិច្ចសន្យា ដែលនេះហៅម្យ៉ាងទៀតថា ការបង្ហាញឆន្ទៈដោយដាក់ល័ក្ខខ័ណ្ឌបង្អង់។

ឧទាហរណ៍ ៖ នៅក្នុងកិច្ចសន្យាជួលរវាងលោក ក និងកញ្ញា ខ ដែលមានអំឡុងពេល០២ឆ្នាំ គូភាគីបានព្រមព្រៀងគ្នា ***"ភតិបតីមានសិទ្ធិរំលាយកិច្ចសន្យាពេលណាក៏បានដោយត្រូវជូនដំណឹងទៅភតិកៈ០៣ខែមុនពេលរំលាយកិច្ចសន្យា***[៨]***"***។

គូភាគីនៃកិច្ចសន្យាអាចសន្យាឱ្យភាគីម្ខាង ឬសងខាងមានសិទ្ធិរំលាយនៅក្នុងកិច្ចសន្យានោះបាន [៩] ។ ដូច្នេះមានន័យថា ដើម្បីឱ្យមានសិទ្ធិរំលាយនៅក្នុងខ្លឹមសារនៃកិច្ចសន្យាគូភាគីគួរតែព្រមព្រៀងគ្នាសរសេរជាលាយលក្ខ័អក្សរ ឬបើមិនដូច្នោះទេ អាចព្រមព្រៀងគ្នាដោយផ្ទាល់មាត់។

---

[៨] មេធាវី ទេព បូផល, លោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយៈ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), , ទំព័រទី ១៩។

[៩] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧ មាត្រា ៤១៤ ចំណុចទី ១

សិទ្ធិរំលាយកិច្ចសន្យាដែលបានកំណត់នៅក្នុងកិច្ចសន្យាគឺជា***សិទ្ធិរំលាយកិច្ចសន្យា*** ដែលភាគីម្ខាង ឬទាំងសងខាងអាចរំលាយបានដោយផ្អែកទៅលើកិច្ចសន្យានោះផ្ទាល់តែម្តង[10]។

ឧទាហរណ៍ ៖ ប្រសិនបើភាគីបានធ្វើការព្រមព្រៀងគ្នានៅក្នុងកិច្ចសន្យាជាមុនថា "អ្នកទិញអាចរំលាយកិច្ចសន្យាជាឯកតោភាគី ***នៅពេលណាក៏បាន*** ក្នុងរយៈពេលមួយសប្តាហ៍ក្រោយពេលប្រគល់នូវ-កម្មវត្ថុ" ដូច្នេះអ្នកទិញអាចរំលាយកិច្ចសន្យាតាមល័ក្ខខ័ណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យានោះផ្ទាល់តែម្តង។

#### ១.១.៣.៣ ការរំលាយកិច្ចសន្យាដោយផ្អែកទៅលើការព្រមព្រៀង

ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង គឺជាការរំលាយដែលផ្អែកលើឆន្ទៈព្រមព្រៀងរបស់ភាគីដោយពុំមានការកំណត់ទុកជាមុននៅក្នុងកិច្ចសន្យាទេ។ ដូច្នេះ ពុំមានវិវាទនោះទេក្នុង-ករណីដែលភាគីព្រមព្រៀងគ្នារំលាយកិច្ចសន្យា។

ឧទាហរណ៍ ៖ លោក ក ជួលផ្ទះឱ្យកញ្ញា ខ រយៈ០២ឆ្នាំអំឡុងពេលពេលជួលមិនទាន់បានបញ្ចប់នៅឡើយ ប៉ុន្តែលោក ក ចង់បានផ្ទះមកវិញលោក ក បានធ្វើសំណើទៅកញ្ញា ខ អំពីការរំលាយកិច្ចសន្យាជួលដោយយល់ព្រមបង់ការខូចខាតទាំងអស់កញ្ញា ខ បានយល់ព្រម ក្នុងករណីនេះភាគីលោក ក និងកញ្ញា ខ បានព្រមព្រៀងគ្នារំលាយគ្នាកិច្ចសន្យា[11]។

ការរំលាយកិច្ចសន្យាតាមច្បាប់កំណត់ និងរំលាយតាមកិច្ចសន្យា គឺសុទ្ធតែជាការរំលាយដោយឯកតោភាគី លើកលែងតែការរំលាយតាមការព្រមព្រៀងគ្នាប៉ុណ្ណោះ។

## ១.២ ល័ក្ខខ័ណ្ឌនៅក្នុងការរំលាយកិច្ចសន្យា

ភាគីនៃកិច្ចសន្យាមិនអាចរំលាយកិច្ចសន្យាតាមទំនើងចិត្តរបស់ខ្លួនឯងបានទេ ព្រោះបើមានការទទួលស្គាល់ឱ្យមានការរំលាយតាមតែចិត្តរបស់ភាគីម្ខាងនោះនឹងនាំឱ្យការខូចខាតដល់សកម្មភាពជំនួញរបស់ភាគីម្ខាងទៀតមិនខាន។ ដូច្នេះទើបក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាកំណត់នូវល័ក្ខខ័ណ្ឌពីរដើម្បីទទួលស្គាល់នូវការរំលាយរបស់ភាគីម្ខាង។ ល័ក្ខខ័ណ្ឌដែលជាមូលហេតុទូទៅ (១.២.១) និងល័ក្ខខ័ណ្ឌដែលជាមូលហេតុពិសេស(១.២.២)។

### ១.២.១ ល័ក្ខខ័ណ្ឌដែលជាមូលហេតុទូទៅ

ល័ក្ខខ័ណ្ឌដែលជាមូលហេតុទូទៅត្រូវអនុវត្តទៅលើគ្រប់កិច្ចសន្យាទាំងអស់។ ក្នុងករណី

---

[10] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៧៦។

[11] មេធាវី ទេព បូផល, លោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយៈ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩),, ទំព័រទី ២០។

ដែលភាគីណាម្ខាងចង់ប្រើប្រាស់សិទ្ធិរំលាយកិច្ចសន្យានោះ ចាំបាច់ត្រូវបំពេញល័ក្ខខ័ណ្ឌដែលច្បាប់បានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីជាមុនសិន ដែលល័ក្ខខ័ណ្ឌនេះគឺជាប្រភេទកិច្ចសន្យាអញ្ញមញ្ញ (១.២.១.១) និងភាគីម្ខាងទៀតបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ(១.២.១.២)។

### ១.២.១.១ កិច្ចសន្យាអញ្ញមញ្ញ

កិច្ចសន្យាអញ្ញមញ្ញគឺជាកិច្ចសន្យា ដែលភាគីមានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមកដូចជាកិច្ចសន្យាលក់ទិញ កិច្ចសន្យាម៉ៅការ ភតិសន្យា កិច្ចសន្យាលក់ទិញ...[12] ។

កិច្ចសន្យាអញ្ញមញ្ញគឺជាកិច្ចសន្យាដែលបង្កើតឱ្យមានកាតព្វកិច្ចទៅវិញទៅមក (កាតព្វកិច្ចបដិការ) រវាងភាគីទាំងសងខាងនៃកិច្ចសន្យា ពោលគឺភាគីទាំងសងខាងជាម្ចាស់បំណុលផង និងជាកូនបំណុលផង។

ឧទាហរណ៍ ៖ លោក ក លក់ឡានឱ្យលោក ខ តម្លៃ ៥០០០ ដុល្លារ។ លោក ក ត្រូវតែប្រគល់ឡានដល់គាត់បានលក់ទៅឱ្យលោក ខ ( លោក ក គឺជាកូនបំណុល) តែជាថ្នូរ លោក ក មានសិទ្ធិតម្រូវឱ្យលោក ខ ទូទាត់ចំនួនទឹកប្រាក់ដែលបានព្រមព្រៀងគ្នាមកឱ្យគាត់ (លោក ក ជាម្ចាស់បំណុល)។ ជាបញ្ច្រាស់មកវិញ លោក ខ ត្រូវទូទាត់តម្លៃដែលបានព្រមព្រៀងគ្នាទៅឱ្យលោក ក (លោក ខ ជាកូនបំណុល) តែលោក ខ មានសិទ្ធិតម្រូវឱ្យលោក ក ប្រគល់ឡានដែលបានព្រមព្រៀងគ្នាមកឱ្យគាត់ (លោក ខ ជាម្ចាស់បំណុល)។

នៅក្នុងកិច្ចសន្យាអញ្ញមញ្ញ ការសន្យារបស់ភាគីកិច្ចសន្យាទាំងពីរគឺចំណុះគ្នាទៅវិញទៅមក។ ប្រសិនបើអ្នកលក់ត្រូវបានសន្យាថានឹងប្រគល់ទំនិញនេះគឺថាអ្នកលក់ត្រូវទទួលបាននូវតម្លៃដែលបានព្រមព្រៀងគ្នា។ ដូចគ្នានេះដែរ អ្នកទិញត្រូវតែទូទាត់តម្លៃដែលជាថ្នូរនៃការសន្យាក្នុងការប្រគល់ទំនិញ។ ដូច្នេះវាកើតមាននូវចំណងគតិយុត្តរវាងកាតព្វកិច្ចដែលកើតចេញពីកិច្ចសន្យាអញ្ញមញ្ញ[13]។

ការរំលាយកិច្ចសន្យាអាចធ្វើទៅបានចំពោះកិច្ចសន្យាអញ្ញមញ្ញតែប៉ុណ្ណោះ ដោយសារតែការ-រំលាយកិច្ចសន្យាគឺជាប្រព័ន្ធដែលភាគីម្ខាងនៃកិច្ចសន្យាអញ្ញមញ្ញ អាចរួចផុតពីកាតព្វកិច្ចរបស់ខ្លួនដោយការយកការមិនអនុវត្តន៍កាតព្វកិច្ចរបស់ភាគីម្ខាងទៀតមកធ្វើជាមូលហេតុ។

ឧទាហរណ៍ ៖ ក្នុងករណីដែលអ្នកលក់ ក និងអ្នកទិញ ខ បានចុះកិច្ចសន្យាលក់ទិញមួយកន្លែង ប្រសិនបើអ្នកទិញមិនបានបង់ថ្លៃលក់ទេ អ្នកលក់អាចនឹងស្វែងរកអ្នកទិញដីនេះផ្សេងទៀត។ ប៉ុន្តែប្រសិនបើអ្នកលក់ដីមិនបានរំលត់កាតព្វកិច្ចប្រគល់ដីដែលខ្លួនមានតាមកិច្ចសន្យាលក់ទិញដោយ

[12] គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋ-ប្បវេណី″ (ភ្នំពេញ ៖ ទីស្ដីការគណៈរដ្ឋមន្ត្រី នៅឆ្នាំ ២០០៧) លេខរៀងទី ២១។

[13] លោកសាស្ត្រាចារ្យ ញឹក វុធ្ធី, នីតិកាតព្វកិច្ច, ភាគ១ (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) ទំព័រទី ៤។

[13] លោកសាស្ត្រាចារ្យ ញឹក វុធ្ធី, នីតិកាតព្វកិច្ច, ភាគ១ (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច) ទំព័រទី ៤។

រំលាយកិច្ចសន្យាលក់ទិញដីនេះទេ អ្នកលក់ ក ត្រូវទទួលខុសត្រូវចំពោះការមិនអនុវត្តន៍កាតព្វកិច្ច នៅពេលដែលអ្នកទិញ ខ ស្នើផ្តល់ថ្លៃលក់នៅពេលក្រោយវិញ។ ដូច្នេះហើយវាជាការចាំបាច់ចំពោះអ្នកលក់ដែលត្រូវរំលាយកិច្ចសន្យាជាមុនសិន មុននឹងស្វែងរកអ្នកទិញផ្សេងទៀត។ អាស្រ័យហេតុនេះ ចំពោះកិច្ចសន្យាឯកតោភាគី(កិច្ចសន្យាដែលភាគីតែម្ខាងមានកាតព្វកិច្ច)ដូចជាកិច្ចសន្យាប្រទានកម្ម មិនចាំបាច់ទទួលស្គាល់ការរំលាយទេ។ ម្ចាស់បំណុលនៃកិច្ចសន្យាប្រទានកម្មគ្មានផលប្រយោជន៍ក្នុងការរំលាយកិច្ចសន្យានោះទេ ក្នុងករណីដែលទាយកមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន[14]។

ក្នុងករណីដែលមានការមិនអនុវត្តន៍កាតព្វកិច្ចរបស់កូនបំណុល ម្ចាស់បំណុលអាចទាមទារឱ្យអនុវត្តដោយបង្ខំ សងសំណងការខូចខាត ឬរំលាយកិច្ចសន្យា ដោយយោងតាមឱ្យអនុវត្តដោយបង្ខំ សងសំណងការខូចខាត ឬរំលាយកិច្ចសន្យា ដោយយោងតាមបញ្ញត្តិចាប់ពីផ្នែកទី ២ ដល់ផ្នែកទី ៤ នៃជំពូកទី ៨ នេះបាន[15]។

ល័ក្ខខ័ណ្ឌត្រឹមតែជាកិច្ចសន្យាអញ្ញមញ្ញមិនគ្រប់គ្រាន់ទេ សម្រាប់ការរំលាយកិច្ចសន្យាគឺលុះត្រាតែមានការបំពានកិច្ចសន្យាបន្ថែមទៀតទើបនាំឱ្យគ្រប់ល័ក្ខខ័ណ្ឌនៃការរំលាយកិច្ចសន្យា។

### ១.២.១.២ ភាគីម្ខាងទៀតបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ

ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបានដោយសារការបំពានរបស់ភាគីម្ខាងទៀត។ ការបំពានកិច្ចសន្យាធ្ងន់ធ្ងរត្រូវបានបញ្ញត្តិនៅក្នុងមាត្រា ៤០៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី។ ដើម្បីរំលាយកិច្ចសន្យាផ្អែកទៅតាមបញ្ញត្តិនេះគេមិនពិចារណាអំពីកំហុសរបស់កូនបំណុលទេ ប៉ុន្តែគេពិចារណាអំពីភាពគ្មានសិទ្ធិតវ៉ានៃការមិនអនុវត្តន៍កាតព្វកិច្ចរបស់កូនបំណុល មានន័យថាកូនបំណុលមិនអនុវត្តកាតព្វកិច្ចទាំងខ្លួនគ្មានសិទ្ធិបដិសេធការអនុវត្តន៍កាតព្វកិច្ច (កំណត់ពេលត្រូវអនុវត្ត កូនបំណុលមិនអនុវត្តជាអាទិ៍) ទើបអាចរំលាយកិច្ចសន្យាបាន។ ហេតុនេះ ក្នុងករណីដែលកូនបំណុលមិនអនុវត្តកាតព្វកិច្ចដោយមានសិទ្ធិតវ៉ា ការរំលាយកិច្ចសន្យាមិនអាចធ្វើបានឡើយ។

ឧទាហរណ៍ ៖ នៅក្នុងកិច្ចសន្យាលក់ទិញរថយន្តរវាង លោក ក និងកញ្ញា ខ ដោយលោក ក ត្រូវប្រគល់រថយន្តនៅថ្ងៃទី ០១.០៥.២០១៩ និងកញ្ញា ខ ជាអ្នកទិញត្រូវបង់ប្រាក់នៅថ្ងៃទី ០១.០៦.២០១៩ ក្នុងករណីដែលលោក ក មិនបានប្រគល់រថយន្តតាមពេលកំណត់ហើយកាលបរិច្ឆេទបង់ប្រាក់បានមកដល់ កញ្ញា ខ បដិសេធមិនព្រមបង់ប្រាក់ ខ្ញុំមិនបង់ប្រាក់ទេរហូតដល់លោក ក បានប្រគល់រថយន្ត

[14]ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៨, (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០១០), ទំព័រ ១២៣។

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧, មាត្រា ៤១៤ ចំណុចទី ១។

លោក ក មិនអាចយកមូលហេតុការមិនអនុវត្តន៍កាតព្វកិច្ចរបស់កញ្ញា ខ ជាមូលហេតុនៃការរំលាយកិច្ចសន្យាបានទេ ពីព្រោះកញ្ញា ខ មិនបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ ការមិនអនុវត្តន៍កាតព្វកិច្ចរបស់កញ្ញា ខ ពុំមានភាពផ្ទុយច្បាប់(កញ្ញា ខ មានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា)។ ក្នុងករណីដែលលោក ក ប្រគល់រថយន្តរួចហើយ ប៉ុន្តែកញ្ញា ខ មិនបានបង់ប្រាក់តាមពេលកំណត់លោក ក អាចរំលាយកិច្ចសន្យាបានពីព្រោះ កញ្ញា ខ បដិសេធមិនអនុវត្តកាតព្វកិច្ចទាំងខ្លួនគ្មានសិទ្ធិនឹងបដិសេធ(គ្មានសិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា) ហេតុនេះក្រៅពីការអះអាងអំពីការបំពានកិច្ចសន្យាធ្ងន់ធ្ងរលោក ក គប្បីត្រូវអះអាងថា ខ្លួនបានប្រគល់រថយន្តឱ្យកញ្ញា ខ រួចហើយ ដើម្បីឱ្យកញ្ញា ខ រលត់សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នានឹងនាំឱ្យកញ្ញា ខ គ្មានសិទ្ធិតវ៉ាក្នុងការមិនអនុវត្តន៍កាតព្វកិច្ច[16]។

ការរំលាយកិច្ចសន្យា មិនមែនមានតែការមិនអនុវត្តន៍កាតព្វកិច្ចទេគឺត្រូវមាន ***ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ*** ដែលជាល័ក្ខខ័ណ្ឌនៃការរំលាយកិច្ចសន្យា។ ដោយសារការរំលាយកិច្ចសន្យាគឺជាឧបករណ៍ដ៏មានឥទ្ធិពល ដែលទទួលស្គាល់ឱ្យភាគីម្ខាងនៃកិច្ចសន្យាអាចបដិសេធចោលនូវកិច្ចសន្យាដោយឯកឯង ដូច្នេះវាមិនសមហេតុផលទេក្នុងការអនុញ្ញាតឱ្យភាគីម្ខាងរំលាយកិច្ចសន្យាដោយហេតុថាមកពីមិនអនុវត្តកាតព្វកិច្ចបន្តិចបន្តួច។ ដូច្នេះហើយ ការរំលាយកិច្ចសន្យា អាចធ្វើទៅបានតែក្នុងករណីដែលការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរតែប៉ុណ្ណោះ។

កិច្ចសន្យាត្រូវបានសង្គ្រោះនៅពេលដែលភាគីនៃកិច្ចសន្យារងការបំពានពីភាគីម្ខាងទៀតនៃកិច្ចសន្យាតាមរយៈការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ យ៉ាងណាក៏ដោយ ទម្រង់នៃការមិនអនុវត្តន៍កាតព្វកិច្ចមិនគ្រប់គ្រាន់សម្រាប់ល័ក្ខខ័ណ្ឌដែលនាំមានការរំលាយកិច្ចសន្យានោះទេ ប៉ុន្តែការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរបន្ថែមពីលើការមិនអនុវត្តន៍កាតព្វកិច្ចទៀត ទើបគ្រប់ជាល័ក្ខខ័ណ្ឌដែលនាំឱ្យមានការរំលាយកិច្ចសន្យា។

អនុលោមតាមមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណីកម្ពុជា ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅទៅដល់ករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។ ត្រូវចាត់ទុកថាជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរមានដូចជា ៖

**ក** - ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀត ដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។

[16] មេធាវី ទេព បូផល និងលោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយៈ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), ទំព័រទី ៣៣។

**ខ** - ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យាក្នុងករណីគោលបំណងនៃ-កិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ។

**គ** - ភាគីមិនអាចអនុវត្តករណីយកិច្ចផ្ដល់តាវកាលិកចម្បងរបស់ខ្លួនបានទេ។

**ឃ** - ការបំពាននូវកិច្ចសន្យាដែលមានភាពហួសហេតុដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគីហើយមិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន[17]។

រហូតមកទល់នឹងពេលនេះ ការបកស្រាយមាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណីមានភាពមិនស្របគ្នាចំពោះអ្នកច្បាប់[18]។

ដើម្បីសិក្សាលំអិតអំពី***ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ*** នោះគេត្រូវសិក្សាអំពីករណីនីមួយៗដូចខាងលើនេះសិន ដូចជាការយឺតយ៉ាវក្នុងការអនុវត្តន៍កាតព្វកិច្ចទោះបីជាមានការដាស់តឿនពីភាគីម្ខាងទៀតក៏ដោយ (ក) ការមិនអនុវត្តន៍កាតព្វកិច្ចតាមពេលវេលាគឺជាចំណុចសំខាន់ (ខ) ភាគីមិនអាចផ្ដល់តាវកាលិកចម្បងរបស់ខ្លួនបានទេ (គ) និងការបាត់បង់ទំនុកចិត្តរបស់ភាគី (ឃ)។

## ក. ការរំលាយកិច្ចសន្យាដោយសារការយឺតយ៉ាវក្នុងការអនុវត្តន៍

យោងតាមមាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច ក បញ្ញត្តិថា ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀតដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ដោយកំណត់អំឡុងពេលសមស្របដើម្បីឱ្យអនុវត្តកាតព្វកិច្ចហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ ភាគីអាចរំលាយកិច្ចសន្យាបានភ្លាម។ បើទោះបីជាភាគីម្ខាងទៀតបានអនុវត្តកាតព្វកិច្ច ក្រោយពេលអំឡុងពេលសមរម្យក៏ដោយក៏គ្មានន័យក្នុងការបន្តអានុភាពកិច្ចសន្យានោះដែរ[19]។

ការរំលាយតាមរយៈការដាស់តឿន ជាការរំលាយក្នុងករណីភាគីម្ខាងមិនអនុវត្តកាតព្វកិច្ចតាមការកំណត់ហើយភាគីម្ខាងទៀតបានដាស់តឿនភាគី ដែលមិនអនុវត្តកាតព្វកិច្ចដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្ត ប៉ុន្តែអំឡុងពេលសមរម្យបានកន្លងផុតភាគីនោះនៅតែមិនអនុវត្ត។ តើអំឡុងពេលសមរម្យមានរយៈពេលប៉ុន្មាន?

- អំឡុងពេលសមរម្យ ជាការគណនាអំឡុងពេលដោយសន្និដ្ឋានថាកូនបំណុលបានរៀបចំដើម្បីអនុវត្តមួយភាគធំ។
- ករណីមានការជូនដំណឹងដោយមិនបានកំណត់អំឡុងពេលសមរម្យ។

[17] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧ មាត្រា ៤០៨។

[18] ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់លោកសាស្ត្រាចារ្យ សេង នាង, ចៅក្រមនៃតុលាការកំពូល,កិច្ចពិភាក្សាស្ដីពីការរំលាយកិច្ចសន្យា, រៀបចំដោយៈ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩)។

[19] សូមមើលគម្រូកិច្ចសន្យាលក់ទិញក្នុងឧបសម្ព័ន្ធទី ២។

ទោះបីជាការកំណត់ពេលមិនសមរម្យ ឬមិនបានកំណត់ពេលក៏ដោយក៏ការរំលាយអាចធ្វើបានដែរ ពេលដែលអំឡុងពេលសមរម្យបានកន្លងផុតចាប់ពីពេលបានដាស់តឿននោះ។

ជាគោលការណ៍កូនបំណុលត្រូវអនុវត្តកាតព្វកិច្ចតាមពេលវេលាកំណត់។ បើទោះបីជាការ-មានការយឺតយ៉ាវក្នុងការអនុវត្តន៍ក៏មានរយៈពេលតិចតួច ព្រោះកូនបំណុលគួរតែរៀបចំដើម្បីអនុវត្តមួយភាគធំ ដូច្នេះម្ចាស់បំណុលគ្រាន់តែផ្តល់អំឡុងពេលសមរម្យក្រោយពេលដាស់តឿនជាការគ្រប់-គ្រាន់។

ក្នុងករណីមានការអះអាងអំពីការរំលាយកិច្ចសន្យាតាមរយៈការដាស់តឿនភាគីត្រូវអះអាងអង្គហេតុចម្បង៖

១.ការកំណត់ពេលអនុវត្ត។

២.ការកន្លងផុតនៃពេលអនុវត្ត។

៣.បានដាស់តឿនដោយកំណត់អំឡុងពេលសមរម្យ។

៤.អំឡុងពេលសមរម្យបានកន្លងផុត។

៥.ម្ចាស់បំណុលស្នើផ្តល់ការសង[20]។

ល័ក្ខខ័ណ្ឌដែលនាំឱ្យមានការចាត់ទុកថាមានការយឺតយ៉ាវក្នុងការអនុវត្តន៍កាតព្វកិច្ចគឺ ៖

- ប្រសិនបើមានពេលកំណត់ពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ចនៅពេលដល់កាលកំណត់នោះ។
- ប្រសិនបើមានកំណត់ពេលមិនពិតប្រាកដសម្រាប់អនុវត្តកាតព្វកិច្ច នៅពេលដែលកូនបំណុលនោះដឹងថា ដល់ពេលកំណត់ហើយ។
- ប្រសិនបើមិនបានកំណត់ពេលសម្រាប់អនុវត្តកាតព្វកិច្ចទេ នៅពេលដែលកូនបំណុលនោះទទួលការទាមទារឱ្យអនុវត្ត[21]។

មានន័យថា ទោះបីជាកូនបំណុលយឺតយ៉ាវក្នុងការអនុវត្តន៍កាតព្វកិច្ចក៏ដោយ ប៉ុន្តែប្រសិនបើម្ចាស់បំណុលមិនបានធ្វើការដាស់តឿន និងកំណត់អំឡុងពេលសមរម្យទេ មិនអាចចាត់ទុកថាជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរបានទេ។

អំឡុងពេលសមរម្យនេះមិនមែនជាការគណនាអំឡុងពេលចាំបាច់ដើម្បីរៀបចំក្នុងការអនុវត្តន៍ពីពេលដែលបានទទួលការដាស់តឿនរហូតដល់ការអនុវត្តន៍ស្ថាពរនោះទេ ប៉ុន្តែជាការគណនាអំឡុងពេលដោយសន្និដ្ឋានថា ការរៀបចំដើម្បីអនុវត្តមួយភាគធំបានធ្វើរួចរាល់ហើយ។

[20] មេធាវី ទេព បូផល និងលោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយៈ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), ទំព័រទី ៣៥។

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧ ,មាត្រា ៣៩១។

ទោះបីជាបានដាស់តឿនដោយកំណត់អំឡុងពេលមិនសមរម្យ ឬមិនបានកំណត់ពេលសមរម្យ បានកន្លងផុតចាប់ពីពេលដាស់តឿន ឬទោះបីជាគ្មានការដាស់តឿនក៏ដោយ ក៏កូនបំណុលត្រូវអនុវត្តនៅពេលកំណត់អនុវត្តមកដល់ដែរ។ បើទោះបីជាមានការយឺតយ៉ាវក្នុងការអនុវត្តន៍ក៏ដោយក៏-ជាទូទៅ កូនបំណុលគួរតែបានរៀបចំដើម្បីអនុវត្តហើយមួយភាគធំដែរ ហេតុនេះយើងគ្រាន់តែផ្តល់អំឡុងពេលសមរម្យ ក្រោយពេលដាស់តឿនជាការគ្រប់គ្រាន់[22]។

## ខ. ការរំលាយកិច្ចសន្យាដោយសារពេលវេលាគឺជាចំណុចសំខាន់

នៅក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេច ប្រសិនបើការអនុវត្តន៍កាតព្វកិច្ចមិនត្រូវបានបំពេញនៅក្នុងពេលកំណត់នោះ វាត្រូវបានគេចាត់ទុកថាជា ***ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ*** ប្រសិនបើកូនបំណុលមិនបានបំពេញកាតព្វកិច្ចនៅពេលកំណត់នោះ។ ចំពោះ-សកម្មភាពដែលមានកំណត់ពេលបែបនេះ ភាគីអាចរំលាយកិច្ចសន្យាភ្លាមៗដោយ***មិនចាំបាច់ដាស់តឿន***។

ឧទាហរណ៍ ៖ ភាគីបានកម្មង់នំខេកសម្រាប់ពិធីរៀបការ ប៉ុន្តែអ្នកធ្វើនំខេកមិនអាចប្រគល់ទាន់នៅថ្ងៃរៀបការ។ ក្រោយពិធីរៀបការកន្លងផុត ទោះបីជាអនុវត្តការប្រគល់ក៏ដោយគ្មានន័យដែរ។

កិច្ចសន្យាប្រភេទនេះ ទោះបីជាកូនបំណុលអាចអនុវត្តនៅពេលក្រោយក៏ដោយក៏ពុំមានន័យដែរ ហេតុនេះភាគីអាចរំលាយកិច្ចសន្យាបានភ្លាមៗដោយមិនចាំបាច់ធ្វើការដាស់តឿន[23]។

គេបានបែងចែកជា ២ ប្រភេទនៃពេលវេលាជាចំណុចសំខាន់នៅក្នុងការអនុវត្តន៍កាតព្វកិច្ច។

**ប្រភេទទី ១** គឺកិច្ចសន្យាដែលគោលបំណងរបស់វាមិនអាចសម្រេចបានសោះតាមលក្ខណៈរបស់កិច្ចសន្យានោះ ប្រសិនបើការអនុវត្តន៍កាតព្វកិច្ចមិនត្រូវបានធ្វើឡើងនៅក្នុងពេលកំណត់នោះ។

ឧទាហរណ៍ ៖ ក បញ្ជាឱ្យជាងកាត់សំលៀកបំពាក់ ខ កាត់សំលៀកបំពាក់អាពាហ៍ពិពាហ៍សម្រាប់ស្លៀកក្នុងពិធីរៀបអាពាហ៍ពិពាហ៍នៅថ្ងៃទី ៧ ខែ វិច្ឆិកា0 ឆ្នាំ ២០១០។ ប៉ុន្តែពេលកំណត់មកដល់ហើយជាង ខ កាត់សំលៀកបំពាក់មិនទាន់ដេររួចរាល់ទៀត។ ក្នុងករណីនេះ ក អាចរំលាយ-កិច្ចសន្យាបានដោយសារ ខ បានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ វាមានលក្ខណៈច្បាស់លាស់ថាគោលបំណងនៃកាតព្វកិច្ចនេះមិនត្រូវបានសម្រេច ប្រសិនបើការអនុវត្តន៍កាតព្វកិច្ចមិនត្រូវបានធ្វើ

[22] សាស្ត្រាចារ្យ UMEMOTO YUMI , ការរំលាយកិច្ចសន្យា, (ភ្នំពេញ៖ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់,នាយក-ដ្ឋានសហប្រតិបត្តិការអន្តរជាតិ) , ទំព័រទី ១៣

[23] មេធាវី ទេព បូផល និងលោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយ៖ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩),ទំព័រទី ៣៨។

ឡើងនៅកាលបរិច្ឆេទកំណត់គឺថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១០ដោយផ្អែកទៅតាមលក្ខណៈនៃខ្លឹមសារខាងលើនៃកិច្ចសន្យា។

**ប្រភេទទី ២** គឺកិច្ចសន្យាដែលត្រូវអនុវត្តនៅក្នុងពេលកំណត់ដោយស្របទៅតាមឆន្ទៈរបស់ភាគី។

ឧទាហរណ៍ ៖ ក បានបញ្ជាទិញស្រាបៀរជាច្រើនកេះសម្រាប់ពិធីជប់លៀងពេលល្ងាចរបស់ខ្លួន ប៉ុន្តែឈ្មួញលក់ស្រាបៀរ ខ មិនបានប្រគល់ស្រាបៀរនោះនៅថ្ងៃពិធីជប់លៀងទេ។ ចំពោះករណីនេះ ក ចាំបាច់ត្រូវប្រាប់ថាគាត់ត្រូវការស្រាបៀរជាច្រើនកេះ***នៅថ្ងៃណាមួយជាក់លាក់*** ដើម្បីអះអាងថាវាត្រូវបានចាត់ទុកថាជាការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងររបស់ ខ ព្រោះវាមិនមានភាព-ច្បាស់លាស់ថា គោលបំណងនៃកិច្ចសន្យានេះមិនត្រូវសម្រេចប្រសិនបើការអនុវត្តន៍កាតព្វកិច្ចមិនត្រូវបានធ្វើឡើងនៅក្នុងកាលបរិច្ឆេទកំណត់។

ប្រសិនបើ ក បានប្រាប់ថា គាត់ត្រូវការស្រាបៀរជាច្រើនកេះនៅថ្ងៃជប់លៀង ទោះបីជា ខ បានអនុវត្តកាតព្វកិច្ចប្រគល់ស្រាបៀរនៅពេលក្រោយមកក៏ដោយ ក៏វាគ្មានប្រយោជន៍សម្រាប់ម្ចាស់បំណុលដែរ។ ព្រោះថាពិធីជប់លៀងបានបញ្ចប់ ដូច្នេះ ម្ចាស់បំណុលអាចរំលាយកិច្ចសន្យាបានភ្លាមក្រោយពេលកំណត់នោះ។ ម្យ៉ាងទៀត វាក៏ចាត់ទុកថាជាការយឺតយ៉ាវក្នុងការអនុវត្តន៍កាតព្វកិច្ចដែរ ព្រោះការកំណត់ពេលវេលាមិនពិតប្រាកដ ប៉ុន្តែកូនបំណុលបានទទួលការទាមទារឱ្យអនុវត្ត[24]។

### គ. ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ

ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបាន[25]។

ឧទាហរណ៍ ៖ នៅថ្ងៃទី ១ ខែ សីហា ក ចុះកិច្ចសន្យាទិញចូបុរាណពី ខ ក្នុងតម្លៃ ២០០០ដុល្លារ។ ដោយកំណត់ឱ្យ ខ យកចូមកដាក់ក្នុងឃ្លាំងរបស់ ក នៅថ្ងៃទី ១០ ខែ សីហា។ នៅថ្ងៃទី ៩ ខែ សីហា កប៉ាល់ដែលដឹកចូនោះបានលិចបាត់។ ដល់ថ្ងៃកំណត់ ក បានយកប្រាក់ថ្លៃទិញទៅ ហើយទាមទារឱ្យ ខ ប្រគល់ចូ។ យើងសង្កេតឃើញថា ការស្រង់កប៉ាលនាំឱ្យចំណាយប្រាក់ច្រើនហើយពិបាកណាស់ ដូច្នេះ ក អាចរំលាយកិច្ចសន្យាបាន។ នេះគឺជាអលទ្ធភាពក្នុងការអនុវត្តន៍កាតព្វកិច្ចផងដែរ ព្រោះមិនអាចផ្តល់តាវកាលិកចម្បងដែលជាកម្មវត្ថុនៃកិច្ចសន្យា ហើយគោលបំណងនៃកិច្ចសន្យាមិនអាចសម្រេចបាន។

[24] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧, មាត្រា ៣៩១ ចំណុច គ។

[25] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧, មាត្រា ៤០៨ ចំណុច គ។

នៅពេលដែលមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងបានទេ វាក្លាយទៅជាអលទ្ធភាពនៅក្នុងការអនុវត្តន៍។ អលទ្ធភាពនេះត្រូវរាប់បញ្ចូលទាំងករណីដែលការអនុវត្តន៍កាតព្វកិច្ចនោះត្រូវបានវាយតម្លៃថា មិនអាចធ្វើកើតតាមស្ថានភាពសង្គម ឬសេដ្ឋកិច្ច។

ឧទាហរណ៍៖ ករណីការលក់ទិញថូបុរាណ

- ថូនោះបានបែកខ្ទេច ➡ អលទ្ធភាពតាមស្ថានភាពរូបធាតុ។
- ថូនោះត្រូវបានចោរលួច ➡ អលទ្ធភាពតាមស្ថានភាពសង្គម។
- ថូនោះបានលិចបាត់ ➡ អលទ្ធភាពតាមស្ថានភាពសេដ្ឋកិច្ច។

បើសិនជាច្បាស់ថាមិនអាចអនុវត្តកាតព្វកិច្ចបាននៅថ្ងៃអនុវត្ត នោះអលទ្ធភាពក្នុងការអនុវត្តន៍កើតឡើងនៅចំណុចពេលនោះ។ ហេតុនេះមិនចាំបាច់ត្រូវផុតអំឡុងពេលត្រូវអនុវត្ត និងមិនចាំបាច់ដាស់តឿនឡើយ[26]។

ប្រសិនបើការណ៍ដែលមិនអាចអនុវត្តកាតព្វកិច្ច នៅពេលកំណត់ដែលត្រូវអនុវត្តមានពិតប្រាកដមុនពេលកំណត់ដែលត្រូវអនុវត្តការអនុវត្តន៍កាតព្វកិច្ចត្រូវក្លាយជាអលទ្ធភាពនៅពេលនោះ [27] ។ ក្នុងករណីនេះមិនចាំបាច់ផុតអំឡុងពេលអនុវត្តទេក៏ម្ចាស់បំណុលអាចរំលាយកិច្ចសន្យាដោយមិនចាំបាច់ដាស់តឿន។

ឧទាហរណ៍ ៖ ក ចុះកិច្ចសន្យាលក់ទិញរថយន្តជាមួយ ខ។ ក គឺជាអ្នកលក់ ហើយ ខ គឺជាអ្នកទិញ។ ក្រោយពីបង្កើតកិច្ចសន្យារួច ខ បានបង់ថ្លៃលក់ទិញរថយន្តទៅឱ្យ ក ក៏ប៉ុន្តែ ម៉ាស៊ីនរបស់រថយន្តនោះខូចដោយសារទឹកជំនន់នៅមុនពេលប្រគល់។ ក្នុងករណីនេះទោះបីជារថយន្តស្ថិតនៅក្នុងទ្រង់ទ្រាយដើមក៏ដោយ ក៏កាតព្វកិច្ចក្លាយទៅជាអលទ្ធភាពដែរ ព្រោះ ខ មិនអាចបើករថយន្តនោះបានទេ។ ដូច្នេះ ខ អាចរំលាយកិច្ចសន្យាទិញលក់នោះបានភ្លាម ព្រោះថា ក មិនអាចប្រគល់រថយន្តដែលជាតាវកាលិកចម្បងនៃកិច្ចសន្យាទិញលក់ទៅឱ្យ ខ បាន។

ផ្ទុយមកវិញនៅក្នុងករណីដែលមានកាតព្វកិច្ចបន្ទាប់បន្សំ ក្រៅពីកាតព្វកិច្ចចម្បងនោះ ម្ចាស់បំណុលមិនអាចរំលាយកិច្ចសន្យា ដោយផ្អែកទៅលើការមិនអនុវត្តន៍កាតព្វកិច្ចបន្ទាប់បន្សំបានទេ។

ឧទាហរណ៍ ៖ ក បានចុះកិច្ចសន្យាលក់ដីរបស់ខ្លួនឱ្យទៅ ខ ហើយពួកគេក៏បានព្រមព្រៀងគ្នាថា ក ត្រូវបង់ថ្លៃចុះបញ្ជី។ ក្រោយពីការបង្កើតកិច្ចសន្យា ខ បានបង់ថ្លៃចុះបញ្ជីជំនួស ក ប៉ុន្តែ ក មិនបានបង់ថ្លៃចុះបញ្ជីនេះទៅឱ្យ ខ ទេ។ ក្នុងករណីនេះ ការបង់ថ្លៃចុះបញ្ជីគឺជាកាតព្វកិច្ចបន្ទាប់បន្សំ ដូច្នេះ គេអាច

[26] មេធាវី ទេព បូផល និងលោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយៈ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), ទំព័រទី ៤៣។

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧, មាត្រា ៣៩២។

ពិចារណាថា ខ មិនអាចរំលាយកិច្ចសន្យា ដោយផ្អែកទៅលើមូលហេតុនៃការមិនអនុវត្តន៍កាតព្វកិច្ចបាន ទេ[28]។

### ឃ. ការរំលាយកិច្ចសន្យាដោយមូលហេតុបាត់បង់ជំនឿទុកចិត្តរបស់ភាគី

ការបំពានកិច្ចសន្យាមានភាពហួសហេតុដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន[29] ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យាបាន។ ក៏ប៉ុន្តែ ការរំលាយកិច្ចសន្យាប្រភេទនេះគឺពុំមានភាពច្បាស់លាស់ឡើយ។

ឧទាហរណ៍ ៖ ក បានលក់វត្ថុធាតុដើមនៃផលិតផលទៅឱ្យ ខ ជាបន្តបន្ទាប់ហើយ ខ បានផលិតនូវផលិតផលរបស់ខ្លួនពីវត្ថុធាតុដើមនោះ។ ក ផ្គត់ផ្គង់នូវវត្ថុដើមនោះមានការយឺតយ៉ាវ ២ ទៅ ៣ ថ្ងៃជារឿយៗ ហើយជាលទ្ធផល ខ មិនអាចផលិតនូវផលិតផលរបស់ខ្លួនដែរ ដែលកើតមានជាញឹកញាប់។ វាមានលក្ខណៈលំបាកសម្រាប់ ខ ក្នុងការរក្សានូវទំនុកចិត្តចំពោះ ក ទោះបីជាការបំពានកិច្ចសន្យាម្តងៗ។ ដូច្នេះ ខ អាចរំលាយកិច្ចសន្យាដោយសារតែការបាត់បង់ជំនឿទុកចិត្តរវាងគូភាគី។

ចំពោះការរំលាយកិច្ចសន្យាដោយយកមូលហេតុបាត់បង់ជំនឿទុកចិត្ត ច្រើនកើតមាននៅលើកិច្ចសន្យាដែលធ្វើរវាងភតិក: និងភតិបតី(ភតិសន្យា)។

ឧទាហរណ៍ ៖ ក្នុងការបង់ថ្លៃឈ្នួលជាដើម ហើយប្រសិនបើការខកខានបង់ប្រាក់ឈ្នួល០១ ដង ឬ ០២ ដង យើងអាចបកស្រាយថាមិនមែនជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរទេ (ដូច្នេះ ភតិបតីមិនអាចរំលាយកិច្ចសន្យាបានឡើយ)។ ប៉ុន្តែបើភតិបក:មិនបានបង់ថ្លៃឈ្នួលដែលមានចំនួន ០៤ ដងទៅ ០៥ ដង យើងអាចបកស្រាយថាជាការបំពានកិច្ចសន្យាធ្ងន់ធ្ងរ(ដូច្នេះ ភតិបតីអាចរំលាយកិច្ចសន្យាបាន)។ ចំពោះការអនុវត្តន៍នៅប្រទេសជប៉ុន ការមិនបានបង់ប្រាក់ឈ្នួលចំនួន ០៦ ដង ទើបចាត់ទុកថាបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ[30]។

### ១.២.២ល័ក្ខខ័ណ្ឌដែលជាមូលហេតុពិសេស

ការរំលាយកិច្ចសន្យាដែលធ្វើទៅតាមល័ក្ខខ័ណ្ឌ ដែលជាមូលហេតុពិសេសគឺសំដៅទៅដល់ការរំលាយកិច្ចសន្យាតាមកិច្ចសន្យាសំខាន់នីមួយៗនៅក្នុងគន្ថីទី៥ នៃក្រមរដ្ឋប្បវេណីថ្មីឆ្នាំ ២០០៧។ នៅក្នុងល័ក្ខខ័ណ្ឌនេះការរំលាយកិច្ចសន្យា គឺមិនចាំបាច់អនុលោមទៅតាមការរំលាយកិច្ចសន្យាតាមមូលហេតុទូទៅនោះទេ ដោយសារតែការរំលាយកិច្ចសន្យាតាមមូលហេតុពិសេសត្រូវបានបញ្ញត្ត

[28] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៨២។

[29] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧ មាត្រា ៤០៨ ចំណុច ឃ។

[30] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៨៣។

យ៉ាងច្បាស់លាស់នៅក្នុងកិច្ចសន្យាសំខាន់ៗនៅក្នុងគន្លឹទី ៥ ក៏ដូចជាបញ្ជាក់បន្ថែមនូវមូលហេតុដទៃផ្សេងទៀតក្រៅពីល័ក្ខខ័ណ្ឌដែលជាមូលហេតុទូទៅ ប្រសិនបើក្នុងករណីដែលមានអង្គហេតុណាមួយកើតឡើងដូចមានចែងយ៉ាងច្បាស់ៗនៅក្នុងកិច្ចសន្យាសំខាន់ៗ នោះភាគីដែលមានសិទ្ធិ-រំលាយតាមល័ក្ខខ័ណ្ឌពិសេសនេះអាចរំលាយកិច្ចសន្យាបាន។

ឧទាហរណ៍ ៖ ក្រមរដ្ឋប្បវេណីដែលប្រកាសឱ្យប្រើឆ្នាំ ២០០៧ មាត្រា ៥៣៣ ការទទួលខុស-ត្រូវក្នុងការធានាចំពោះករណីដែលសិទ្ធិមួយភាគជាសិទ្ធិរបស់អ្នកដទៃបានបញ្ញត្តថា ៖

១ - ក្នុងករណីសិទ្ធិមួយភាគក្នុងចំណោមសិទ្ធិដែលជាកម្មវត្ថុនៃការលក់ទិញគឺជាសិទ្ធិរបស់អ្នកដទៃហើយបើអ្នកលក់មិនអាចទទួលសិទ្ធិនៃភាគនោះដើម្បីផ្ទេរទៅឱ្យអ្នកទិញបានទេ អ្នកទិញអាចទាមទារឱ្យបន្ថយនូវតម្លៃតាមសមាមាត្រនៃភាគនោះបាន។

២ - ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើនៅពេលធ្វើកិច្ច-សន្យា អ្នកទិញមិនបានដឹងថា ភាគខ្វះនោះមិនមែនជារបស់អ្នកលក់ទេ ហើយបើទទួលស្គាល់ថាអ្នកទិញនឹងមិនទិញតែភាគដែលសល់តែប៉ុណ្ណោះទេ ***អ្នកទិញនោះអាចរំលាយកិច្ចសន្យាបាន*** ។

៣ - ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បើនៅពេលធ្វើកិច្ចសន្យាអ្នកទិញមិនបានដឹងថា សិទ្ធិមួយភាគនោះមិនមែនជារបស់អ្នកលក់ទេ អ្នកទិញក៏អាចទាមទារសំណងនៃការខូចខាតបានដែរ។

ឧទាហរណ៍ ៖ មាត្រា ៦៤៧ នៃក្រមរដ្ឋប្បវេណី ការរំលាយកិច្ចសន្យាអាណត្តិ

១- ភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិ នៅពេលណាក៏បាន។

២- ភាគីម្ខាងទៀតត្រូវសងសំណងនៃការខូចខាត ប្រសិនបើបានរំលាយកិច្ចសន្យាអាណត្តិនៅក្នុងអំឡុងពេលដែលធ្វើឱ្យខូចផលប្រយោជន៍ចំពោះភាគីម្ខាងទៀត។

សរុបសេចក្តីមក មូលហេតុពិសេសត្រូវបានយកមកអនុវត្តជាអាទិភាព ប្រសិនបើមូលហេតុពិសេសត្រូវបានចែងយ៉ាងច្បាស់ សម្រាប់ការអនុវត្តន៍ជាក់ស្តែង។ ប្រសិនបើមូលហេតុពិសេសពុំ-ត្រូវបានបញ្ញត្តិទេ នោះមូលហេតុទូទៅនឹងត្រូវយកមកអនុវត្ត។ ក្នុងករណីដែលមូលហេតុទូទៅ និងមូលហេតុពិសេសមានចែងដូចគ្នា នោះមូលហេតុពិសេសត្រូវមានឧត្តមានុភាពជាង[31]។

[31] ប្រសាសន៍លោកស្រី មេធាវី ទេព បូផល, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយ៖ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩)។

# ជំពូកទី ២

# នីតិវិធីនៃការអនុវត្តន៍

# សិទ្ធិរំលាយកិច្ចសន្យា

# ជំពូកទី ២
# នីតិវិធីនៃការអនុវត្តន៍សិទ្ធិរំលាយកិច្ចសន្យា

ប្រសិនបើភាគីណាម្ខាងចង់រំលាយកិច្ចសន្យា នោះភាគីម្ខាងនោះត្រូវធ្វើសកម្មភាពមួយចំនួន ដែលជាកាតព្វកិច្ចកំណត់ដោយច្បាប់ លើកលែងតែមានការព្រមព្រៀងគ្នារវាងគូភាគី ទើបអាចទទួលស្គាល់នូវការរំលាយនោះបាន។

វិធីក្នុងការរំលាយកិច្ចសន្យាគឺ***ភាគីម្ខាង*** ដែលមានសិទ្ធិរំលាយអាចរំលាយកិច្ចសន្យាដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន[32]។ ការរំលាយកិច្ចសន្យាជាសកម្មភាពឯកតោភាគី។ ដូចនេះអ្នកមានសិទ្ធិរំលាយកិច្ចសន្យា អាចរំលាយដោយឯកឯងបានដោយគ្រាន់តែបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតជាការគ្រប់គ្រាន់[33]។ ការបង្ហាញឆន្ទៈរបស់ភាគីដែលមានបំណងបង្កើតអានុភាពគតិយុត្តហៅថា ការបង្ហាញឆន្ទៈ។ ការបង្ហាញឆន្ទៈត្រូវមានអានុភាពចាប់ពីពេលដែលការជូនដំណឹងអំពីការបង្ហាញឆន្ទៈនោះបានទៅដល់ភាគីម្ខាងទៀត[34]។ ការបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតអាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលិខិត ឬជាអ៊ីម៉ែលជាដើម[35]។ ទោះបីជាភាគីមានសិទ្ធិរំលាយកិច្ចសន្យាក៏ពិតមែន ប៉ុន្តែមិនមានន័យថាកិច្ចសន្យាត្រូវរំលាយដោយស្វ័យប្រវត្តិនោះទេគឺលុះត្រាតែមានការជូនដំណឹង។ ក្រៅពីការបង្ហាញឆន្ទៈនៃការរំលាយហើយគូភាគីក៏អាចអនុវត្តនីតិវិធីរំលាយកិច្ចសន្យាតាមមធ្យោបាយផ្សេងទៀតផងដែរ។

តើនីតិវិធីនៃការរំលាយអាចត្រូវបានធ្វើឡើងយ៉ាងដូចម្តេច? ហើយប្រសិនបើភាគីដែលមានសិទ្ធិរំលាយមិនបានអនុវត្តសិទ្ធិរំលាយកិច្ចសន្យាទេ តើនឹងមានអានុភាពដូចម្តេច?

ភាគីអាចរំលាយកិច្ចសន្យាតាមនីតិវិធីនៃការរំលាយកិច្ចសន្យា (២.១) ហើយប្រសិនបើភាគីខកខានមិនបានរំលាយកិច្ចសន្យានោះទេ នោះនឹងនាំឱ្យសិទ្ធិរំលាយកិច្ចសន្យាត្រូវរលត់ (២.២) ដែលការរលត់នៃសិទ្ធិរំលាយនេះនឹងកើតមាននូវអានុភាពនៃការរលត់សិទ្ធិរំលាយកិច្ចសន្យា(២.៣)។

## ២.១ នីតិវិធីនៃការរំលាយកិច្ចសន្យា

នីតិវិធីនៃការរំលាយកិច្ចសន្យា គូភាគីអាចបង្ហាញឆន្ទៈរំលាយកិច្ចសន្យាដែលធ្វើឡើងតាមរយៈប្រព័ន្ធតុលាការ (២.១.១) និងតាមរយៈក្រៅប្រព័ន្ធតុលាការ(២.១.២)ផងដែរ។

---

[32] មេធាវី ទេព បូផល និងលោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយ៖ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), ទំព័រទី ៤៨។

[33] លោកសាស្ត្រាចារ្យ គង់ សុភ័ក្រ្ត, សញ្ញាណទូទៅនៃកាតព្វកិច្ច, (ឆ្នាំ ២០១៨-២០១៩), ទំព័រ ២១។

[34] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧, មាត្រា ៣១០។

[35] មេធាវី ទេព បូផល និងលោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយ៖ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), ទំព័រទី ៤៨។

### ២.១.១ ការរំលាយតាមផ្លូវតុលាការ

ក្នុងករណីដែលភតិក: មិនប្រគល់ផ្ទះជូនភតិបតីនោះទេ ភតិបតីមិនអាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់ដោយផ្អែកទៅលើសិទ្ធិទាមទារដោយខ្លួនឯងនោះទេដូចជា ការបណ្តេញចេញ ការចាក់សោផ្ទះដោយភតិក:មិនទាន់រុះរើចេញ ជាដើម ព្រោះភតិក:មានមូលហេតុគតិយុត្តក្នុងការកាន់កាន់ គឺសិទ្ធិកាន់កាប់ដោយផ្អែកទៅតាម មាត្រា២២៧ នៃក្រមរដ្ឋប្បវេណី។ ដូច្នេះភតិបតីត្រូវអនុវត្តសិទ្ធិទាមទារឱ្យប្រគល់តាមរយៈសេចក្តីសម្រេចរបស់តុលាការ។

បើសិនជាការរំលាយកិច្ចសន្យាមានការព្រមព្រៀងពីភាគីទាំងសងខាង ឬមានការទទួលស្គាល់ពីមូលហេតុនៃការរំលាយរបស់ភាគី នោះការរំលាយកិច្ចសន្យាមិនមានបញ្ហាចោទនោះទេ ប៉ុន្តែក្នុងករណីដែលភាគីបដិសេធនៃសិទ្ធិរំលាយរបស់ភាគីម្ខាងទៀត នោះមានតែតុលាការទេដែល-អាចសម្រេចថា កិច្ចសន្យានោះមានមូលហេតុនៃការរំលាយមែនឬមិនមែន តើភាគីបានបំពានកិច្ចសន្យាធ្ងន់ធ្ងរមែន ឬមិនមែន? ព្រោះថាមានតែចៅក្រមទេដែលជាអ្នកមានចំណេះដឹងជ្រៅជ្រះផ្នែកច្បាប់ អាចយល់បានច្បាស់ពីអង្គហេតុ និង អង្គច្បាប់ និងឆ្លងកាត់ការបណ្តុះបណ្តាលជាច្រើន ដើម្បីឱ្យការផ្តល់យុត្តិធម៌ជូនប្រជាពលរដ្ឋមានប្រសិទ្ធភាពល្អ ។

ផ្អែកតាមមាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី វិធីនៃការរំលាយកិច្ចសន្យាគឺជាការបង្ហាញឆន្ទ:របស់-ភាគីម្ខាងទៅភាគីម្ខាងទៀត។ ការរំលាយកិច្ចសន្យាមិនត្រូវការអន្តរាគមន៍របស់តុលាការនោះទេក្នុងករណីដែលបង្ហាញឆន្ទ:ក្រៅតុលាការ។ ប៉ុន្តែប្រសិនបើភាគីបានស្នើសុំឱ្យតុលាការចេញសាលក្រមរំលាយកិច្ចសន្យាជាអាទិ៍ ខ្លឹមសារនៃការទាមទារនេះត្រូវបានចាត់ទុកថាគ្មានផលប្រយោជន៍នៃបណ្តឹងដែលជាមូលហេតុនៃការចេញដីកាសម្រេចលើកចោលបណ្តឹងមិនឆ្លងកាត់ ការទាញហេតុផលដោយផ្ទាល់មាត់[36]។ ប្រសិនបើភាគីបានបង្ហាញឆន្ទ:តាមផ្លូវតុលាការរួចហើយ ដោយមានមូលហេតុតាមផ្លូវច្បាប់ក្នុងការរំលាយកិច្ចសន្យាជាអាទិ៍ អន្តរាគមន៍របស់តុលាការមានភាពចាំបាច់ដើម្បីសម្រេចគោលបំណងរបស់ម្ចាស់បំណុលឱ្យមានលក្ខណៈជាសត្យានុម័ត។

ការសរសេរពាក្យបណ្តឹងឱ្យបានត្រឹមត្រូវទៅតាមនីតិវិធីរដ្ឋប្បវេណី គឺមានភាពចាំបាច់ខ្លាំងណាស់សម្រាប់មេធាវី ជាអាទិ៍ ក្នុងការអនុវត្តន៍សិទ្ធិរំលាយរបស់ភាគីនៅចំពោះមុខតុលាការក្នុងនាមជាអ្នកតំណាងដោយអាណត្តិ[37]។

ឧទាហរណ៍ ៖ រឿងក្តីសិទ្ធិទាមទារឱ្យធ្វើបដិទានផ្អែកទៅលើការរំលាយកិច្ចសន្យា

---

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧០៦/០២១, ៦,កក្កដា,២០០៦, មាត្រា ៨១។

[37] សូមអញ្ជើញមើលគម្រូពាក្យបណ្តឹងក្នុងឧបសម្ព័ន្ធទី ១។

A បានលក់ដី L ឱ្យ B ក្នុងតម្លៃ $10000 នៅថ្ងៃទី 01.01.2019 ដោយបានធ្វើជាលិខិតយថាភូត[38]ហើយ B បានបង់ប្រាក់ $3000 នៅថ្ងៃចុះកិច្ចសន្យា ចំនែកឯប្រាក់ដែលនៅសល់ $7000 B ត្រូវបង់នៅពេលដែលមានការផ្ទេរកម្មសិទ្ធិរួចរាល់គឺនៅថ្ងៃទី 01.02.2019។ កម្មសិទ្ធិត្រូវបានផ្ទេរពី A ទៅ B ហើយ Aបានប្រគល់ដី L តាមពេលកំណត់ ប៉ុន្តែ B មិនបានបង់ប្រាក់ដែលនៅសល់នោះទេ ទោះបីជាមានការដាស់តឿន និងកំណត់អំឡុងពេលសមរម្យក៏ដោយ។ ពេលនេះ Aចង់បានដី L ត្រលប់មកវិញ តើត្រូវធ្វើដូចម្ដេច?

ផ្អែកតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណីក្រៅពីការសរសេរពាក្យបណ្ដឹងជាលាយល័ក្ខអក្សរគឺតម្រូវឱ្យដើមចោទបំពេញនូវចំណុចសារធាតុមួយចំនួន ដូចជា ៖

**ទី១** ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ[39]

(១) បង្គាប់ឱ្យចុងចម្លើយប្រគល់ដីមកឱ្យដើមចោទវិញ។

(២) បង្គាប់ឱ្យចុងចម្លើយធ្វើនីតិវិធីចុះបញ្ជីអំពីការលុបចោលការចុះបញ្ជីការផ្ទេរកម្មសិទ្ធិលើដីដោយមូលហេតុការរំលាយកិច្ចសន្យាចុះថ្ងៃទី 05.04.2019[40]។

(៣) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

**ទី ២** អង្គហេតុចាំបាច់សម្រាប់បញ្ជាក់ការទាមទារ ។

ការបង្កើតកិច្ចសន្យាលក់ទិញ។

**ទី ៣** អង្គហេតុដែលជាមូលហេតុនៃការទាមទារ។

(១) ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។

(២) ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា។

(៣) ផ្ដល់តាវកាលិក (ប្រគល់ដី និងចុះបញ្ជី)។

ក្រោយពីបណ្ដឹងត្រូវបានសរសេររួចហើយ តុលាការនឹងពិនិត្យបណ្ដឹងតាមមាត្រា ៧៨ នៃ-ក្រមនីតិវិធីរដ្ឋប្បវេណី ២០០៦។

ក្នុងករណីដើមចោទសរសេរខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារនោះគឺ ***ទាមទាររំលាយកិច្ចសន្យា*** តុលាការមិនអាចចេញសាលក្រមចំពោះចំណុចនេះបានទេ។ ក្នុងករណីនេះ ដើម-

[38] ច្បាប់ស្ដីពីការអនុវត្តន៍ក្រមរដ្ឋប្បវេណី, នស/រកម/០៥១១/០០៧,៣១ ឧសភា ២០១១, (លិខិតយថាភូតសំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬលិខិតឯកជនដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់), មាត្រា ៩ ចំណុច ក។

[39] សូមអញ្ជើញមើលគម្រូពាក្យបណ្ដឹងក្នុងឧបសម្ព័ន្ធទី ២។

[40] ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, (រាជធានីភ្នំពេញ ៖ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣) ប្រការ ៣១ ពាក្យសុំចុះបញ្ជីអំពីការលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ។

ចោទទាមទាររំលាយកិច្ចសន្យាគឺជាការទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្តដែល-បណ្តឹងប្រភេទនេះអាចទាមទារបានលុះត្រាតែមានមូលដ្ឋាន (ច្បាប់ចែង) ប៉ុន្តែពាក្យបណ្តឹងនេះគ្មានមូលដ្ឋានគ្រប់គ្រាន់ទេ (គ្មានច្បាប់ចែង) ហេតុនេះចាត់ទុកថា ដើមចោទមិនបានសរសេរខ្លឹមសារនៃ-សាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញជាចំណុច ដែលតុលាការអាចបង្គាប់ឱ្យកែតម្រូវតាមបញ្ញត្តិនៃមាត្រា ៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

បន្ទាប់មក នៅពេលពាក្យបណ្តឹងបានបំពេញត្រឹមត្រូវតាមល័ក្ខខ័ណ្ឌទម្រង់ហើយ តុលាការនឹងបញ្ជូនពាក្យបណ្តឹង[41]ទៅចុងចម្លើយ ហើយចុងចម្លើយត្រូវធ្វើឯកសារចម្លើយ ដើម្បីឆ្លើយតបជាមួយនឹងពាក្យបណ្តឹងនោះ[42]។ ប៉ុន្តែក្នុងករណីដែលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅចុងចម្លើយដោយតុលាការពុំ-បានពិនិត្យ និងបង្គាប់ឱ្យកែតម្រូវ ក្នុងករណីនេះតុលាការអាចប្រើប្រាស់សិទ្ធិបំភ្លឺតាមបញ្ញត្តិនៃមាត្រា-៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើម្បីឱ្យមានភាពច្បាស់លាស់ចំពោះការទាមទាររបស់ដើមចោទហើយតុលាការអាចបង្គាប់ឱ្យកែតម្រូវពាក្យបណ្តឹងរបស់ខ្លួនឱ្យបានត្រឹមត្រូវ ដោយធ្វើការផ្លាស់ប្តូរកម្មវត្ថុនៃ-បណ្តឹង ដូចមានបញ្ញត្តិនៃមាត្រា ៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ដូច្នេះ ដើមចោទគប្បីសរសេរថា ***បង្គាប់ឱ្យចុងចម្លើយប្រគល់ដី***[43]។

ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ គឺមានសារៈសំខាន់ខ្លាំងណាស់ ប្រសិនបើមិនបានច្បាស់លាស់ ឬខ្លឹមសារនោះមិនអាចអនុវត្តជាសត្យានុម័តនោះទេធ្វើឱ្យការធ្វើនីតិវិធីគ្មានន័យ ហើយជាគោលការណ៍តុលាការចេញសាលក្រមគឺអនុវត្តតាមអត្ថន័យនៃ-ការទាមទារក្នុងពាក្យបណ្តឹង ប្រសិនបើការទាមទារនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់សារធាតុដោយមានភស្តុតាងបញ្ជាក់ ជាអាទិ៍។

សេចក្តីសម្រេចបញ្ចប់នៃសាលក្រម គឺជាលទ្ធផលនៃការវិនិច្ឆ័យដោយភ្ជាប់ជាមួយនឹងសំអាងហេតុ។ សំអាងហេតុគឺជាវិចារណាកិច្ចគតិយុត្តដោយភ្ជាប់ជាមួយនឹងខ្លឹមសារនៃច្បាប់សារធាតុ និងភស្តុតាង[44]។

សេចក្តីសម្រេចបញ្ចប់នៃសាលក្រមមិនអាចសម្រេចនូវចំណុច ដែលភាគីមិនបានទាមទារនោះទេ និងចំណុចដែលភាគីបានទាមទារត្រូវសម្រេច ទទួលស្គាល់ ឬមិនទទួលស្គាល់។ ទោះបីជា

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧០៦/០២១, ៦,កក្កដា,២០០៦, មាត្រា ៧៩។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧០៦/០២១, ៦,កក្កដា,២០០៦, មាត្រា ១០១។

[43] មេធាវី ទេព បូផល និងលោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយៈ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), ទំព័រទី ៧៧។

[44] មេធាវី អ៊ីវ ប៉ូលី,ការរំលាយកិច្ចសន្យា, វិភាគទានច្បាប់ ចែករំលែក, (០៧,១២,២០១៧), ទំព័រទី ៨។

សិទ្ធិរបស់ភាគីមានច្រើនជាងអ្វីដែលបានស្នើសុំក៏ដោយ និងតុលាការប្រមើលមើលឃើញថាអាចមានលើសក៏ដោយ ក៏តុលាការមិនអាចសម្រេចបាននោះទេ[45]។

ភាគីម្ខាងដែលមានសិទ្ធិរំលាយកិច្ចសន្យា អាចរំលាយកិច្ចសន្យាដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន។ ការបង្ហាញឆន្ទៈនឹងមានអានុភាពពេលទៅដល់ភាគីម្ខាងទៀត។ ពាក្យ-ថាបានទៅដល់មិនចាំបាច់លុះត្រាតែ ភាគីម្ខាងទៀតបានបើកអាននោះទេ សំខាន់គឺការបង្ហាញឆន្ទៈថារំលាយកិច្ចសន្យាបានទៅដល់ភាគីម្ខាងទៀតជាការគ្រប់គ្រាន់។ ក៏ប៉ុន្តែ អ្នកដែលមានសិទ្ធិរំលាយកិច្ចសន្យា ក៏អាចដកឆន្ទៈរំលាយកិច្ចសន្យារបស់ខ្លួនបានដែរ នៅក្នុងករណីដែលការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាមិនទាន់ទៅដល់ភាគីម្ខាងទៀត ឬទៅដល់ព្រមគ្នានឹងឆន្ទៈរំលាយនោះ[46]។

ការបង្ហាញឆន្ទៈរំលាយអាចដាក់ល័ក្ខខ័ណ្ឌបង្អង់បាន[47]។ ល័ក្ខខ័ណ្ឌសំដៅទៅលើព្រឹត្តការណ៍ដែលកើតនាពេលអនាគត ហើយដែលមិនទៀតទាត់។ ទន្ទឹមនឹងនេះ ល័ក្ខខ័ណ្ឌបង្អង់មានន័យថាកាតព្វកិច្ច និងសិទ្ធិនឹងមានអានុភាព នៅពេលដែលល័ក្ខខ័ណ្ឌត្រូវបានបំពេញ[48]។

ឧទាហរណ៍៖ នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកទិញ ខ មិនបានបង់ប្រាក់ថ្លៃទិញនៅកាលបរិច្ឆេទប្រគល់ បន្ទាប់មកអ្នកលក់ ក បានបង្ហាញឆន្ទៈថា ខ្ញុំនឹងរំលាយកិច្ចសន្យានេះក្នុងករណីល័ក្ខខ័ណ្ឌដែល ខ មិនបង់ប្រាក់ក្នុងរយៈពេល ១ សប្តាហ៍។ ឆន្ទៈនៃការរំលាយនេះត្រូវបានដាក់ល័ក្ខខ័ណ្ឌបង្អង់។ ការបង្ហាញឆន្ទៈដោយដាក់ល័ក្ខខ័ណ្ឌបង្អង់មិនចាំបាច់ជូនដំណឹងទេ ព្រោះភតិបតីបានបង្ហាញឆន្ទៈរួចហើយគ្រាន់តែមិនទាន់មានអានុភាពប៉ុណ្ណោះ។

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា មិនអាចដកវិញបានទេ[49] ដោយហេតុថា អាចកើតឡើងនូវភាពច្របូកច្របល់ ប្រសិនបើអនុញ្ញាតឱ្យមានការដក និងកិច្ចសន្យាដែលត្រូវរំលាយហើយនោះប្រែ-ក្លាយទៅជាមានអានុភាពឡើងវិញ។

### ២.១.២ ការរំលាយកិច្ចសន្យាក្រៅប្រព័ន្ធតុលាការ

ថ្វីត្បិតតែការរំលាយកិច្ចសន្យា អាចធ្វើនៅក្រៅតុលាការបានមែនបើយោងទៅតាមមាត្រា៤០៩ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីដែលបានចែងថា "ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើ

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧០៦/០២១, ៦,កក្កដា,២០០៦, មាត្រា ១៨២។

[46] លោក ខាន់ សុខា និងលោកស្រី ឌី លីឡា, ជំពូកទី ៣ ការរំលាយកិច្ចសន្យា, (CAMBODIAN LAW GROUP, សុមេធកុលបុត្ត, ១.២៨.២០១៨), ទំព័រទី ២៥។

[47] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧, មាត្រា ៤០៩ ចំណុចទី ៣។

[48] ក្រុមការងារនៃអនាគតគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៨៣។

[49] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧, មាត្រា ៤០៩ ចំណុចទី ២។

ឡើងក្រៅតុលាការបាន[50]”។ ក៏ប៉ុន្តែដូចដែលបានរៀបរាប់ខាងលើអញ្ចឹងថាបើសិនជាភាគីមិនទទួលស្គាល់សិទ្ធិរំលាយនោះទេ គឺមានតែចៅក្រមទេដែលជាអ្នកមានសិទ្ធិសម្រេចអំពីសិទ្ធិរំលាយនោះ។ ដូច្នេះសង្កេតមើលទៅ យើងឃើញថាមានតែករណីដែលភាគីទទួលស្គាល់នូវសិទ្ធិរំលាយកិច្ចសន្យារបស់ភាគីម្ខាងទៀតទេ ទើបកិច្ចសន្យាអាចត្រូវបានរំលាយនៅក្រៅតុលាការបាន ។ ការរំលាយក្រៅផ្លូវតុលាការនេះ គឺដើម្បីជួយសម្រួលដល់ភាពងាយស្រួលរបស់ភាគីនៃកិច្ចសន្យាជួយសន្សំសំចៃប្រាក់កាស និងថែមទាំងកុំឱ្យមានការកកស្ទះសំណុំរឿងនៅតុលាការទៀតផង។

ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា មិនអាចដកវិញបានទេ បើទោះបីជាបានរំលាយនៅក្រៅតុលាការក៏ដោយ។ ព្រោះនឹងនាំឱ្យមានភាពច្របូកច្របល់ដល់សកម្មភាពជំនួញរបស់ភាគីម្ខាងទៀត ហើយកិច្ចសន្យាដែលត្រូវរំលាយបែរជាមានអានុភាពវិញ។ បញ្ហាចោទឡើងថា ប្រសិនបើមានការព្រមព្រៀងគ្នាក្រៅតុលាការថាមិនរំលាយកិច្ចសន្យាវិញ តើអាចទទួលស្គាល់អានុភាពវិញយ៉ាងដូចម្តេច?

ពាក្យថា ***មិនអាចដកវិញបានទេ*** គឺសំដៅទៅដល់ការមិនអាចដកវិញដោយឯកតោភាគីបានទេ។ ប៉ុន្តែ ប្រសិនបើភាគីទាំងសងខាងបានព្រមព្រៀងគ្នា ឬផ្សះផ្សាគ្នា មិនរំលាយកិច្ចសន្យាវិញ មានន័យថា ពួកគាត់បានធ្វើសម្បទានឱ្យគ្នាទៅវិញទៅមក។ ដូច្នេះ មិនមានបញ្ហាទេ ហើយក៏មិនអាចបកស្រាយយ៉ាងតឹងតែងថា ***មិនអាចដកវិញបាន*** មានន័យថា ទោះបីជាភាគីបានព្រមព្រៀងគ្នាមិនរំលាយកិច្ចសន្យា មិនអាចដកវិញបានទេ ហាក់ដូចជាចង្អៀត និងតឹងតែងពេក។ សរុបមក ការបង្ហាញឆន្ទៈមិនអាចដកវិញបាន គឺសំដៅទៅដល់ ការមិនអាចដកវិញដោយឯកតោភាគី ព្រោះគាត់បង្ហាញឆន្ទៈរំលាយតែម្ខាង ហើយមិនអាចដកវិញតែម្ខាងបានទេ។

## ២.២ ការរលត់សិទ្ធិរំលាយកិច្ចសន្យា

គូភាគីនៃកិច្ចសន្យា មានសិទ្ធិរំលាយកិច្ចសន្យានៅពេលល័ក្ខខ័ណ្ឌដែលជាមូលហេតុខាងលើនៃការរំលាយត្រូវបានបំពេញ។ ប៉ុន្តែ សិទ្ធិរំលាយមិនមែនចេះតែបន្តមានអត្ថិភាពរហូតសូម្បីតែក្នុងស្ថានភាពមិនត្រឹមត្រូវ ឬមិនសមហេតុផលក្នុងការទទួលស្គាល់នោះទេ។ ប្រសិនបើកិច្ចសន្យាត្រូវបានរំលាយភាគីនៃកិច្ចសន្យាមានករណីយកិច្ចធ្វើបដិទាន ដែលត្រូវប្រគល់វិញនូវវត្ថុដែលខ្លួនបានទទួលទៅឱ្យភាគីម្ខាងទៀត។ បញ្ហាចោទឡើងថា សិទ្ធិរំលាយអាចអនុវត្តបានដែរឬទេ នៅពេលភាគីនោះមិនអាចប្រគល់វិញនូវវត្ថុនោះបានដោយសារតែវត្ថុ ដែលត្រូវប្រគល់វិញនោះបានបាត់បង់ ឬទទួលការខូចខាត។ សិទ្ធិរំលាយកិច្ចសន្យារបស់ភាគីត្រូវរលត់ដោយហេតុកំណត់ដោយច្បាប់ ហើយភាគីមិនអាចអះអាងអំពីសិទ្ធិរំលាយបានទេ។

[50] សូមអញ្ជើញមើលគម្រូដូចមានក្នុងឧបសម្ព័ន្ធទី ៣ និង ទី ៥។

ដើម្បីងាយស្រួលក្នុងការសិក្សាអំពីសិទ្ធិរំលាយត្រូវរលត់ ត្រូវសិក្សាអំពីមូលហេតុនៃការ-រំលត់សិទ្ធិរំលាយកិច្ចសន្យា (២.២.១) និងអានុភាពនៃការរលត់សិទ្ធិរំលាយកិច្ចសន្យា(២.២.២)។

### ២.២.១ មូលហេតុនៃការរំលត់សិទ្ធិរលាយកិច្ចសន្យា

សិទ្ធិរំលាយរបស់ភាគីអាចត្រូវបានរលត់ដោយសារសកម្មភាពរបស់ភាគី (២.២.១.១) និងការរលត់ដោយអាជ្ញាយុកាល (២.២.១.២)។

#### ២.២.១.១ ការរលត់សិទ្ធិរំលាយដោយសកម្មភាពរបស់ភាគី

ក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនអាចសងវត្ថុនោះវិញបានដោយចេតនា (ក) ឬធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេងដោយការកែច្នៃ ឬផ្លាស់ទម្រង់ដោយចេតនា(ខ) ដោយសារសកម្មភាពរបស់ភាគីនោះសិទ្ធិរំលាយត្រូវរលត់។

**ក. វត្ថុត្រូវបានខូចខាត ឬបាត់បង់ ឬមិនអាចសងវត្ថុនោះបានដោយចេតនា**

នៅពេលដែលភាគីបានអនុវត្តសិទ្ធិរំលាយ អានុភាពនៃការរំលាយបានធ្វើឱ្យភាគីមានកាតព្វកិច្ចថ្មីមួយទៀតគឺធ្វើបដិទានទៅស្ថានភាពដើម។ សារៈសំខាន់នៃការធ្វើបដិទានទៅស្ថានភាពដើមដោយសារតែអានុភាពនៃការរំលាយកិច្ចសន្យារបស់ភាគីដូច្នេះហើយ ប្រសិនបើកម្មវត្ថុដែលត្រូវបង្វិលទៅម្ចាស់ដើមវិញមិនអាចធ្វើបានទេ នោះសិទ្ធិរំលាយរបស់ភាគីក៏ត្រូវរលត់ដែរ។ សិទ្ធិរំលាយត្រូវរលត់ ក្នុងករណីភាគីដែលមានសិទ្ធិរំលាយបានធ្វើឱ្យមានការខូចខាត ឬការបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យាមិនអាចសងវត្ថុនោះបាន*ដោយចេតនា* ឬធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេងដោយការកែច្នៃ ឬការផ្លាស់ទម្រង់*ដោយចេតនា* [51] របស់ភាគីម្ខាងគឺជាមូលហេតុដែល-ធ្វើឱ្យសិទ្ធិរំលាយភាគីនោះរលត់ផងដែរ។ ការសិក្សាអំពីការរលត់សិទ្ធិរំលាយគឺផ្តោតសំខាន់ទៅលើចេតនារបស់ភាគីនោះថាតើពិតជាមានចេតនាមែនឬទេ ទាំងនេះគឺអាស្រ័យទៅតាមការសិក្សា និងវិនិច្ឆ័យទៅតាមអង្គហេតុនីមួយៗ។

ឧទាហរណ៍ ៖ ក្នុងករណីដែលអ្នកទិញរំលាយកិច្ចសន្យាលក់ទិញរថយន្តដោយមូលហេតុថារថយន្តនោះមានវិការៈ (វិការៈកំបាំង) ហើយអះអាងថា អ្នកលក់មិនអាចផ្តល់តាវកាលិកចម្បងបាន ហើយអ្នកទិញនោះបានធ្វើឱ្យខូចខាតដោយចេតនាដល់រថយន្តដែលខ្លួនត្រូវប្រគល់នោះវិញ តួយ៉ាងដូចជាករណី-ដែលអ្នកទិញបានបើករថយន្តចូលផ្លូវកំពុងស្ទះលូ បណ្តាលឱ្យម៉ាស៊ីនគាំងដំណើរការមិនអាចបើកទៅមុខបានទៀត សិទ្ធិរំលាយកិច្ចសន្យារបស់អ្នកទិញនោះត្រូវរលត់។

---

[51] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧ មាត្រា ៩១២។

ឧទាហរណ៍ ៖ ក្នុងករណីដែលអ្នកទិញបានដុតបំផ្លាញរថយន្តដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬអ្នកទិញបានលក់រថយន្តនោះបន្តទៅឱ្យតតិយជន ហើយបានប្រគល់រថយន្តនោះរួចហើយនោះសិទ្ធិរំលាយរបស់អ្នកទិញក៏ត្រូវរលត់ដែរ។

**ខ.វត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេងដោយការកែច្នៃឬផ្លាស់ទម្រង់ដោយចេតនា**

ប្រសិនកម្មវត្ថុនៃកិច្ចសន្យាដែលត្រូវប្រគល់នោះត្រូវបានកែច្នៃ ឬផ្លាស់ទម្រង់ ***ដោយចេតនា*** របស់ភាគីនោះ សិទ្ធិរំលាយរបស់ភាគីនោះត្រូវរលត់។ ចេតនាក្នុងការកែច្នៃ ឬផ្លាស់ទម្រង់នៃវត្ថុគឺវត្ថុនោះលែងស្ថិតនៅក្នុងស្ថានភាពដើមទៀតហើយ។

ឧទាហរណ៍ ៖ កិច្ចសន្យាលក់ទិញអង្ករ តែអ្នកទិញបានយកអង្ករដែលជាកម្មវត្ថុនៃកិច្ចសន្យាទៅកិនជាម្សៅ និងបានផលិតជានំបុ័ងទៅហើយ។ ដូច្នេះអង្ករដែលជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបានកែច្នៃដោយចេតនារបស់ភាគីបាត់ទៅហើយ។

ឧទាហរណ៍ ៖ កិច្ចសន្យាលក់ទិញកងដៃដែលជាកម្មវត្ថុនៃកិច្ចសន្យាត្រូវបានអ្នកទិញយកទៅកែច្នៃ និងបានផ្លាស់ប្តូរទៅជាចិញ្ចៀនពាក់វិញ នោះសិទ្ធិរំលាយរបស់អ្នកទិញក៏ត្រូវរលត់ដែរ។

ក្នុងករណីដែលភាគីបានអនុវត្តសិទ្ធិរំលាយកិច្ចសន្យា ភាគីនោះត្រូវសងជាប្រាក់នូវតម្លៃនៃ-វត្ថុដែលជាកម្មវត្ថុនោះត្រឹមកម្រិតតម្លៃដែលបានកំណត់ក្នុងកិច្ចសន្យា[52]។

មូលហេតុដែលសិទ្ធិរំលាយកិច្ចសន្យា ត្រូវរលត់នៅក្នុងករណីទាំងពីរខាងនេះគឺដោយសារតែវាផ្ទុយនឹង "គោលការណ៍នៃភាពសុចរិត និងស្មោះត្រង់" ប្រសិនបើភាគីដែលបានធ្វើឱ្យខូចខាត ឬមិនអាចសងវត្ថុនោះវិញដោយចេតនាអាចរំលាយកិច្ចសន្យាបានទៀត។

សិទ្ធិរំលាយកិច្ចសន្យាមិនត្រូវបានរលត់ទេ នៅក្នុងករណីដែលកម្មវត្ថុត្រូវបានធ្វើឱ្យខូចខាត ឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនអាចសងវត្ថុនោះវិញដោយអចេតនា។ នៅក្នុងករណីនេះភាគីដែលមានសិទ្ធិរំលាយកិច្ចសន្យា ត្រូវសងជាប្រាក់នូវតម្លៃនៃកម្មវត្ថុនោះត្រឹមកម្រិតតម្លៃដែលបានកំណត់ក្នុងកិច្ចសន្យា[53]។

ទោះជាយ៉ាងនេះក្តី ក្នុងករណីដែលភាគីម្ខាងទៀតមានកំហុស ឬមានមូលហេតុនៃការខូចខាត ឬការមិនបានសងវត្ថុដែលជាកម្មវត្ថុនោះ ភាគីដែលមានសិទ្ធិរំលាយ គ្មានករណីយកិច្ចក្នុងការសងជាប្រាក់នូវ-តម្លៃនៃវត្ថុនោះដូចករណីខាងលើនេះឡើយ[54]។

---

[52] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧, មាត្រា ៤១២។

[53] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៩២។

[54] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧, មាត្រា ៤១២ ចំណុច ទី ៣។

ឧទាហរណ៍ ៖ ប្រសិនបើករណីខាងលើនេះ អ្នកទិញបានបើករថយន្តចូលផ្លូវកំពុងស្ទះលូ ជាហេតុបណ្តាលឱ្យម៉ាស៊ីនគាំងដំណើរការមិនអាចបើកទៅមុខបានទៀត ដោយសារតែអ្នកលក់បានដកចេញនូវប្រព័ន្ធការពារទឹកក្នុងរថយន្តចេញ ក្រោយមកទើបអ្នកទិញបានដឹង នោះអ្នកទិញគ្មានករណីយកិច្ចសងការខូចខាតដូចខាងលើនោះឡើយ។

### ២.២.១.២ អាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយកិច្ចសន្យា

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យា ដោយមូលហេតុនៃការមិនអនុវត្តន៍កាតព្វកិច្ច និងសិទ្ធិទាមទារឱ្យធ្វើបដិទានមានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ក្រោយពីពេលដែលមិនបានអនុវត្តកាតព្វកិច្ច[55] ។វាមិនដូចគ្នាទៅនឹងការការទាមទារឱ្យសងសំណងការខូចខាតទេ អាជ្ញាយុកាលនៃសិទ្ធិរំលាយគិតចាប់ពីពេលដែលមានការមិនអនុវត្តន៍កាតព្វកិច្ច។ ក្នុងករណីនៃការមិនអនុវត្តន៍កាតព្វកិច្ចសិទ្ធិរំលាយកិច្ចសន្យាមិនត្រូវកើតឡើង ប្រសិនបើម្ចាស់បំណុលមិនបានដាស់តឿន។ ប៉ុន្តែ-ប្រសិនបើការអនុវត្តន៍កាតព្វកិច្ចមានការយឺតយ៉ាវនោះ ម្ចាស់បំណុលអាចបង្កើតសិទ្ធិរំលាយដោយធ្វើការដាស់តឿននៅពេលណាក៏បានដែរ។ ហេតុដូច្នេះ គ្មានបញ្ហាទេចំពោះការចែងថាអាជ្ញាយុកាលនៃ-ការរលត់សិទ្ធិរំលាយកិច្ចសន្យា គិតចាប់ពីពេលនៃការយឺតយ៉ាវក្នុងការអនុវត្តន៍កាតព្វកិច្ច។

ចំពោះសិទ្ធិទាមទារឱ្យធ្វើបដិទានដែលកើតឡើងដោយអនុវត្តសិទ្ធិរំលាយ សិទ្ធិទាមទារឱ្យធ្វើបដិទាននេះនឹងត្រូវរលត់ ប្រសិនបើមិនទាមទារឱ្យធ្វើបដិទានមុនអាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយត្រូវបានសម្រេច[56]។

ឧទាហរណ៍ ៖ នៅក្នុងករណីដែល ក និង ខ បានចុះកិច្ចសន្យាលក់ទិញ ប៉ុន្តែ ខ មិនបានបង់ប្រាក់ថ្លៃទិញ ទោះបីជាមានការប្រគល់របស់ ក ក៏ដោយ ។ ខ ត្រូវស្ថិតនៅក្នុងស្ថានភាពយឺតយ៉ាវ ចាប់ពីពេលដែល ក បានធ្វើការប្រគល់កម្មវត្ថុ។ នៅក្នុងករណីនេះ អាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយ-ត្រូវគិតចាប់ពីពេលដែល ខ ស្ថិតនៅក្នុងភាពយឺតយ៉ាវ។ ដូច្នេះ ក ត្រូវអនុវត្តសិទ្ធិរំលាយកិច្ចសន្យា និងសិទ្ធិទាមទារឱ្យធ្វើបដិទានក្នុងអំឡុងពេល ៥ ឆ្នាំ ចាប់ពីពេលប្រគល់របស់ ក។

### ២.២.២ អានុភាពនៃការរលត់សិទ្ធិរំលាយកិច្ចសន្យារបស់ភាគី

អាជ្ញាយុកាលនៃការរលត់សិទ្ធិរំលាយកិច្ចសន្យាគឺ ៥ ឆ្នាំ គិតចាប់ពីពេលដែលការមិនអនុវត្តន៍កាតព្វកិច្ចបានកើតឡើង។ ម្ចាស់បំណុលអាចធ្វើការទាមទារឱ្យកូនបំណុលធ្វើបដិទានឡើងវិញ ដោយផ្អែកទៅលើសេចក្តីចម្រើនឥតហេតុ ក្រោយពេលដែលម្ចាស់បំណុលបានធ្វើការដាស់តឿន

[55] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧ មាត្រា ៤១៣។

[56] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្ថីទី ៤, (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០១០)មាត្រា ៤១៣។

ដោយកំណត់អំឡុងពេលសមរម្យនិងសម្រេចចិត្តធ្វើការរំលាយកិច្ចសន្យា។ សិទ្ធិទាមទារឱ្យធ្វើបដិទានទៅបានលុះត្រាតែម្ចាស់បំណុលបានធ្វើការរំលាយកិច្ចសន្យាជាមុនសិន ហើយអត្ថិភាពនៃ-សិទ្ធិរំលាយនៅមានសុពលភាពមុនពេលផុតអាជ្ញាយុកាល ៥ ឆ្នាំ។ ប្រសិនបើសិទ្ធិរំលាយកិច្ចសន្យាបានគិតចាប់ពីពេលដែលការមិនអនុវត្តន៍កាតព្វកិច្ចបានកើតឡើង ហើយម្ចាស់បំណុលមិនអើពើជាមួយបញ្ហានេះអស់រយៈពេល ៥ ឆ្នាំ ដូច្នេះសិទ្ធិរំលាយកិច្ចសន្យារបស់ម្ចាស់បំណុលត្រូវរលត់ដោយអាជ្ញាយុកាល។ មិនតែប៉ុណ្ណោះ សិទ្ធិទាមទារឱ្យធ្វើបដិទានក៏ត្រូវរលត់ដែរដោយសារសិទ្ធិរំលាយកិច្ចសន្យាជាសិទ្ធិចម្បងដែលបង្កើតឱ្យមានសិទ្ធិទាមទារឱ្យធ្វើបដិទានបានរលត់។

ឧទាហរណ៍ ៖ លោក ក បានទិញកៅអីសាឡុងចំនួន ៥ ឈុតនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៤ ពីលោក ខ ជាអ្នកលក់ និងបានប្រគល់ប្រាក់កក់ពាក់កណ្តាលនៃតម្លៃសរុបដោយសន្យាថានឹងប្រគល់ប្រាក់ឱ្យគ្រប់នៅពេល លោក ខ ប្រគល់កៅអីសាឡុងគ្រប់ដែរត្រឹមថ្ងៃទី ៣០ ខែ មករា ឆ្នាំ-២០១៤។ ប៉ុន្តែអ្នកលក់មិនបានប្រគល់កៅអីសាឡុងតាមពេលកំណត់ឡើយ។ លោក ក ក្រោយពីបានដឹងរឿងនេះក៏មិនខ្វល់ខ្វាយដែរដោយបណ្តែតបណ្តោយរហូតដល់ឆ្នាំ ២០១៩ ទើបមានការចង់ប្តឹងលោក ខ ឱ្យប្រគល់ប្រាក់កក់ស្មើនឹងពាក់កណ្តាលត្រលប់មកវិញ និងទាមទាររំលាយកិច្ចសន្យា។ ប៉ុន្តែសិទ្ធិរំលាយរបស់លោក ក ត្រូវបានរលត់ដោយសារអាជ្ញាយុកាលបាត់ទៅហើយ ម្យ៉ាងទៀតសិទ្ធិទាមទារឱ្យធ្វើបដិទានក៏ត្រូវរលត់ទៅតាមសិទ្ធិរំលាយកិច្ចសន្យាដែរ។

# ជំពូកទី ៣

# អានុភាពនៃការរំលាយ

# កិច្ចសន្យា

# ជំពូកទី ៣
# អានុភាពនៃការរំលាយកិច្ចសន្យា

ក្រោយពេលភាគីបង្ហាញឆន្ទៈរំលាយកិច្ចសន្យា នោះកិច្ចសន្យាត្រូវបញ្ចប់នូវអានុភាព មានន័យថា កាតព្វកិច្ចដែលមិនទាន់អនុវត្តត្រូវរលត់ ហើយគ្មានភាពចាំបាច់ត្រូវអនុវត្ត[57]។ ប្រសិនបើកិច្ចសន្យាមួយត្រូវបានរំលាយ ចំណងកិច្ចសន្យានេះនឹងត្រូវរលត់។ ការរំលាយកិច្ចសន្យានឹងរលត់នូវរាល់-កាតព្វកិច្ចទាំងឡាយរបស់ភាគីដែលកើតឡើងដោយកិច្ចសន្យា និងនាំឱ្យភាគីរួចផុតពីកិច្ចសន្យានោះ។ ប៉ុន្តែ ក្នុងករណីរំលាយកិច្ចសន្យា ដោយមូលហេតុមកពីការមិនអនុវត្តន៍កាតព្វកិច្ច នោះករណីយកិច្ចសងសំណងការខូចខាតរបស់កូនបំណុលដែលមិនអនុវត្តកាតព្វកិច្ចនៅតែមានអានុភាព[58]។

គេបានធ្វើការចាត់ថ្នាក់កិច្ចសន្យាដែលមានទំនាក់ទំនងជាមួយនឹងអានុភាពប្រតិសកម្មជាពីរចំណាត់ថ្នាក់គឺ កិច្ចសន្យាអនុវត្តម្តងចប់ និងកិច្ចសន្យាដែលអនុវត្តបន្តបន្ទាប់ ។ ដោយអានុភាពនៃ-ការរំលាយកិច្ចសន្យាអនុវត្តម្តងចប់តម្រូវឱ្យមានអានុភាពប្រតិសកម្ម រីឯអានុភាពនៃកិច្ចសន្យាអនុវត្តបន្តបន្ទាប់ មិនមានអានុភាពប្រតិសកម្មជាចាំបាច់នោះទេ ។ នេះក៏ព្រោះតែការអនុវត្តន៍កាតព្វកិច្ចជាបន្តបន្ទាប់វាធ្វើឱ្យភាគីណាម្ខាង ខាតបង់ច្រើនបើសិនជាតម្រូវឱ្យមានការបដិទានឡើងវិញ ។

ឧទាហរណ៍ទី១ ៖ កិច្ចសន្យាម៉ៅការ ដែលម្ចាស់ការបាន ជួលអ្នកម៉ៅការឱ្យសង់ផ្ទះឱ្យខ្លួនពេលសង់បានពាក់កណ្តាល អ្នកម៉ៅការក៏បានបង្កកំហុសដែលនាំឱ្យម្ចាស់ការមានសិទ្ធិក្នុងការរំលាយកិច្ច-សន្យា។ នៅក្នុងករណីនេះ យើងឃើញថាផ្ទះសង់បានពាក់កណ្តាលហើយបើសិនជាច្បាប់អនុញ្ញាតឱ្យអានុភាពនៃការរំលាយកិច្ចសន្យាធ្វើឱ្យមានអានុភាពប្រតិសកម្មនោះ នឹងនាំឱ្យអ្នកម៉ៅការត្រូវរុះរើផ្ទះនោះចេញ ហើយអ្នកម៉ៅការថែមទាំងត្រូវសងនូវសោហ៊ុយ និងកម្រៃដែលខ្លួនបានទទួលទៀតផង។ ដូច្នេះយើងឃើញថាវាធ្វើឱ្យអ្នកម៉ៅការមានការប៉ះពាល់ផលប្រយោជន៍ច្រើន ដោយសារអានុភាពប្រតិសកម្មនេះ។

ឧទាហរណ៍ទី២ ៖ កិច្ចសន្យាជួលដែល ភតិបតី បានជួលផ្ទះឱ្យ ភតិកៈ កំណត់៥ឆ្នាំ ប៉ុន្តែភតិកៈនៅបានតែ១ឆ្នាំក៏ឈប់បង់ប្រាក់ទៅឱ្យភតិបតីទៀត ដែលជាហេតុធ្វើឱ្យភតិបតីរំលាយកិច្ចសន្យាចោល ។ នៅក្នុងករណីនេះ បើសិនជាអនុញ្ញាតនាំឱ្យមានអានុភាពប្រតិសកម្មនោះនាំឱ្យភតិបតីត្រូវសងនូវប្រាក់ឈ្នួលផ្ទះដែលខ្លួនទទួលបានទៅឱ្យភតិកៈវិញ ព្រោះវាគ្មានកិច្ចសន្យាតាំងពីដំបូង រីឯភតិបតីវិញ

---

[57] សាស្ត្រាចារ្យ UMEMOTO YUMI , ការរំលាយកិច្ចសន្យា, (ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវទូទៅអំពីកិច្ចការច្បាប់, នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ) ទំព័រទី ៣៨។

[58] ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់-មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្លឹះទី ៤, (ភ្នំពេញ៖ក្រសួងយុត្តិធម៌, ២០១០), មាត្រា ៤០៩, ទំព័រ ១២៨។

មានសិទ្ធិត្រឹមតែទាមទារឱ្យបដិទានផ្ទះឱ្យដូចដើមវិញ និងទាមទារសំណងការខូចខាតដោយការបំពានកិច្ចសន្យាប៉ុណ្ណោះ។

តើការរំលាយកិច្ចសន្យានាំឱ្យមានអានុភាពយ៉ាងដូចម្ដេច? ហើយតើការរំលាយកិច្ចសន្យាមានអានុភាពចំពោះភាគី និងតតិយជនយ៉ាងដូចម្ដេច?

ដើម្បីសិក្សាឱ្យបានស៊ីជម្រៅអំពីអានុភាពនៃការរំលាយកិច្ចសន្យា ត្រូវសិក្សាវិបាកទាក់ទងទៅនឹងការរំលាយកិច្ចសន្យា (៣.១) អានុភាពចំពោះភាគី (៣.២) និងអានុភាពចំពោះតតិយជន(៣.៣)។

## ៣.១ វិបាកទាក់ទងទៅនឹងអានុភាពនៃការរំលាយកិច្ចសន្យា

នៅពេលដែលអានុភាពកើតចេញពីការរំលាយកិច្ចសន្យា នោះនឹងឱ្យមានលក្ខណៈថ្មីមួយទៀតនៃអានុភាព នោះគឺភាពប្រតិសកម្ម (៣.១.១) និងភាពមិនប្រតិសកម្ម (៣.១.២) ដែលគំនិតទាំង ២ នេះត្រូវទទួលស្គាល់ដោយផ្អែកទៅលើចំណាត់ថ្នាក់នៃកិច្ចសន្យា។

### ៣.១.១ អានុភាពប្រតិសកម្ម

យោងតាមគំនិតនេះ នៅពេលកិច្ចសន្យាត្រូវបានរំលាយ ត្រូវបានចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង ដូច្នេះតាវកាលិកដែលភាគីម្ខាងបានទទួលត្រូវប្រគល់ទៅឱ្យភាគីម្ខាងទៀតវិញដោយផ្អែកលើសេចក្ដីចម្រើនឥតហេតុ[59]។

ឧទាហរណ៍ ៖ ក្នុងកិច្ចសន្យា ក បានទិញឡានពី ខ ដោយបានព្រមព្រៀងគ្នាថា ក ត្រូវបង់លុយថ្លៃឡាននៅថ្ងៃធ្វើកិច្ចសន្យា រីឯ ខ ត្រូវអនុវត្តកាតព្វកិច្ចនៅថ្ងៃដែលបានកំណត់មួយ ។ លុះដល់ថ្ងៃកំណត់ ខ មិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនឡើយ ដែលធ្វើឱ្យ ក បានសម្រេចចិត្តរំលាយកិច្ចសន្យា។ ដូច្នេះ នៅពេលដែលកិច្ចសន្យាត្រូវបានរំលាយអានុភាពដែលកើតឡើងមានអានុភាពប្រតិសកម្មនាំឱ្យស្មើនឹងគ្មានកិច្ចសន្យាតាំងពីដំបូង ដូចនេះលុយដែល ខ ទទួលបាននឹងក្លាយទៅជាសេចក្ដីចម្រើនឥតហេតុដែលអាចឱ្យ ក អាចប្ដឹងទាមទារយកមកវិញបានដោយផ្អែកលើសិទ្ធិតាមច្បាប់សារធាតុ ។

### ៣.១.២ អានុភាពមិនប្រតិសកម្ម

ផ្អែកតាមគំនិតនេះ ការរំលាយកិច្ចសន្យាត្រូវបានចាត់ទុកថាគ្មានអានុភាពប្រតិសកម្ម។ ដូច្នេះ សិទ្ធិលើបំណុល និង កាតព្វកិច្ចដើមត្រូវផ្លាស់ប្ដូរទៅជាសិទ្ធទាមទារ និងកាតព្វកិច្ចធ្វើបដិទាន

[59] ក្រុមការងារនៃអនាគតគ្រូបណ្ដុះបណ្ដាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្ដីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៨៥។

ទៅស្ថានភាពដើមរបស់គូភាគី[60]។ នេះគឺព្រោះតែមាត្រា ៥១១កថាខណ្ឌទី២ បានចែងបញ្ជាក់ច្បាស់ពីចំណុចបដិទាននូវតាវកាលិកដែលភាគីបានទទួល។

ឧទាហរណ៍ ៖ ក្នុងកិច្ចសន្យាលក់ទិញ គ បានទិញទូរស័ព្ទមួយគ្រឿងពី ឃ ។ ឃ បានប្រគល់ទូរស័ព្ទឱ្យ គ រួចហើយ ប៉ុន្តែ គ មិនបានបង់ប្រាក់ឱ្យ ឃ ទេ ។ ដែលជាហេតុធ្វើឱ្យ ឃ រំលាយកិច្ចសន្យា ។ ដោយផ្អែកលើអានុភាពមិនប្រតិសកម្មកិច្ចសន្យា មានអានុភាពរហូតដល់មានការរំលាយកិច្ចសន្យា ។ រីឯតាវកាលិកដែលភាគីបានទទួលបានត្រូវតែបង្វិលឱ្យភាគី ឃ វិញ។ ការផ្ទេរទូរស័ព្ទទៅវិញនេះខុសពីករណីនៃអានុភាពប្រតិសកម្ម ព្រោះការសងតាវកាលិកត្រឡប់ទៅវិញនេះគឺជាកាតព្វកិច្ចថ្មី មិនមែនផ្អែកលើសេចក្តីចម្រើនឥតហេតុដូចករណីដែលផ្អែកលើទ្រឹស្តីអានុភាពប្រតិសកម្មនោះទេ។

សរុបមក លក្ខណៈនៃអានុភាពនៃការរំលាយកិច្ចសន្យាទាំង ២ ខាងលើ សុទ្ធតែចងកាតព្វកិច្ចដល់ភាគីត្រូវតែប្រគល់តាវកាលិកត្រលប់ទៅវិញទាំងអស់ឱ្យទៅម្ចាស់ដើមវិញ ហើយក៏មិនមានគំនិតណាមួយប្រឆាំងនឹងការប្រគល់ត្រលប់ទៅវិញដែរ លើកលែងតែប្រភេទកិច្ចសន្យានោះមិនអាចប្រគល់ត្រលប់បានដូចការបកស្រាយខាងលើ។

បន្ទាប់ពីបានសិក្សាខ្លឹមសារនៃអានុភាពដែលកើតឡើងចេញពីការរំលាយកិច្ចសន្យាខាងលើរួចមក យើងនឹងសិក្សាអានុភាពចំពោះគូភាគីវិញម្តង។

## ៣.២ អានុភាពចំពោះភាគី

ភាគីនៃកិច្ចសន្យានឹងទទួលអានុភាពពីការរំលាយដូចជា ការរលត់នូវករណីយកិច្ចនៃកិច្ចសន្យា (៣.២.១) លើកលែងតែការរួចផុតពីសំណងនៃការខូចខាត (៣.២.២)។

### ៣.២.១ ការរលត់នូវករណីយកិច្ចនៃកិច្ចសន្យា

ការរំលាយកិច្ចសន្យានាំឱ្យគូភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យា លើកលែងតែករណីកិច្ចសងការខូចខាត។ បន្ទាប់ពីមានការរំលាយកិច្ចសន្យាបានន័យថា ភាគីគ្មានកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមកទៀតទេ។ យើងដឹងហើយថាភាគីមានកាតព្វកិច្ចឱ្យគ្នាទៅវិញទៅមកគឺដោយសារអានុភាពចងនៃកិច្ចសន្យា ដូច្នេះបើសិនជាគ្មានកិច្ចសន្យាផងតើមានមូលហេតុគតិយុត្តអ្វីដែលត្រូវឱ្យមានការអនុវត្តន៍នូវកាតព្វកិច្ចនោះ ដូចជាករណីដែល អ្នកទិញមិនចាំបាច់បង់ប្រាក់ឡើយ រីឯអ្នកលក់មិនចាំបាច់ប្រគល់នំខេកឡើយ ក្នុងករណីដែលអ្នកលក់មិនប្រគល់វត្ថុតាមពេលកំណត់ក្នុងថ្ងៃអាពាហ៍ពិពាហ៍ហើយក្រោយមកអ្នកទិញសម្រេចចិត្តរំលាយកិច្ចសន្យាចោល។ សិក្សាដល់ចំណុចនេះនាំឱ្យសិក្សាអំពីការធ្វើបដិទាននៃការផ្ទេរកម្មសិទ្ធិ (៣.២.១.១) និង ការធ្វើបដិទានទៅស្ថានភាពដើម ( ៣.២.១.២)។

[60]ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទថៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៨៥។

### ៣.២.១.១ ការធ្វើបដិទាននៃការផ្ទេរកម្មសិទ្ធ

ក្នុងគំនិតដែលទទួលស្គាល់អានុភាពនៃប្រតិសកម្ម អ្នកដែលទទួលបានការផ្ទេរកម្មសិទ្ធិគឺចាត់ទុកថាមិនដែលទទួលបានការលទ្ធកម្មកម្មសិទ្ធតាំងពីដំបូង។ ដូច្នេះអនុប្បទាយីអាចទាមទារឱ្យអនុប្បទានិកផ្ទេរកម្មសិទ្ធិមកវិញបានដោយផ្អែកលើកម្មសិទ្ធិ។ ផ្ទុយទៅវិញ គំនិតដែលមិនទទួលស្គាល់អានុភាពប្រតិសកម្មគឺកម្មសិទ្ធិត្រូវបានផ្ទេរ ហើយកាតព្វកិច្ចក្នុងការប្រគល់កម្មសិទ្ធិត្រលប់មកវិញគឺជាកាតព្វកិច្ចមួយថ្មី។ ទន្ទឹមនឹងនេះកាតព្វកិច្ចត្រូវផ្ទេរមកវិញដោយស្វ័យប្រវត្តិ[61]។

### ៣.២.១.២ ការធ្វើបដិទានទៅស្ថានភាពដើម

ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យាតែមួយភាគ ឬទាំងអស់ ត្រូវមានករណីយកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីនោះទទួលបដិទានឡើងវិញដោយសារការរំលាយ។ ក្នុងករណីដែលភាគីទាំងសងខាងមានករណីយកិច្ចធ្វើបដិទានទៅវិញទៅមក ករណីយកិច្ចទាំងនោះត្រូវអនុវត្តនៅពេលជាមួយគ្នា។

ភាគីដែលមានករណីយកិច្ចសងជាប្រាក់ដោយការរំលាយកិច្ចសន្យា ត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ។ ភាគីដែលមានករណីយកិច្ចបង្វិលជា-វត្ថុ ឬជាតាវកាលិកផ្សេងដែលខ្លួនបានទទួលទៅភាគីម្ខាងទៀត ដោយសារការរំលាយត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬតាវកាលិកនោះផងដែរ[62]។

ការធ្វើបដិទានមានលក្ខណៈសំខាន់ដែលយើងត្រូវសិក្សាអំពីខ្លឹមសារនៃកាតព្វកិច្ចធ្វើបដិទាន (ក) លក្ខណៈនៃការធ្វើបដិទាន (ខ) និងករណីដែលមិនអាចសងកម្មវត្ថុត្រលប់ទៅវិញ (គ)។

#### ក. ខ្លឹមសារនៃកាតព្វកិច្ចធ្វើបដិទាន

ក្រមរដ្ឋប្បវេណីបានបញ្ញត្តថា ភាគីដែលទទួលតាវកាលិក ត្រូវសងតាវកាលិកនោះទៅឱ្យភាគីម្ខាងទៀតមិនត្រឹមតែអ្វីដែលគាត់បានទទួលនោះទេគឺថែមទាំងត្រូវសងការប្រាក់ ឬផលប្រយោជន៍ដែលកើតមានឡើងពីសិទ្ធលើបំណុលជាប្រាក់ ឬ កម្មវត្ថុនោះទៀតផង។ ក្នុងន័យនេះកាតព្វកិច្ចធ្វើបដិទានមានន័យថា មិនត្រឹមតែជាការធ្វើបដិទានទៅស្ថានភាពពេលបង្កើតកិច្ចសន្យាទេ ប៉ុន្តែទៅដល់ស្ថានភាពដែលអាចមាន។ នេះក៏ព្រោះតែក្រមរដ្ឋប្បវេណីកម្ពុជាបានគិតគូទៅដល់កាលៈទេសៈដែល-ភាគីមិនបានបង្កើតកិច្ចសន្យាទេនោះ តើនឹងមានផលប្រយោជន៍អ្វីខ្លះកើតឡើង?

---

[61]ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៨៦ ។

[62] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,៨ ធ្នូ ២០០៧ មាត្រា ៤១១ ចំណុចទី ២ និងទី ៣។

ឧទាហរណ៍ ៖ លោក ខេម បានទិញគោញី(ដើម)ពីលោកស្រី សុជាតា ដោយកាតព្វកិច្ចមិនអនុវត្តព្រមគ្នាទេ គឺលោក ខេម គាត់យកគោទៅផ្ទះមើលសិន ទើបគាត់បង់ប្រាក់តាមក្រោយ។ លុះពីរ បីថ្ងៃក្រោយមកលោកស្រី សុជាតា បានទៅដាស់តឿនឱ្យលោក ខេម អនុវត្តកាតព្វកិច្ច តែលោក ខេម គេចវេស ។ ហេតុផលនេះហើយដែលធ្វើឱ្យលោកស្រី សុជាតា សម្រេចចិត្តរំលាយកិច្ចសន្យាចោល ហើយទាមទារឱ្យលោកខេម ប្រគល់គោមកវិញ។ លោកខេម គាត់យល់ព្រមប្រគល់គោនោះមកវិញ ប៉ុន្តែគោញីនោះបានកើតកូនហើយគាត់ទាមទារកូនគោថាជារបស់គាត់ដោយហេតុថា កូនគោនោះកើតនៅពេលដែលស្ថិតនៅក្រោមការកាន់កាប់របស់គាត់។ នៅក្នុងករណីនេះលោកស្រីសុជាតា មានសិទ្ធិទាមទារកូនគោនោះមកវិញផងដែរ ដោយហេតុថាកូនគោនោះគឺជាផលដែល-កើតចេញពីកម្មវត្ថុនៃកិច្ចសន្យា ដូច្នេះវាមិនត្រឹមត្រូវទេដែលអោយបុគ្គលដែលបានបំពានកិច្ចសន្យាធ្វើឱ្យខូចផលប្រយោជន៍របស់ភាគីម្ខាងទៀតមានសិទ្ធិទទួលបានផលពីកម្មវត្ថុនៃកិច្ចសន្យា។

### ខ. លក្ខណៈនៃកាតព្វកិច្ចធ្វើបដិទាន

**គោលគំនិតប្រតិសកម្ម** កាតព្វកិច្ចដែលត្រូវធ្វើបដិទានត្រឡប់មកវិញនូវវត្ថុ ដែលបានប្រគល់តាមកិច្ចសន្យា បន្ទាប់ពីមានការរំលាយកិច្ចសន្យា គឺជាករណីពិសេសនៃសេចក្តីចម្រើនឥតហេតុ។ ជាទូទៅ ប្រសិនបើកិច្ចសន្យាត្រូវបានរំលាយនោះ ត្រូវចាត់ទុកថាគ្មានកិច្ចសន្យាតាំងពីដំបូង ដូច្នេះទំហំនៃកាតព្វកិច្ចក្នុងការប្រគល់ ត្រូវបានកម្រិតត្រឹមផលប្រយោជន៍ដែលមាន ដោយផ្អែកលើមាត្រា ៧៣៦ កថាខណ្ឌទី២ ។ ក៏ប៉ុន្តែ មាត្រា ៥១១ កថាខណ្ឌទី២ បានពង្រីកទំហំនៃកាតព្វកិច្ចធ្វើបដិទាននេះទៅតាមស្ថានភាពដើមរបស់ភាគីដូចដែលមានរៀបរាប់។

**គោលគំនិតមិនប្រតិសកម្ម** កាតព្វកិច្ចដែលត្រូវធ្វើបដិទានត្រឡប់វិញនូវវត្ថុ ដែលបានប្រគល់តាមកិច្ចសន្យាបន្ទាប់ពីមានការរំលាយកិច្ចសន្យាគឺជាកាតព្វកិច្ចថ្មី ដោយផ្អែកលើការរំលាយកិច្ច-សន្យា ចំណែកឯកាតព្វកិច្ចដែលបានអនុវត្តរួចហើយ គឺមានសុពលភាពព្រោះថាការរំលាយកិច្ច-សន្យា មានឥទ្ធិពលឆ្ពោះទៅអនាគតតែប៉ុណ្ណោះ[63]។

### គ.ករណីដែលភាគីនៃកិច្ចសន្យាមិនអាចសងត្រឡប់ទៅវិញនូវវត្ថុ

សិទ្ធិរំលាយកិច្ចសន្យាត្រូវរលត់ក្នុងករណីដែលភាគីមានសិទ្ធិរំលាយៈ

**ក.** បានធ្វើឱ្យមានការខូចខាត ឬបាត់បង់ដល់វត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬ មិនអាចសងវត្ថុនោះវិញដោយចេតនា ។

**ខ.** ធ្វើឱ្យវត្ថុនោះ ក្លាយជាវត្ថុផ្សេងដោយសារការកែច្នៃ ឬ ការផ្លាស់ប្តូរទម្រង់។

[63] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៨៥។

ឬនិយាយម្យ៉ាងទៀត នៅក្នុងករណីដែលកម្មវត្ថុត្រូវបានធ្វើឱ្យខូចខាត ឬ បាត់បង់ ឬ មិនអាចសងត្រឡប់មកវិញបាន ដោយអចេតនា នោះសិទ្ធិរំលាយមិនត្រូវរលត់ទេ មានន័យថាអ្នកមានសិទ្ធិ-រំលាយនៅតែមានសិទ្ធិរំលាយ ប៉ុន្តែត្រូវសងជាប្រាក់នូវតម្លៃដែលជាកម្មវត្ថុនោះ ត្រឹមកម្រិតតម្លៃដែលបានកំណត់នៅក្នុងកិច្ចសន្យា យោងតាមមាត្រា៤១២ កថាខណ្ឌទី២។

### ៣.២.២ ករណីយកិច្ចសងសំណងការខូចខាត

សំណងការខូចខាត ជាវិធីមួយសម្រាប់សង្គ្រោះក្នុងករណីដែលមានការមិនអនុវត្តន៍កាតព្វកិច្ច ឬកាតព្វកិច្ចត្រូវបានបំពានផងដែរ ។ ថ្វីត្បិតតែភាគីបានជ្រើសរើសយកវិធីរំលាយកិច្ចសន្យាដើម្បីការពារប្រយោជន៍ខ្លួនក៏ពិតមែន ក៏មិនមានន័យថាគាត់មិនអាចទាមទារសំណងការខូចខាតបាននោះដែរ។ នៅក្នុងវិធីនៃការសង្គ្រោះកិច្ចសន្យា ភាគីអាចប្រើវិធីសង្គ្រោះមួយ ឬ ច្រើនឱ្យតែវិធីសង្គ្រោះមិនមានលក្ខណៈផ្ទុយគ្នា ឧទាហរណ៍ដូចជា ភាគីអនុវត្តការសង្គ្រោះតាមរយៈការរំលាយកិច្ចសន្យាហើយ បន្ទាប់មកភាគីចង់អនុវត្តដោយបង្ខំទៀត ដូច្នេះវាមិនសមហេតុផលទេដែលភាគីបានរំលាយកិច្ចសន្យាហើយ(កាតព្វកិច្ចរលត់ហើយ) ភាគីចង់អនុវត្តដោយបង្ខំទៀត ព្រោះថាភាគីទាំងសងខាងអស់កាតព្វកិច្ចដែលត្រូវឱ្យអនុវត្តដោយបង្ខំហើយ ។ លើសពីនេះទៀតមាត្រា ៤១១ កថាខណ្ឌទី១ ក៏បានបញ្ជាក់ដែរថាគូភាគីមិនអាចរួចផុតពីករណីយកិច្ចសងការខូចខាតទេ ទោះបីជាភាគីរួចផុតពីករណីយកិច្ចក្នុងកិច្ចសន្យាក៏ដោយ។

ផលប្រយោជន៍ដែលត្រូវសងមាន២គឺ (១) ផលប្រយោជន៍ពីការរំពឹងទុក និង (២) ផលប្រយោជន៍ពីការជឿទុកចិត្ត ។

**១. ផលប្រយោជន៍ពីការរំពឹងទុក** សម្តៅទៅលើផលប្រយោជន៍ដែលអាចនឹងទទួលបានប្រសិនកិច្ចសន្យាត្រូវបានអនុវត្តដូចការសន្យា ។

**២. ផលប្រយោជន៍ពីការជឿទុកចិត្ត** គឺសម្តៅទៅលើ ការចំណាយរបស់ភាគីដែលបានជឿជាក់ថាកិច្ចសន្យា មិនត្រូវបានរំលាយនោះទេ ។ ក្នុងករណីនេះ ភាគីដែលទទួលរងនូវការខូចខាតដោយសារការរំលាយកិច្ចសន្យា អាចទាមទារសំណងនៃការខូចខាតដែលនឹងមិនត្រូវបានចំណាយប្រសិនបើគាត់បានដឹងការណ៍ថា កិច្ចសន្យានឹងត្រូវរំលាយ ។

ក្រោយពីបានសិក្សាអានុភាពចំពោះភាគីរួចមកការពារតតិយជនពីអានុភាពនៃការរំលាយកិច្ចសន្យាគឺពិតជាមានសំខាន់ខ្លាំងណាស់ចំពោះតតិយជនដែលត្រឹមត្រូវ។

## ៣.៣ អានុភាពចំពោះតតិយជន

ការរំលាយកិច្ចសន្យា មិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ។ នេះគឺជាគោលបំណងក្នុងការការពារស្ថិរភាពជំនួញរបស់តតិយជន ដែលត្រឹមត្រូវមិនឱ្យស្ថិតក្នុង

ស្ថានភាពមួយដែលមាននូវការព្រួយបារម្ភ។ មិនមែនគ្រប់តតិយជនសុទ្ធតែត្រូវបានការពារទាំងអស់នោះទេ លុះត្រាតែតតិយជននោះមានភាពត្រឹមត្រូវតាមច្បាប់[64]។

ឧទាហរណ៍ ៖ ថ្ងៃទី ០១.០៤.២០១៩ X បានលក់ដី L ឱ្យទៅ Y និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិ។ ថ្ងៃទី ០១.០៥.២០១៩ Y បានលក់ដី L ឱ្យទៅ Z និងបានចុះបញ្ជីផ្ទេរកម្មសិទ្ធិ។ ទោះបីជា X បានដាស់តឿនក៏ Y នៅតែមិនបង់ថ្លៃលក់ទិញដីបង្គ្រប់។ ថ្ងៃទី ០១.០៦.២០១៩ X បានរំលាយកិច្ចសន្យា។

ប្រសិនបើជាការទិញលក់ដី L ពី X ទៅ Y ក្លាយជានត្ថិភាពដោយសារការរំលាយ នោះផលប្រយោជន៍របស់ Z ដែលបានទិញដី ដោយការជឿជាក់លើការចុះបញ្ជីរបស់ Y នឹងត្រូវខូចខាតយ៉ាងខ្លាំង ហើយសុវត្ថិភាពជំនួញក៏មានការខូចខាតផងដែរ។ ការរំលាយមិនអាចធ្វើឱ្យខូចខាតប្រយោជន៍ត្រឹមត្រូវរបស់ Z បានឡើយ។ ***អានុភាពនៃការរំលាយមិនមានចំពោះ Z ទេ។ Z អាចតតាំងអំពីលទ្ធកម្មនៃកម្មសិទ្ធិលើដី L ចំពោះ X បាន។***

ផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនជាអ្វី? ដោយសារតែការបកស្រាយនេះមិនមានកំណត់ក្នុងច្បាប់ ហេតុនេះត្រូវពឹងផ្អែកទៅយុត្តិសាស្ត្ររបស់តុលាការ។ តើករណីណាខ្លះដែលយើងអាចនិយាយថា Z មានផលប្រយោជន៍ត្រឹមត្រូវ?

→ ករណីដែល Z មិនទាន់បានចុះបញ្ជីដី L រួចរាល់?

→ ករណីដែល L បានដឹងថា Y មិនមានលទ្ធភាពបង់ប្រាក់ថ្លៃទិញបាន?

→ ករណីដែល Y បានប្រាប់ថា Z ថា ចង់លក់ដីនេះ មុនពេលដែល X រំលាយកិច្ចសន្យា[65]?

តើត្រូវការពារតតិយជន យ៉ាងដូចម្ដេចនោះគឺអាស្រ័យទៅលើថា តើអានុភាពប្រតិសកម្ម ត្រូវបានទទួលស្គាល់ ឬមិនទទួលស្គាល់ ។

ឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តខាងលើ ភាពប្រតិសកម្មត្រូវយកមកសិក្សាដើម្បីការពារតតិយជនក្នុងគោលការណ៍ប្រតិសកម្ម (៣.៣.១) និងតតិយជនក្នុងគោលការណ៍មិនប្រតិសកម្ម (៣.៣.២)។

### ៣.៣.១ តតិយជនក្នុងគោលការណ៍ប្រតិសកម្ម

ចំពោះតតិយជនមុនការរំលាយកិច្ចសន្យាវិញ គេអាចចាត់ទុកថា តតិយជនត្រូវទទួលបានការកាន់កាប់ ឬចុះបញ្ជី ដើម្បីទទួលបាននូវការការពារតាមមាត្រា ៤១១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណីកម្ពុជា ព្រោះតតិយជនត្រូវបានគេចាត់ទុកថាបានខិតខំប្រឹងប្រែងជាអតិបរមាដើម្បីការពារសិទ្ធិរបស់

---

[64] ប្រសាសន៍របស់លោកស្រីមេធាវី ទេព បូផល, កិច្ចពិភាក្សាស្ដីពីការរំលាយកិច្ចសន្យា, រៀបចំដោយ៖ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩)។

[65]មេធាវី ទេព បូផល និងលោក សេង នាង, កិច្ចពិភាក្សាស្ដីពីការរំលាយកិច្ចសន្យា, រៀបចំដោយ៖ វិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCC ០៩ មិថុនា ២០១៩), ទំព័រទី ៦៤។

ខ្លួន។ ដោយផ្អែកលើគំនិតនេះ ការកាន់កាប់ ឬ ការចុះបញ្ជីមានតួនាទីជា "ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃសិទ្ធរក្សាការពារ"។ ផ្ទុយទៅវិញគេអាចគិតថា លក្ខខណ្ឌតតាំងមិនមានលក្ខណៈចាំបាច់សម្រាប់តតិយជនក្នុងការទទួលបានការការពារទេ ព្រោះមាត្រា៤១១កថាខណ្ឌទី៤ មិនបានតម្រូវឱ្យមានល័ក្ខខ័ណ្ឌតតាំងសម្រាប់តតិយជនទេ។

ដោយផ្អែកលើភាពប្រតិសកម្មតតិយជនដែលបានចុះកិច្ចសន្យានៅក្រោយការរំលាយកិច្ចសន្យា មិនអាចទទួលបាននូវការការពារតាមមាត្រា ៤១១ កថាខណ្ឌទី៤ ទេ ព្រោះអានុភាពប្រតិសកម្មបានកើតឡើងរួចហើយ។ តតិយជននៅក្រោយការរំលាយកិច្ចសន្យា ត្រូវបានចាត់ទុកថា បានទទួល កម្មសិទ្ធិពីជនដែលមិនមានកម្មសិទ្ធិ។ ដូច្នេះ តតិយជនមិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិទេ។ ជាការពិត នៅក្នុងករណី-ដែលកម្មសិទ្ធិ គឺជាចលនវត្ថុ អនុប្បទានិកអាចធ្វើលទ្ធកម្មលើកម្មសិទ្ធិបាន បើសិនជាអនុប្បទានិកជាជនសុចរិត និងគ្មានកំហុស ដោយបំពេញលក្ខខណ្ឌដែលមានចែងនៅក្នុងមាត្រា ១៩៣ នៃក្រមរដ្ឋប្បវេណីកម្ពុជា។ ក៏ប៉ុន្តែ នៅក្នុងករណីកម្មវត្ថុ គឺជាអចលនវត្ថុតតិយជនមិនអាចទទួលបានកម្មសិទ្ធិ តាមរយៈលទ្ធកម្មដោយសុចរិតនោះទេ។ ជាលទ្ធផលគឺមានគំនិតមួយ ដែលការពារតតិយជនប្រភេទនេះតាមរយៈការអនុវត្តន៍ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងមាត្រា ៣៥៣ កថាខណ្ឌទី២។ ព្រោះគេអាចនិយាយបានថា ក បានបន្សល់ទុកនូវការចុះបញ្ជី ហើយបានបង្កើតនូវទិដ្ឋភាពមួយដែលបង្ហាញថា ខ គឺជាកម្មសិទ្ធិករលើអចលនវត្ថុនោះ ហើយ គ បានជឿជាក់ថា ខ គឺជាម្ចាស់សិទ្ធិពិតប្រាកដមែន។

មូលហេតុដែលក្រមរដ្ឋប្បវេណីធ្វើការការពារតតិយជនដែលសុចរិត និងគ្មានកំហុសធ្ងន់ធ្ងរ ព្រោះជនដែលបង្កើតនូវទិដ្ឋភាពមិនពិត មិនមានសិទ្ធិក្នុងការអះអាងនូវមោឃភាពនៃកិច្ចសន្យាចំពោះតតិយជនដែលបានជឿជាក់ទៅលើទិដ្ឋភាពនោះ ដោយមានហេតុផលឡើយ ។ គោលការណ៍នេះទាញចេញពី "លទ្ធិដែលមានលក្ខណៈជារូបភាព" [66]។

### ៣.៣.២ តតិយជនក្នុងគោលការណ៍មិនប្រតិសកម្ម

ដោយផ្អែកលើភាពមិនប្រតិសកម្ម ការរំលាយកិច្ចសន្យាមិនមានអានុភាពប្រតិសកម្មទេ។ ទោះបីជាមានការរំលាយកិច្ចសន្យាក៏ដោយ ។ ប៉ុន្តែទោះបីជាការរំលាយមិនមានអានុភាពប្រតិសកម្ម តែពេលមានការរំលាយកិច្ចសន្យា ម្ចាស់កម្មសិទ្ធិអាចទាមទារឱ្យធ្វើការផ្ទេរកម្មវត្ថុត្រឡប់មកវិញបាន ទោះបីជាវត្ថុនោះត្រូវបានផ្ទេរឱ្យតតិយជនហើយក៏ដោយ ។

[66] ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៩៣។

ផ្អែកលើគំនិតនេះវាមានលក្ខណៈស្រដៀងគ្នាទៅនឹងការផ្ទេរពីរដងជាន់គ្នា ដោយមិនគិតថាតតិយជនបានទិញកម្មវត្ថុនៅមុន ឬនៅក្រោយការរំលាយកិច្ចសន្យាទេ ដូច្នេះ បុគ្គលណាដែលបានទទួលនូវល័ក្ខខ័ណ្ឌតតាំងមុនបុគ្គលផ្សេងទៀត អាចអះអាងពីកម្មសិទ្ធិរបស់ខ្លួនបាន ។ វាមានន័យថាទោះបីជាមិនមានបញ្ញត្តិដូចជាមាត្រា ៤១១ កថាខណ្ឌទី៤ នៃក្រមរដ្ឋប្បវេណី ក៏លទ្ធផលដូចគ្នានឹងការផ្ទេរពីរដងជាន់គ្នា ដូច្នេះមាត្រា ៤១១ កថាខណ្ឌទី៤ គឺមិនមែនជាបញ្ញត្តិពិសេស ដើម្បីការពារតតិយជនដែលមានផលប្រយោជន៍ស្របច្បាប់ គឺគ្រាន់តែជាបញ្ញត្តិបញ្ជាក់បន្ថែមតែប៉ុណ្ណោះ[67]។

[67]ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាលនៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, (រាជធានីភ្នំពេញ ៖ សាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ខែ មេសា ឆ្នាំ ២០១៣), ទំព័រទី ១៩៣។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងបកស្រាយខាងលើរួចមក ការរំលាយកិច្ចសន្យាអាចធ្វើទៅបានលុះត្រាតែមានកិច្ចសន្យាសិនទើបអាចរំលាយកិច្ចសន្យាបាន។ ការរំលាយកិច្ចសន្យាអាចត្រូវបានរំលាយតាមមធ្យោបាយជាច្រើនដែលក្នុងនោះអាចរំលាយតាមរយៈការកំណត់ដោយច្បាប់ ការរំលាយតាមកិច្ចសន្យា និងការរំលាយតាមការព្រមព្រៀងរបស់គូភាគី។ ផ្ទុយទៅវិញ ប្រសិនបើភាគីមិនអាចរំលាយតាមកិច្ចសន្យាដោយហេតុថាមិនបានកំណត់ជាមុន និងការមិនយល់ព្រមពីភាគីម្ខាងទៀតទេ នោះភាគីដែលមានសិទ្ធិរំលាយអាចរំលាយកិច្ចសន្យាបានតាមរយៈច្បាប់កំណត់គឺធ្វើតាមបញ្ញត្តិច្បាប់សារធាតុក្រមរដ្ឋប្បវេណីដោយលើកឡើងអំពីល័ក្ខខ័ណ្ឌ ដែលត្រូវបានបំពេញដូចជាប្រភេទនៃកិច្ចសន្យាអញ្ញមញ្ញ និងភាគីម្ខាងទៀតបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ កិច្ចសន្យាអញ្ញមញ្ញគឺជាកិច្ចសន្យា ដែលភាគីមានបន្ទុកបំពេញកាតព្វកិច្ចទៅវិញទៅមកដូចជា កិច្ចសន្យាលក់ទិញ កិច្ចសន្យាម៉ៅការ ភតិសន្យា កិច្ចសន្យាលក់ទិញ រីឯការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ សំដៅលើករណីដែលភាគីម្ខាង មិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបានដោយសារការបំពានរបស់ភាគីម្ខាងទៀត។ ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរមានដូចជា ៖

**ក** - ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀត ដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ដោយកំណត់អំឡុងពេលសមរម្យដើម្បីឱ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះ។

**ខ** - ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យាក្នុងករណីគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះ បើភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នោះ។

**គ** - ភាគីមិនអាចអនុវត្តករណីយកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួនបានទេ។

**ឃ** - ការបំពាននូវកិច្ចសន្យាដែលមានភាពហួសហេតុដែលធ្វើឱ្យបាត់បង់នូវទំនុកចិត្តរវាងគូភាគីហើយមិនអាចជឿជាក់ថានឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន

នៅក្រោយពេលដែលភាគីបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ចំពោះភាគីម្ខាងទៀតអានុភាពនៃការរំលាយនឹងមាននៅពេលដែលការបង្ហាញឆន្ទៈ បានទៅដល់ភាគីម្ខាងទៀតបើទោះបីជាភាគីម្ខាងទៀតមិនបានបើកអានក៏ដោយ។ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាអាចត្រូវបានធ្វើឡើងតាមប្រព័ន្ធតុលាការ និងនៅក្រៅតុលាការ។ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាតាមប្រព័ន្ធតុលាការ គឺធ្វើឡើងតាមរយៈពាក្យបណ្តឹងជាលាយល័ក្ខអក្សររបស់ដើមចោទ ដែលជាភាគីដែលមានសិទ្ធិរំលាយកិច្ចសន្យា។ ហើយការសរសេរពាក្យបណ្តឹងក៏ត្រូវតែទាមទារឱ្យបានត្រឹមត្រូវផងដែរ។ ចំណែកឯរំលាយកិច្ចសន្យានៅក្រៅតុលាការវិញ គឺភាគីគ្រាន់តែបង្ហាញឆន្ទៈថារំលាយកិច្ចសន្យាដូចជាផ្ទាល់

មាត់ អ៊ីម៉ែលជាដើម។ ការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា មិនអាចដកវិញបានទេ បើទោះបីជាបានរំលាយនៅក្រៅតុលាការក៏ដោយ។ ព្រោះនឹងនាំឱ្យមានភាពច្របូកច្របល់ដល់សកម្មភាពជំនួញរបស់ភាគីម្ខាងទៀត ហើយកិច្ចសន្យាដែលត្រូវរំលាយបែរជាមានអានុភាពវិញ។ សិទ្ធិរំលាយកិច្ចសន្យារបស់ភាគីអាចត្រូវបានរលត់វិញដោយតែសកម្មភាពរបស់ភាគីដូចជាក្នុងករណីដែលកម្មវត្ថុនៃកិច្ចសន្យាត្រូវបានខូចខាត ឬបាត់បង់ដល់កម្មវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ឬមិនអាចសងវត្ថុនោះវិញបានដោយចេតនា ឬធ្វើឱ្យវត្ថុនោះក្លាយជាវត្ថុប្រភេទផ្សេងដោយការកែច្នៃ ឬផ្លាស់ទម្រង់ដោយចេតនា និងការរលត់សិទ្ធិរំលាយដោយអាជ្ញាយុកាលគឺ ៥ ឆ្នាំក្នុងករណីដែលអ្នកមានសិទ្ធិរំលាយមិនបានអនុវត្តសិទ្ធិ-រំលាយ។ នៅពេលដែលកិច្ចសន្យាត្រូវបានរំលាយជាស្ថាពរនោះ នឹងនាំឱ្យគូភាគីនៃកិច្ចសន្យារួចផុតពីករណីយកិច្ចដែលចងដោយកិច្ចសន្យា លើកលែងតែសំណងការខូចខាត និងត្រូវធ្វើបដិទានទៅស្ថានភាពដើមវិញ ភាគីដែលមានករណីយកិច្ចសងជាប្រាក់ ដោយការរំលាយកិច្ចសន្យាត្រូវសងជាមួយនឹងការប្រាក់ ដោយគិតចាប់ពីថ្ងៃដែលបានទទួលប្រាក់ដើមនោះ។ ភាគីដែលមានករណីយកិច្ចបង្វិលជាវត្ថុ ឬជាតាវកាលិកផ្សេង ដែលខ្លួនបានទទួលទៅភាគីម្ខាងទៀតដោយសារការរំលាយត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬតាវកាលិកនោះផងដែរ នេះគឺជាការវិធានការ-សង្គ្រោះកិច្ចសន្យាក្នុងករណីដែលភាគីម្ខាងបានបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ។ សំណងការខូចខាតជាវិធីមួយសម្រាប់សង្គ្រោះក្នុងករណីដែលមានការមិនអនុវត្តន៍កាតពកិច្ច ឬកាតព្វកិច្ចត្រូវបានបំពានផងដែរ ។ ថ្វីត្បិតតែភាគីបានជ្រើសរើសយកវិធីរំលាយកិច្ចសន្យាដើម្បីការពារប្រយោជន៍ខ្លួនក៏ពិតមែន ក៏មិនមានន័យថាគាត់មិនអាចទាមទារសំណងការខូចខាតបាននោះដែរ ។ នៅក្នុងវិធីនៃការ-សង្គ្រោះកិច្ចសន្យា ភាគីអាចប្រើវិធីសង្គ្រោះមួយ ឬ ច្រើនឱ្យតែវិធីសង្គ្រោះមិនមានលក្ខណៈផ្ទុយគ្នា។ មានន័យថា ភាគីអាចទាមទារឱ្យអនុវត្តដោយបង្ខំ និងទាមទារសំណងការខូចខាតបាន ឬភាគីរំលាយកិច្ចសន្យា និងទាមទារសំណងការខូចខាតបាន ប៉ុន្តែភាគីមិនអាចរំលាយកិច្ចសន្យា និងអនុវត្តដោយបង្ខំបានទេ។ ការរំលាយកិច្ចសន្យាមិនត្រឹមតែមានអានុភាពចំពោះភាគីប៉ុណ្ណោះទេ ពោលគឺមានអានុភាពចំពោះតតិយជនផងដែរ។ ការរំលាយកិច្ចសន្យាមិនអាចធ្វើឱ្យខូចផលប្រយោជន៍ត្រឹមត្រូវរបស់តតិយជនបានឡើយ។ នេះគឺជាគោលបំណងក្នុងការការពារស្ថិរភាពជំនួញរបស់តតិយជន ដែលត្រឹមត្រូវមិនឱ្យស្ថិតក្នុងស្ថានភាពមួយដែលអស្ថិរភាព ដែលរំលត់នូវការព្រួយបារម្ភទាំងឡាយរបស់តតិយជនត្រឹមត្រូវផងដែរ។ មិនមែនគ្រប់តតិយជនសុទ្ធតែត្រូវបានការពារទាំងអស់នោះទេ លុះត្រាតែ តតិយជននោះមានភាពត្រឹមត្រូវតាមច្បាប់។ តតិយជន ដែលមានផលប្រយោជន៍ត្រឹមត្រូវតាមច្បាប់នឹងត្រូវទទួលបាននូវការការពារ ហើយនេះក៏ជាយុទ្ធសាស្ត្ររបស់តុលាការកម្ពុជានាពេលអនាគតផងដែរក្នុងការវិនិច្ឆ័យទៅតាមអង្គហេតុនីមួយៗ។

# ឯកសារយោង


១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣។

២.ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០,ប្រកាសឱ្យប្រើថ្ងៃទី ៨ ខែធ្នូ ឆ្នាំ២០០៧។

៣.ក្រមនីតិវិធីរដ្ឋប្បវេណី, នស/រកម/០៧០៦/០២១, ៦,កក្កដា,២០០៦

៤. ក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់, ប្រកាសអន្តរក្រសួងស្តីពីនីតិវិធី-នៃការចុះបញ្ជីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី, (រាជធានីភ្នំពេញ ៖ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣)

៥.ក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី និងគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី, សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, ភាគ ២ គន្លឹះទី ៦, (ក្រសួង-យុត្តិធម៌,ភ្នំពេញ ២០១០)។

៦.ក្រុមការងារនៃអនាគតគ្រូបណ្តុះបណ្តាល នៅសាលាភូមិន្ទចៅក្រមនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី, ភាគ ២, ការកែសម្រួលលើការបោះពុម្ពលើកទី១, (រាជធានីភ្នំពេញ ខែ មេសា ឆ្នាំ ២០១៣)។

៧. សមិទ្ធផលរបស់គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ, , ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋ-ប្បវេណី ភាគ ២, (ក្រសួងយុត្តិធម៌ បោះពុម្ពលើកទី ១ ខែ ធ្នូ ឆ្នាំ ២០១៥)។

៨. មេធាវី ទេព បូផល និងលោក សេង នាង, កិច្ចពិភាក្សាស្តីពីការរំលាយកិច្ចសន្យា, រៀបចំដោយៈវិភាគទានច្បាប់, (មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ CKCCកាលបរិច្ឆេទៈ ០៩ មិថុនា ២០១៩)។

៩. គង់ សុភ័ក្រ, សញ្ញាណទូទៅនៃកាតព្វកិច្ច, ឆ្នាំ ២០១៨-២០១៩។

១០. អៀង សំណាង, ច្បាប់កិច្ចសន្យា, ឆ្នាំ ២០១៤។

១១. ញឹក វុធ្ធី, នីតិកាតព្វកិច្ច, ភាគ១ (សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)។

១២.សាស្ត្រាចារ្យ UMEMOTO YUMI , ការរំលាយកិច្ចសន្យា, (ក្រសួងយុត្តិធម៌ វិទ្យាស្ថានស្រាវជ្រាវ-ទូទៅអំពីកិច្ចការច្បាប់, នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ) ។

១៣. បណ្ឌិត ហាប់ ផល្លី, នីតិរដ្ឋប្បវេណី សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ ឆ្នាំទី ២ (ភ្នំពេញ ២០១៦ បោះពុម្ពឆ្នាំ ២០១៦។

១៤. ជ្រា ប៊ុនឡេង និងកែសម្រួលដោយលោក មេធាវី ស៊ុយ វុឌ្ឍី, ច្បាប់កិច្ចសន្យា, បោះពុម្ពឆ្នាំ ២០១៦។

១៥.លោក ខាន់ សុខា និងលោកស្រី ឌី លីឡា, រក្សាសិទ្ធិដោយ CAMBODIAN LAW GROUP, សុមេធកុលបុត្ត, ឆ្នាំបោះពុម្ព ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៨។

១៦.មេធាវី អ៊ីវ ប៉ូលី, ការរំលាយកិច្ចសន្យា,វិភាគទានច្បាប់ (ចែករំលែក),បោះពុម្ពថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៧។

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី ១**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃទី 06 ខែ 07 ឆ្នាំ 2018

សាលាដំបូងរាជធានីភ្នំពេញ
បង់ពន្ធរួច
បង្កាន់ដៃលេខ 0024189 11
ថ្ងៃទី 06 ខែ 07 ឆ្នាំ 2018

## ពាក្យបណ្តឹង

**ដើមចោទឈ្មោះ** [redacted] ភេទស្រី ឆ្នាំកំណើត:១៩៩២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:០២០៨៩១៩៦៦ ដែលមានទីលំនៅបច្ចុប្បន្ន: ផ្ទះលេខ៨៧ ភូមិព្រែកហូ សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល។ លេខទូរស័ព្ទទំនាក់ទំនង: ០១២២៣២៧៩២/០៩៦៦៦៦១១១៧។

**អ្នកតំណាងដោយអាណត្តិ:** លោក [redacted] អត្តលេខ១៨៦៨T ជាមេធាវីនៃក្រុមហ៊ុនមេធាវី [redacted] LAW FIRM) និងជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អាសយដ្ឋានការិយាល័យផ្ទះលេខ១៨CE0 ផ្លូវលេខ៣៨៨ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ (**ទីកន្លែងបញ្ជូន**)។ ទូរស័ព្ទទំនាក់ទំនង: (០១២/០១៥) ៨៨ ៥៥ ១២។

**ចុងចម្លើយឈ្មោះ:** [redacted] និង [redacted] តំណាងឈ្មោះ: [redacted] ភេទ ប្រុស ដែលមានទីតាំងការិយាល័យ: ផ្ទះលេខ៣៨ ផ្លូវ១ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ លេខទូរស័ព្ទទំនាក់ទំនង: ០៧០៦៥៥ ៨៥៥/០១១ ៧៥១ ០២៨

**តម្លៃកម្មវត្ថុនៃបណ្តឹង: ៤៦៧៥$** (បួនពាន់ប្រាំមួយរយចិតសិបប្រាំដុល្លារអាមេរិក) ។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ:** សំណើសុំប្តឹងទាមទារឲ្យផ្តល់តាវកាលិក។

តបតាមកម្មវត្ថុដូចបានជំរាបជូនខាងលើ [redacted] សូមដាក់ពាក្យបណ្តឹងជាលាយល័ក្ខអក្សរ ដូចតទៅ៖

**១). ខ្លឹមសារនៃសាលក្រមទាមទារឲ្យតុលាការចេញ៖**

- បង្គាប់ឲ្យចុងចម្លើយ សងប្រាក់ចំនួន **៤៦៧៥$** (បួនពាន់ប្រាំមួយរយចិតសិបប្រាំដុល្លារអាមេរិក) ថ្លៃទិញដីឡូត៍លេខ៤០៥ ស្ថិតនៅភូមិសេរីសម្បត្តិ សង្កាត់តឯនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ។
- សងសំណងនៃការខូចខាតខាងផ្លូវចិត្ត ដែលភាគីចុងចម្លើយបានបំពានកិច្ចសន្យាលក់-ទិញដីឡូត៍។
- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ។

**២). អង្គហេតុចាំបាច់បញ្ជាក់ពីការទាមទារ៖**

កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦ នាងខ្ញុំបានទិញដីឡូត៍មួយកន្លែងលេខ៤០៥ ពីឈ្មោះ: [redacted] ង សេង ផាលីន តំណាងដោយឈ្មោះ: [redacted] មានទទឹង០៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ ទំហំសរុប១០០ម៉ែត្រការ៉េ (មួយរយម៉ែត្រការ៉េ) ក្នុងមួយឡូត៍ មានតម្លៃសរុប៨០០០$ (ប្រាំបីពាន់ដុល្លារអាមេរិក) មានទីតាំងស្ថិតនៅភូមិសេរីសម្បត្តិ សង្កាត់តឯនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានព្រំប្រទល់៖ ខាងកើតទល់នឹងដីឡូត៍លេខ១២១ ៖

Activate Windows
Go to Settings to activate

Scanned by CamScanner

លិចទល់នឹងផ្លូវ១០ម៉ែត្រ ខាងត្បូងទល់នឹងដីឡូតិ៍លេខ៨០៤ និងខាងជើងទល់នឹងដីឡូតិ៍លេខ៨០៦ តាមរយៈកិច្ចសន្យាទិញ-លក់ដីឡូតិ៍ លេខ០៥៣ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦ ដែលរៀបចំដោយភាគីលក់ដីឡូតិ៍។ ភាគីអ្នកលក់ [redacted] និង [redacted] តំណាងដោយឈ្មោះ [redacted] បានបំពានកិច្ចសន្យាទិញ-លក់ដីឡូតិ៍នេះ នៅត្រង់ចំណុចប្រការ៧នៃកិច្ចសន្យាទិញ-លក់ដីឡូតិ៍ខាងលើ។

៣). មូលហេតុនៃអង្គហេតុចាំបាច់បញ្ជាក់ពីការទាមទារ៖

នៅពេលព្រមព្រៀងគ្នា នាងខ្ញុំបានបង់ប្រាក់កក់ចំនួន៥០០$ (ប្រាំរយដុល្លារអាមេរិក) នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៦ ហើយបន្ទាប់មកក៏បានធ្វើកិច្ចសន្យាទិញ-លក់ដីឡូតិ៍នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦។ នាងខ្ញុំក៏បានចាប់ផ្ដើមបង់ប្រាក់ទិញដីឡូតិ៍ខាងលើចាប់ពី ខែមិថុនា ឆ្នាំ២០១៦ រហូតមកដល់ ខែមេសា ឆ្នាំ២០១៨ ដែលមានទឹកប្រាក់សរុបចំនួន៨៦៧៥$។ តែអ្វីដែលធ្វើឲ្យនាងខ្ញុំខកចិត្តយ៉ាងខ្លាំងនោះ គឺនៅពេលដែលនាងខ្ញុំបានសួររកទីតាំងដីឡូតិ៍លេខ៨០៥ ភាគីអ្នកលក់ដីឡូតិ៍មិនបានផ្ដល់ព័ត៌មានពិតប្រាកដដល់នាងខ្ញុំឡើយ ចាប់តាំងពីនាងខ្ញុំបានបង់ប្រាក់ទិញដីឡូតិ៍នេះបានរយៈពេលមួយឆ្នាំ។ នៅខែមីនា ឆ្នាំ២០១៨ បុគ្គលិកលក់ដីឡូតិ៍ម្នាក់បាននាំនាងខ្ញុំទៅមើលដីដែលនាងខ្ញុំកំពុងទិញនេះ តែមិនបានរកដីឡូតិ៍លេខ៨០៥នេះឃើញឡើយ។ នាងខ្ញុំបានសួរអំពីមូលហេតុនេះ បុគ្គលិកលក់ដីឡូតិ៍នោះបានឆ្លើយថា៎ ខ្ញុំរកមិនឃើញដែរ ចំ។ នៅខែឧសភា ឆ្នាំ២០១៨ នាងខ្ញុំបានប្រាប់ទៅភាគីអ្នកលក់ថា នាងខ្ញុំសម្រេចចិត្តលប់ចោលកិច្ចសន្យាទិញ-លក់ដីឡូតិ៍ និងឈប់បង់ប្រាក់ ដោយទាមទារប្រាក់ចំនួន៨៦៧៥$ (បួនពាន់ប្រាំមួយរយចិតសិបប្រាំដុល្លារអាមេរិក) មកវិញពីភាគីអ្នកលក់ ទើបមានតំណាងភាគីអ្នកលក់បានទូរស័ព្ទមកប្រាប់នាងខ្ញុំថា ឲ្យនាងខ្ញុំទៅមើលដីនៅកន្លែងផ្សេងវិញ ព្រោះមានការដោះដូរដីឡូតិ៍។

៤). មូលហេតុនៃអង្គហេតុបន្ទាប់បន្សំបញ្ជាក់ពីការទាមទារ៖

នៅក្នុងអំឡុងខែឧសភា និង ខែមិថុនា ឆ្នាំ២០១៨ នាងខ្ញុំបានខំព្យាយាមជួបចរចារជាមួយភាគីលក់ដីឡូតិ៍ដែលមានភាគីឈ្មោះ **ស៊ីម តារា** ជាតំណាងឲ្យភាគីលក់ដីឡូតិ៍ ដើម្បីប្រាប់ពួកគេអំពីមូលហេតុដែលនាងខ្ញុំលែងទទួលយកបានពីការភូតកុហក់របស់ភាគីលក់ដីឡូតិ៍ និងទាមទារមកវិញ នូវចំនួនប្រាក់ខាងលើ ដែលនាងខ្ញុំបានបង់កន្លងមក ពោលគឺនាងខ្ញុំលែងចង់ទិញដីរបស់ភាគីលកដីឡូតិ៍នេះទៀតឡើយ។ តែភាគីលក់ដីឡូតិ៍ មិនបានឆ្លើយតបមកនាងខ្ញុំយ៉ាងណានោះឡើយរហូតមកដល់ពេលនេះ។

ហេតុដូច្នេះ សូមលោកប្រធានសាលាដំបូងរាជធានីភ្នំពេញ មេត្តាបង្គាប់ឲ្យភាគីចុងចម្លើយសងប្រាក់របស់នាងខ្ញុំមកវិញ ព្រមទាំងបង្គាប់ឲ្យសងសំណងនៃការខូចខាតខាងផ្លូវចិត្ត ដូចមានចែងក្នុងខ្លឹមសារនៃសាលក្រមទាមទារឲ្យតុលាការចេញខាងលើ អោយនាងខ្ញុំដោយយុត្តិធម៌។

សូមលោកប្រធានសាលាដំបូងរាជធានីភ្នំពេញ ទទួលនូវក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ៕

ថ្ងៃ.សុក្រ.៥ រោច......ខែ.បឋមាសាឍ..ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

......ភ្នំពេញ..........ថ្ងៃទី.០៦......ខែកក្កដា.......ឆ្នាំ២២០១៨

ស្នាមមេដៃស្ដាំអ្នកប្ដឹង



[redacted]

ឯកសារភ្ជាប់ជូន៖

- កិច្ចសន្យាទិញ-លក់ដីឡូតិ៍ ០១ច្បាប់។
- សក្ខីប័ត្របង់ប្រាក់ចំនួនចំនួន ២២សន្លឹក។
- តារាងសងប្រាក់ចំនួន០១ច្បាប់។

Activate Windows
Go to PC settings to activate

Scanned by CamScanner

**ឧបសម្ព័ន្ធទី ២**



# ករណីសិក្សា៖ រឿងក្តីសិទ្ធិទាមទារឱ្យធ្វើបដិទាន (ប្រគល់ដី និងលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិ) ផ្អែកលើការរំលាយកិច្ចសន្យា

## ការអះអាងរបស់ដើមចោទ A៖

ខ្ញុំ បានលក់ដី (អត្តសញ្ញាណដី) ក្នុងតម្លៃ $10,000 ឱ្យ B នៅថ្ងៃទី 01.01.2019 ដោយបានធ្វើជាលិខិតយថាភូត (លិខិតលក់ផ្តាច់) ហើយ B បានបង់ប្រាក់ $3,000 នៅថ្ងៃចុះកិច្ចសន្យា ចំណែកឯប្រាក់ដែលនៅសល់ចំនួន $7,000 B ត្រូវបង់នៅពេលដែលមានការផ្ទេរកម្មសិទ្ធិរួចរាល់ គឺនៅថ្ងៃទី01.02.2019។ កម្មសិទ្ធិត្រូវបានផ្ទេរពី A ទៅ B ហើយ A បានប្រគល់ដី តាមពេលកំណត់ ប៉ុន្តែ B មិនបានបង់ប្រាក់ដែលនៅសល់ចំនួន $7,000 ទេ ។ នៅថ្ងៃទី 01.04.2019 ខ្ញុំបានធ្វើការជូនដំណឹងដាស់តឿនឱ្យ B បង់ប្រាក់ដែលនៅសល់ចំនួន $7,000 ត្រឹមថ្ងៃទី04.04.2019 បើមិនបង់ទេ ខ្ញុំនឹងរំលាយកិច្ចសន្យាលក់ទិញនេះ។ ការជូនដំណឹងនេះផ្ញើឡើងតាមរយៈអ៊ីម៉ែលនៅថ្ងៃទី01.04.2019 ហើយនៅថ្ងៃដដែល B បានទទួលការជូនដំណឹងរបស់ខ្ញុំ ប៉ុន្តែថ្ងៃទី 04.04.2019 បានកន្លងផុត B នៅតែមិនបង់ថ្លៃលក់ដែលនៅសល់មកឱ្យខ្ញុំ។ កិច្ចសន្យាលក់ទិញរវាងខ្ញុំ និង B ត្រូវបានរំលាយ ហេតុនេះខ្ញុំចង់ឱ្យ B ប្រគល់ការកាន់កាប់ដីមកវិញ និងលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិ។

## ការអះអាងរបស់ចុងចម្លើយ B៖

ខ្ញុំពិតជាបានទិញដី (អត្តសញ្ញាណដី) ពី A មែន កាលពីថ្ងៃទី01.01.2019 ហើយនៅថ្ងៃចុះកិច្ចសន្យា ខ្ញុំបានបង់ប្រាក់ថ្លៃលក់ទិញលើកទី១ ចំនួន $3,000 និងត្រូវបង់ប្រាក់ដែលនៅសល់ចំនួន $7,000 នៅពេលដែលកម្មសិទ្ធិបានផ្ទេររួចរាល់ គឺថ្ងៃទី01.02.2019 ។ នៅថ្ងៃនោះ A បានប្រគល់ដី និងចុះបញ្ជីផ្ទេរកម្មសិទ្ធិមកឈ្មោះរបស់ខ្ញុំរួចរាល់ ប៉ុន្តែពេលនោះ ខ្ញុំមានការខ្វះខាតលុយ ប្រមូលមិនទាន់បានគ្រប់ចំនួនសម្រាប់បង់ឱ្យ A ហើយខ្ញុំបានសុំពេលពី A បន្ទាប់មក នៅថ្ងៃទី01.04.2019 ខ្ញុំបានយកលុយចំនួន $ 7,000 ទៅសង A ។ ដោយសារខ្ញុំបានបង់ប្រាក់ឱ្យ A រួចរាល់ គ្មានហេតុផលអ្វីដែល A ត្រូវជូនដំណឹងដាស់តឿនឱ្យខ្ញុំសងប្រាក់នោះទេ ជាក់ស្តែងខ្ញុំក៏មិនបានទទួលការដាស់តឿន និងការបង្ហាញឆន្ទៈរំលាយកិច្ចសន្យាពី A ដែរ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យបណ្ដឹង

**ដើមចោទ៖**

ឈ្មោះ ៖ A

អាសយដ្ឋាន ៖ ផ្ទះលេខ០០ ផ្លូវលេខ០០ សង្កាត់០០ ខណ្ឌ០០ រាជធានីភ្នំពេញ ។

**អ្នកតំណាងដោយអាណត្តិ៖**

លោក/លោកស្រី ៖ P

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ..................................................

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....................................

លេខទូរស័ព្ទ ៖ ...........................................................................................................

**ទីកន្លែងបញ្ជូន ៖** ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី..................................

**ចុងចម្លើយ៖**

ឈ្មោះ ៖ B

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់ ០០ ខណ្ឌ០០ រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ[1] ៖**

១. បង្គាប់ឱ្យចុងចម្លើយប្រគល់ដី ដែលមានកំណត់នៅក្នុងបញ្ជីសារពើភ័ណ្ឌនៃវត្ថុមកឱ្យដើមចោទ។

២. បង្គាប់ឱ្យចុងចម្លើយ ធ្វើនីតិវិធីចុះបញ្ជីអំពីការលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី ដែលមានកំណត់នៅក្នុងបញ្ជីសារពើភ័ណ្ឌស្ដីពីការចុះបញ្ជី ដោយមូលហេតុការរំលាយកិច្ចសន្យាចុះថ្ងៃទី05.04. 2019[2]។

[1] ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ គឺជាចំណុចដែលចាំបាច់ត្រូវសរសេរក្នុងពាក្យបណ្ដឹង (មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច «ខ» នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

[2] ប្រការ ៣១ នៃប្រកាសអន្តរក្រសួងស្ដីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រមរដ្ឋប្បវេណី

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ[3]។

៤. សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបានចំពោះចំណុចទី ១[4]។

## ខ. អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារ[5]

### ខ.១ ការប្រគល់ដី និងការលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិ

ខ.១.១ នៅថ្ងៃទី 01.01.2019 A (ដើមចោទ) បានលក់ដីដែលមានកំណត់នៅក្នុងបញ្ជីសារពើភ័ណ្ឌនៃវត្ថុ ឱ្យ B (ចុងចម្លើយ) ក្នុងតម្លៃ $10,000 ។ B បានបង់ប្រាក់ចំនួន $3,000 នៅថ្ងៃចុះកិច្ចសន្យា ហើយប្រាក់ដែលនៅសល់ចំនួន $7,000 A និងB ព្រមព្រៀងគ្នាបង់នៅពេលដែលបានប្រគល់ និងផ្ទេរកម្មសិទ្ធិរួចរាល់ គឺថ្ងៃទី 01.02.2019។ កិច្ចសន្យាលក់ទិញនេះ បានធ្វើឡើងដោយលិខិតយថាភូត[6] (ភស្តុតាង $X_1$)។

ខ.១.២ ផ្អែកតាមការព្រមព្រៀងខាងលើ ថ្ងៃទី 01.02.2019 បានកន្លងហួស B មិនបានបង់ប្រាក់ដែលនៅសល់ទេ។ A បានធ្វើការជូនដំណឹងដាស់តឿនតាមរយៈអ៊ីម៉ែល ឱ្យ B បង់ប្រាក់ដែលនៅសល់ចំនួន $7,000 ត្រឹមថ្ងៃទី 04.04.2019 បើមិនបង់ទេ A នឹងរំលាយកិច្ចសន្យាលក់ទិញ ហើយការជូនដំណឹងនេះបានទៅដល់ B នៅថ្ងៃទី 01.04.2019។ ប៉ុន្តែថ្ងៃទី04.04.2019 បានកន្លងផុត B មិនបានបង់ប្រាក់ដែលនៅសល់ទេ[7] (ភស្តុតាង $X_2$)។

ខ.១.៣ នៅថ្ងៃទី01.02.2019 A បានប្រគល់ដី (ផ្ទេរការកាន់កាប់) និងចុះបញ្ជីផ្ទេរកម្មសិទ្ធិឱ្យចុងចម្លើយរួចរាល់ផ្អែកតាមកិច្ចសន្យាលក់ទិញខាងលើ[8] (ភស្តុតាង $X_3$)។

[3] តុលាការត្រូវសម្រេចអំពីប្រាក់ប្រដាប់ក្តី ហើយប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកចាញ់ក្តី (មាត្រា ១៨២ កថាខណ្ឌទី៣ និងមាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

[4] មាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

[5] មាត្រា ៧៥ កថាខណ្ឌទី ២ ចំណុច «ខ» និង កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[6] មាត្រា ៤០៧ និងមាត្រា៣៣៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

[7] មាត្រា ៤០៨ កថាខណ្ឌទី ១ ចំណុច «ក» នៃក្រមរដ្ឋប្បវេណី

[8] មាត្រា ៤១១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី

ហេតុនេះ ដើមចោទទាមទារឱ្យចុងចម្លើយធ្វើបដិទានស្ថានភាពដើម គឺប្រគល់ដី ដែលមានកំណត់នៅក្នុងបញ្ជីសារពើភ័ណ្ឌនៃវត្ថុ និងធ្វើនីតិវិធីចុះបញ្ជីអំពីការលុបចោលការចុះបញ្ជីផ្ទេរកម្មសិទ្ធិលើដី ដែលមានកំណត់នៅក្នុងបញ្ជីសារពើភ័ណ្ឌនៃការចុះបញ្ជីមកឱ្យដើមចោទ ដោយផ្អែកលើការរំលាយកិច្ចសន្យា [៩]។

ខ.២ ប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដីនៃរឿងក្ដីនេះគប្បីឱ្យចុងចម្លើយទទួលបន្ទុក (មាត្រា ៦៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

ខ.៣ ការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន

ដោយសារតែរឿងក្ដីនេះគឺ ជារឿងក្ដីទាមទារឱ្យប្រគល់ដី និងលុបចោលការចុះបញ្ជី ហើយដើមចោទមានភស្តុតាងគ្រប់គ្រាន់ក្នុងការទាមទារ ហេតុនេះស្នើសុំឱ្យតុលាការប្រកាសឱ្យអនុវត្តជាបណ្ដោះអាសន្ន ចំពោះចំណុចទី១(មាត្រា ១៩៦ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

**គ. ភស្តុតាង**

១. លិខិតយថាភូតស្ដីពីការលក់ទិញ ចុះថ្ងៃទី01.01.2019 (ភស្តុតាង $X_1$)

២. សារអេឡិចត្រូនិចអំពីការដាស់តឿនឱ្យបង់ប្រាក់ភ្ជាប់ជាមួយនឹងកំណត់ពេលរំលាយថ្ងៃទី 01.04.2019 (ភស្តុតាង $X_2$)

៣. វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី 01.02.2019 (ភស្តុតាង $X_3$)

សេចក្ដីដូចមានកំណត់ សូម **ឯកឧត្ដមប្រធាន** សម្រេចតាមការស្នើសុំ ដោយក្ដីអនុគ្រោះ។ សូម **ឯកឧត្ដមប្រធាន** ទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ ឧសភា ឆ្នាំ២០១៩

**អ្នកតំណាងដោយអាណត្តិ**

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ "ច្បាប់ដើម"

២-ច្បាប់ថតចម្លងនៃភស្តុតាងនីមួយៗខាងលើ "ចំនួន ០៣ ច្បាប់"

P

[៩] ត្រូវបញ្ជាក់ឱ្យបានច្បាស់នូវលក្ខណៈគតិយុត្តនៃការទាមទារ (កម្មវត្ថុនៃបណ្ដឹង)។



Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚

**ឯកសារចម្លើយ[1]**

**<u>ដើមចោទ ៖</u>**

ឈ្មោះ ៖ A

អាសយដ្ឋាន៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់00 ខណ្ឌ00 រាជធានីភ្នំពេញ។

**<u>ចុងចម្លើយ៖</u>**

ឈ្មោះ ៖ B

អាសយដ្ឋាន ៖ ផ្ទះលេខ 00 ផ្លូវលេខ 00 សង្កាត់00 ខណ្ឌ00 រាជធានីភ្នំពេញ។

**<u>អ្នកតំណាងដោយអាណត្តិ៖</u>**

លោក/លោកស្រី ៖ T

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ..............................................

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ..................................

លេខទូរស័ព្ទ ៖ ..........................................................................................

<u>ទីកន្លែងបញ្ជូន ៖</u> ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី...................................

**សូមគោរពជូន**

**លោក J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>** ៖ សុំដាក់ ឯកសារចម្លើយដើម្បីឆ្លើយតបនឹងពាក្យបណ្ដឹងចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០១៩ របស់ ឈ្មោះ A

**<u>យោង</u>**៖ - មាត្រា ១០១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

- សំណុំរឿងរដ្ឋប្បវេណីលេខ ៨១៩ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៩

[1] ឯកសារចម្លើយ គឺជាឯកសារត្រៀមដែលចុងចម្លើយដាក់ទៅតុលាការលើកដំបូង ហេតុនេះ ការបង្កើតឯកសារចម្លើយត្រូវស្រប តាមមាត្រា ១០១ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ក. ការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារ**

(១) ច្រានចោលការទាមទារទាំងអស់របស់ដើមចោទ។

(២) ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

**ខ. ការទទួលស្គាល់ ឬមិនទទួលស្គាល់អង្គហេតុដែលមានសរសេរនៅក្នុងពាក្យបណ្ដឹង**

ខ.១ ស្ដីពីអង្គហេតុ «ខ.១.១» ដែលត្រូវបានសរសេរនៅក្នុងពាក្យបណ្ដឹង ៖ ចុងចម្លើយទទួលស្គាល់ទាំងស្រុង ។

ខ.២ ស្ដីពីអង្គហេតុ «ខ.១.២» **ត្រង់ចំណុចដាស់តឿន និងការបង្ហាញឆន្ទៈរំលាយ** ដែលសរសេរនៅក្នុងពាក្យបណ្ដឹង ៖ ចុងចម្លើយមានវិវាទ។

ខ.៣ ស្ដីពីអង្គហេតុ «ខ.១.៣» ដែលត្រូវបានសរសេរនៅក្នុងពាក្យបណ្ដឹង៖ ចុងចម្លើយទទួលស្គាល់ទាំងស្រុង។

**គ. អង្គហេតុតទល់**

ការសង

នៅកាលបរិច្ឆេទដែលចុងចម្លើយ ត្រូវបង់ប្រាក់ដែលនៅសល់ចំនួន $7,000 ចុងចម្លើយបានសុំការពន្យាពេលពីដើមចោទ បន្ទាប់មក នៅថ្ងៃទី01.04.2019 ចុងចម្លើយបានបង់ប្រាក់ដែលនៅសល់ចំនួន $7,000ទៅ ឱ្យ ដើមចោទ A ។

**ឃ.ភស្ដុតាង**

លិខិតយថាភូត ស្ដីពីការលក់ទិញ ចុះថ្ងៃទី01.01.2019 (ភស្ដុតាង $Y_1$)

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្ដីអនុគ្រោះ។

រាជធានីភ្នំពេញថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៩

**អ្នកតំណាងដោយអាណត្តិ**

T

<u>ឯកសារភ្ជាប់</u>

១-លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ «ច្បាប់ដើម»

២-ច្បាប់ថតចម្លងនៃភស្ដុតាងនីមួយៗខាងលើ «ចំនួន ០២ ច្បាប់»

៣-ឯកសារចម្លងនៃឯកសារចម្លើយ «ចំនួន ០២ ច្បាប់»

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ឯកសារត្រៀមលើកទី ១ របស់ដើមចោទ

**ដើមចោទ ៖**

ឈ្មោះ ៖ A

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់០០ ខណ្ឌ០០ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ ៖**

លោក/លោកស្រី ៖ P

ការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ..................................................

អាសយដ្ឋានការិយាល័យមេធាវី / ក្រុមមេធាវី / ក្រុមហ៊ុនមេធាវី ៖ ....................................

លេខទូរស័ព្ទ ៖ ..........................................................................................

**ទីកន្លែងបញ្ជូន ៖** ការិយាល័យមេធាវី/ ក្រុមមេធាវី/ ក្រុមហ៊ុនមេធាវី..................................

**ចុងចម្លើយ ៖**

ឈ្មោះ ៖ B

អាសយដ្ឋាន ៖ ផ្ទះលេខ ០០ ផ្លូវលេខ ០០ សង្កាត់០០ ខណ្ឌ០០ រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោក J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំដាក់ ឯកសារត្រៀមលើក ទី១ របស់ដើមចោទដើម្បីឆ្លើយតបចំពោះ ឯកសារចម្លើយរបស់ឈ្មោះ B ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១៩ ។

**យោង** ៖-មាត្រា ១០១ កថាខណ្ឌទី ២នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ ៨១៩ ចុះថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៩

**ក. ការទទួលស្គាល់ ឬ មិនទទួលស្គាល់ចំពោះឯកសារចម្លើយ** [1]

ស្ដីពីអង្គហេតុ «គ» អំពីការសង ដែលត្រូវបានសរសេរនៅក្នុងឯកសារចម្លើយ៖ ដើមចោទមិនទទួលស្គាល់ទេ ។

សូម **លោកចៅក្រម** សម្រេចតាមការអះអាងខាងលើ ដោយក្ដីអនុគ្រោះ។

រាជធានីភ្នំពេញ, ថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០១៩

**អ្នកតំណាងដោយអាណត្តិ**

P

[1] ចំណុចដែលត្រូវសរសេរនៅក្នុងឯកសារត្រៀម៖ ① មធ្យោបាយតទល់ ឬ ការពារខ្លួន និង ② សេចក្ដីថ្លែងការណ៍ ចំពោះមធ្យោបាយតទល់ ឬ ការពារខ្លួនរបស់ភាគីម្ខាងទៀត (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ១០១ កថាខណ្ឌទី ២)។



Scanned with CamScanner

**ឧបសម្ព័ន្ធទី ៣**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>លិខិតជូនដំណឹង</u>

លោក [redacted] ជនជាតិខ្មែរ កើតនៅឆ្នាំ១៩៧៥ កាន់អត្តសញ្ញាណប័ណ្ណលេខ ១៣០០២៦២១៦ និងអ្នកស្រី [redacted] ជនជាតិខ្មែរ កើតឆ្នាំ១៩៧៩ កាន់អត្តសញ្ញាណប័ណ្ណលេខ ១៣០០៣២៧៣៤ មានទីលំនៅស្ថិតនៅក្នុងភូមិ៤ សង្កាត់៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលជាម្ចាស់ផ្ទះ ឬភាគី ក ។

**<u>ជំរាបមក</u>**

លោកស្រី [redacted] កើតឆ្នាំ១៩៦៨ សញ្ជាតិចិន មានលិខិតឆ្លងដែនលេខ: G33608615 មានអាសយដ្ឋានផ្ទះលេខ៨ ផ្លូវ២៨៥ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ដែលតំណាងអោយក្រុមហ៊ុន [redacted] រៀល អ៊ីស្ទេត ឌេវ៉ឺឡុបមេន ជាអ្នកជួល ឬ ភាគី ខ ។

**កម្មវត្ថុ:** រំលាយកិច្ចសន្យាជួលចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ រវាងឈ្មោះ ផង់ យ៉ុត និងក្រុមហ៊ុន ស៊ីជីស៊ីន យាន រៀល អ៊ីស្ទេត ។

**យោង:** - ប្រការ១៦.២ នៃកិច្ចសន្យាជួល ចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៤។
- កិច្ចសន្យាជួល ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៦។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំមានកិត្តិយសជំរាបជូនលោកស្រី [redacted] ដែលលោកស្រីបានមានការខកខានមិនបានបំពេញកាតព្វកិច្ចក្នុងនាមជាភាគី ដូចមានកំណត់ក្នុងកិច្ចសន្យាជួលចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ២០១៤ និងកិច្ចព្រមព្រៀងជួលសណ្ឋាគារចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ដែលជាហេតុនាំអោយយើងខ្ញុំបាត់បង់ផលប្រយោជន៍យ៉ាងខ្លាំង។

ហេតុដូចបានជំរាបជូនខាងលើ យើងខ្ញុំទុកពេលវេលានេះ អោយលោកស្រីមកបំពេញកាតព្វកិច្ចក្នុងនាមជាគូភាគីនៃកិច្ចព្រមព្រៀងខាងលើរយៈពេល ៧ថ្ងៃ ដោយគិតចាប់ពីថ្ងៃយើងខ្ញុំ បានចុះនិងបិទផ្សាយលិខិតនេះជាសាធារណៈ ។

សូម លោកស្រី និងសាធារណៈ ជនជ្រាបជាព័ត៌មាន ។

ខេត្តព្រះសីហនុ.ថ្ងៃទី.16.ខែមករា ឆ្នាំ២០១៧

**ស្នាមមេដៃភាគី**

[redacted] [redacted]

បញ្ជាក់ថា៖
ស្នាមមេដៃទាំងពីរនេះពិតជាស្នាមមេដៃ
របស់ឈ្មោះ [redacted] និងឈ្មោះ [redacted]
[redacted] ប្រាកដមែន។
ថ្ងៃទី.16.ខែមករា ឆ្នាំ២០១៧

KINGDOM OF CAMBODIA
AVOCAT
ATTORNEY
AT LAW

**ការិយាល័យ ធិនត្រា**
**មេធាវី**

មេធាវី.ហេង_រិទ្ធី

Activate Windows
Go to PC settings to activate

Scanned by CamScanner

**ឧបសម្ព័ន្ធទី ៤**

crystal
condominium

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ៖PSCC601 (S3)

# កិច្ចព្រមព្រៀងលក់-ទិញខុនដូ

កិច្ចព្រមព្រៀងទិញលក់-ទិញខុនដូនេះត្រូវបានធ្វើឡើង

រវាង

គម្រោងខុនដូគ្រីស្តាល់អេសគ្រីស្តាល់មានអាសយដ្ឋានលេខ 1200 ផ្លូវលេខ 108Tភូមិសន្សំកុសល1សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ("**អ្នកអភិវឌ្ឍន៍អចលនវត្ថុ**")

និង

លោក [redacted] សញ្ជាតិខ្មែរអត្តសញ្ញាណប័ណ្ណលេខ 010873864 មានទីលំនៅផ្ទះលេខ 239 ផ្លូវមៅសេទុង សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ ("**អ្នកទិញ**")

**សេចក្តីថ្លែងរបស់អ្នកអភិវឌ្ឍន៍អចលនវត្ថុ**

**ដោយហេតុថា៖**

- អ្នកអភិវឌ្ឍន៍អចលនវត្ថុជាកម្មសិទ្ធិករស្របច្បាប់លើក្បាលដីលេខ 391តាងដោយវិញ្ញាបនបត្រលេខ 12060202-0391ដែលភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធខ
- លោកស្រីអ៊ិតសុគន្ធាកាន់អត្តសញ្ញាណប័ណ្ណលេខ 010663980 ជាតំណាងស្របច្បាប់នៃអ្នកអភិវឌ្ឍន៍អចលវត្ថុ
- ខុនដូនឹងត្រូវសាងសង់ស្របតាមប្លង់ស្ថាបត្យករដែលភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធ គ ឃ ង ជាពិសេស ប្លង់នេះមានទីតាំងសំរាប់ជួយសំរួលដល់ម្ចាស់ចំណែកឯកជន ដូចជា ភោជនីយដ្ឋាន, អាងហែលទឹក, កន្លែងក្មេងលេង, បន្ទប់ស្ទីម បន្ទប់សោណា, បន្ទប់ហាត់ប្រាណ, បន្ទប់ប្រជុំ, ផ្សារ, ហាងបោកអ៊ុត, ហាងអ៊ុតសក់។ល។ ប៉ុន្តែ ទីតាំងទាំងនោះជាកម្មសិទ្ធិផ្តាច់មុខរបស់អ្នកអភិវឌ្ឍន៍អចលនវត្ថុ។
- អ្នកអភិវឌ្ឍន៍អចលនវត្ថុបានរៀបចំបទបញ្ជាផ្ទៃក្នុងដែលចែងក្នុងឧបសម្ព័ន្ធឆ។



Activate Windows
Go to PC settings to activate

Scanned by CamScanner

- ធនាគារ Advanced Bank of Asia Ltd. (ABA).

  ឈ្មោះគណនីអ៊ិតសុគន្ធា(ITH SOKUNTHEA)

  គណនីលេខ 000049999

- ធនាគារ ACLEDA Bank Plc. (ACLEDA).

  ឈ្មោះគណនីអ៊ិតសុគន្ធា(ITH SOKUNTHEA)

  គណនីលេខ 3473-02083888-18

## ៣. រយៈពេលនៃការសាងសង់

ផ្អែកលើប្លង់នៃខុនដូ និង ការប៉ាន់ស្មានរបស់អ្នកអភិវឌ្ឍន៍អចលនវត្ថុ ការសាងសង់ខុនដូត្រូវចំណាយក្នុងរយៈពេល30ខែ ចាប់ផ្តើមពី**ខែកញ្ញាឆ្នាំ2015**រហូតដល់**ខែមិនាឆ្នាំ2018**លើកលែងតែមានការពន្យា ឬ ការអាក់ខានដែលបណ្តាលមកពី ករណីប្រធានសក្តិ ឬ បណ្តាលមកពីការខកខានរបស់អ្នកទិញក្នុងការបង់ថ្លៃទិញ ឬការខកខានរបស់អ្នកទិញមិនបានគោរពតាមខនិងលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ ក្នុងករណីដែលអ្នកអភិវឌ្ឍន៍អចលនវត្ថុ បញ្ចប់ការសាងសង់ខុនដូយឺតពេល នោះអ្នកអភិវឌ្ឍន៍អចលនវត្ថុសុខចិត្តបង់ថ្លៃ ៥%(ប្រាំភាគរយ)ក្នុង១(មួយ)ឆ្នាំ នៃចំនួនទឹកប្រាក់ដែលបានបង់រួចទៅឲ្យអ្នកទិញ។

## ៤. ការបញ្ចប់ការទិញលក់

ការបញ្ចប់ការទិញលក់នេះត្រូវធ្វើនៅការិយាល័យនៃអ្នកអភិវឌ្ឍន៍អចលនវត្ថុ។ អ្នកទិញត្រូវប្រគល់ ឬ បង់ទឹកប្រាក់បង្ហើយនៃវគ្គចុងក្រោយបង្អស់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ ក។

អ្នកអភិវឌ្ឍន៍អចលនវត្ថុត្រូវផ្តល់នូវ"លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងផ្ទះសម្បែង"។សោហ៊ុយចំណាយសំរាប់ការរៀបចំ"លិខិតផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងផ្ទះសម្បែង" នេះជាបន្ទុករបស់អ្នកអភិវឌ្ឍន៍អចលនវត្ថុ។

## ៥. ការចុះបញ្ជីសុំវិញ្ញាបនប័ត្រសម្គាល់ម្ចាស់ចំណែកឯកជន

អ្នកអភិវឌ្ឍន៍អចលនវត្ថុត្រូវផ្តល់ឯកសារនានាដែលចាំបាច់ដើម្បីឲ្យអ្នកទិញអាចចុះបញ្ជីសុំវិញ្ញាបនប័ត្រសម្គាល់ម្ចាស់ចំណែកទ្រព្យឯកជន។ ការចំណាយនៅក្នុងការចុះបញ្ជីនេះ ដូចជាពន្ធប្រថាប់ត្រា និង សោហ៊ុយដទៃទៀត ត្រូវជាបន្ទុករបស់អ្នកទិញ។

## ៦. ការចូលកាន់កាប់ចំណែកទ្រព្យឯកជន

crystal
condominium

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៖ PSCCLO-009-1

# លិខិតជូនដំណឹងអំពីការយឺតយ៉ាវក្នុងការបង់ប្រាក់

**គម្រោងខុនដូមីញ៉ូមគ្រីស្តាល់** មានរាស័យដ្ឋានលេខ ១២០០ ផ្លូវលេខ ១០BT ភូមិសន្សំកុសល១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

**សូមគោរពជូន**

[redacted]

រាស័យដ្ឋានបច្ចុប្បន្ន៖ ផ្ទះលេខ 239 ផ្លូវ មៅសេទុង សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ ( អ្នកទិញ )។

**កម្មវត្ថុ៖** ជូនដំណឹងអំពីការយឺតយ៉ាវក្នុងការបង់ប្រាក់រំលោះថ្លៃទិញលក់ខុនដូនិងស្នើសុំអោយមានការបង់ប្រាក់ឡើងវិញស្របតាមកិច្ចព្រមព្រៀងទិញលក់ខុនដូ។

**យោង៖** កិច្ចព្រមព្រៀងលក់-ទិញខុនដូ បន្ទប់ S3-601 ចុះថ្ងៃទី 19 ខែ សីហា ឆ្នាំ2015។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំ សូមជម្រាបជូន លោក មេត្តាជ្រាបថា៖ លោក បានខកខានមិនបានបង់ប្រាក់ថ្លៃលក់-ទិញខុន ចំនួន 03 ខែ។ ហេតុដូច្នេះនាងខ្ញុំស្នើអោយ លោក មេត្តាអញ្ជើញមកធ្វើការបង់ប្រាក់ ស្មើនឹងចំនួន ដូចខាងក្រោម៖

- ប្រាក់ប្រចាំខែ វិច្ឆកា ឆ្នាំ 2016 ចំនួន 500 (ដុល្លារអាមេរិក)។
- ប្រាក់ប្រចាំខែ ធ្នូ ឆ្នាំ 2016 ចំនួន 500 (ដុល្លារអាមេរិក)។
- ប្រាក់ប្រចាំខែ មករា ឆ្នាំ 2017 ចំនួន 500 (ដុល្លារអាមេរិក)។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ នាងខ្ញុំស្នើអោយ លោក មេត្តា អញ្ជើញមកធ្វើការបង់ប្រាក់តាមចំនួនដូចបានរៀបរាប់ខាងលើដោយស្ម័គ្រចិត្ត ក្នុងអំឡុងពេល ០៧ ថ្ងៃ បន្ទាប់ពីថ្ងៃដែលចេញលិខិតនេះ។

សូម លោក មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី 10 ខែ កុម្ភៈ ឆ្នាំ2017

**ហត្ថលេខា និងត្រា**

[redacted]

Activate Windows
Go to PC settings to activate Windows

crystal
condominium

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ ៖ PSCCLO-017-1

## លិខិតជូនដំណឹងអំពីការយឺតយ៉ាវក្នុងការបង់ប្រាក់

គម្រោងខុនដូគីធអសគ្រីស្តាល់ មានអាស័យដ្ឋានលេខ ១២០០ ផ្លូវលេខ ១០BT ភូមិសន្សំកុសល១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**<u>សូមគោរពជូន</u>**

[redacted]

អាស័យដ្ឋានបច្ចុប្បន្ន៖ លោក សុខ គីមហាក់ សញ្ជាតិខ្មែរ អត្តសញ្ញាណប័ណ្ណលេខ 010873864 មានទីលំនៅផ្ទះលេខ239 ផ្លូវម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ។

**<u>កម្មវត្ថុ៖</u>** ជូនដំណឹងអំពីការយឺតយ៉ាវក្នុងការបង់ប្រាក់រំលោះថ្លៃទិញលក់ខុនដូ និងស្នើសុំ អោយមានការបង់ប្រាក់ឡើងវិញស្របតាមកិច្ចព្រមព្រៀងទិញលក់ខុនដូ។

**<u>យោង៖</u>** កិច្ចព្រមព្រៀងលក់-ទិញខុនដូ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ២០១៥។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំ សូមជម្រាបជូន លោក មេត្តាជ្រាបថា៖ លោក បានខកខានមិនបានបង់ប្រាក់ថ្លៃលក់-ទិញខុនដូតាំងពី ខែមិនា ២០១៨។ ហេតុដូច្នេះនាងខ្ញុំស្នើអោយ លោក មេត្តាអញ្ជើញមកធ្វើការបង់ប្រាក់ ស្មើនឹងចំនួន ដូចខាងក្រោម៖

- ប្រាក់បង់បញ្ចប់ខែ មិនា ឆ្នាំ 2018 ចំនួន 19,962 USD (ដុល្លារអាមេរិក)។

សេចក្តីដូចបានជម្រាបជូនខាងលើនេះ នាងខ្ញុំស្នើអោយ លោក មេត្តា អញ្ជើញមកធ្វើការបង់ប្រាក់តាមចំនួនដូចបានរៀបរាប់ខាងលើដោយស្ម័គ្រចិត្ត ក្នុងអំឡុងពេល០៧ ថ្ងៃបន្ទាប់ពីថ្ងៃដែលចេញលិខិតនេះ។
សូម លោក មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី 11 ខែ មិថុនា ឆ្នាំ2018

ហត្ថលេខា និងត្រា

crystal
condominium

Activate Windows
Go to PC settings to activate Win

ខេអិន ការិយាល័យពិគ្រោះច្បាប់
LEGAL CONSULTING

## លិខិតជូនដំណឹងអំពីការរំលាយកិច្ចសន្យា

ខ្ញុំបាទ [redacted] ជាសមាជិកនៃការិយាល័យពិគ្រោះច្បាប់ ខេអិន មានអាសយដ្ឋាននៅ ផ្ទះលេខ ៦៣ឈ ភូមិបុរី១០០ខ្នង សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងជាមេធាវីប្រចាំគម្រោង គីរអេសត្រីស្កាល់ខុនដូ។ លេខទូរស័ព្ទ: ០៧៧ ៣៥ ៦៥ ៨៨, ០៩៦ ៥៥ ៥៥ ០៦៧។

**សូមគោរពជូន**

[redacted]

អាសយដ្ឋាន: ផ្ទះលេខ២៣៩ ផ្លូវម៉ៅសេទុង សង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមន រាជធានីភ្នំពេញ

**កម្មវត្ថុ:** សូមជូនដំណឹងអំពីការរំលាយកិច្ចព្រមព្រៀងទិញលក់ខុនដូ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ដែលមានចំណែកឯកជនលេខ ៦០១ ស្ថិតនៅជាន់ទី៦ នៃអគារគីរអេសត្រីស្កាល់ខុនដូ។

**យោង:** កិច្ចព្រមព្រៀងទិញលក់ខុនដូ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥។

សេចក្ដីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន លោក មេត្តាជាបថា ខ្ញុំបាទសរសេរលិខិតនេះក្នុងគោលបំណងជូនដំណឹងលោកអំពីការរំលាយកិច្ចព្រមព្រៀងទិញលក់ខុនដូ :ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ គិតចាប់ពីថ្ងៃចេញលិខិតនេះតទៅ។ ការរំលាយកិច្ចសន្យានេះផ្អែកតាមមូលាន អង្គហេតុ និង ច្បាប់ដូចខាងក្រោម:

### ក. មូលដ្ឋានអង្គហេតុ

)) . កាលពីថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ លោក និងគម្រោងគីរអេសត្រីស្កាល់ បានចុះកិច្ចព្រមព្រៀងទិញលក់ខុនដូ ទៅលើចំណែកឯកជនលេខ ៦០១ ជាន់ទី៦ ក្នុងតម្លៃ ៤៩,៩៦២ ដុល្លារអាមេរិក (សែសិបប្រាំបួនពាន់ ប្រាំបួនរយ ហុកសិបពីរ ដុល្លារអាមេរិក) ដោយធ្វើការបង់រំលស់ទៅតាមតារាងរំលស់ដែលមានចែងក្នុងកិច្ចព្រមព្រៀង។

Activate Windows
Go to PC settings

(២) លោកបានធ្វើការបង់ប្រាក់សរុបជូនគម្រោងភីអេសគ្រីស្តាល់ ចំនួន ២០,៤៦២ ដុល្លារអាមេរិក (ម្ភៃពាន់ បួនរយ ហុកសិបពីរ ដុល្លារអាមេរិក) និងនៅសល់ប្រាក់ចំនួន ១៩,៩៦២ ដុល្លារអាមេរិក (ដប់ប្រាំបួនពាន់ ប្រាំបួនរយ ហុកសិបពីរ ដុល្លារអាមេរិក) ដែលមិនទាន់បានបង់ ហើយការយឺតយ៉ាវនេះត្រូវបានរួសបន្លាយតិតចាប់តាំងពី ខែកុម្ភៈ ឆ្នាំ២០១៨ មក។

(៣) គម្រោងភីអេសគ្រីស្តាល់ បានជូនដំណឹងជាលាយលក្ខណ៍អក្សរមកលោក នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ អោយលោកមកធ្វើការទូទាត់ប្រាក់តាមកិច្ចព្រមព្រៀង តែរហូតមកដល់បច្ចុប្បន្ន លោកនៅតែពុំបានធ្វើការបង់ប្រាក់។

(៤) ការយឺតយ៉ាវនេះធ្វើអោយគម្រោងភីអេសគ្រីស្តាល់ ទទួលរងការខូចខាតដោយសារការជាប់គាំតាមរយៈការមិនបង់ប្រាក់តាមកិច្ចព្រមព្រៀង។

ខ. <u>មូលដ្ឋានច្បាប់</u>

ខ១. <u>ការបំពានកិច្ចព្រមព្រៀង</u>

យោងទៅលើអង្គហេតុខាងលើ ខ្ញុំបាទអាចសន្និដ្ឋានបានថា លោកបានបំពានកិច្ចព្រមព្រៀងយ៉ាងធ្ងន់ធ្ងរ ដែលកិច្ចព្រមព្រៀងត្រូវចាត់ទុកថាជាច្បាប់របស់គូភាគីនៃកិច្ចព្រមព្រៀងត្រូវអនុវត្តតាម។ ការបំពានកិច្ចព្រមព្រៀងយ៉ាងធ្ងន់ធ្ងរត្រូវបានកំណត់ដោយ ប្រការ ១១ និង ប្រការ ១២.២ នៃកិច្ចព្រមព្រៀងទិញលក់ខុនដូចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ដែលមានខ្លឹមសារដូចខាងក្រោមៈ

ប្រការ១១៖

*"ព្រឹត្តិការណ៍ជាអាទិ៍ដូចខាងក្រោមនេះត្រូវចាត់ទុកថាជាការខកខាន ការបំពាន ការមិនអនុវត្តតាម ខ និង លក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ៖*

*ក. ការយឺតយ៉ាវមិនបង់ប្រាក់ថ្លៃទិញស្របទៅតាមផែនការបង់រំលោះ ដែលមានចែងក្នុងឧបសម្ព័ន្ធ ក"*

ប្រការ ១២.២៖

*"បើអ្នកទិញមិនបានបង់ប្រាក់ដែលយឺតយ៉ាវក្នុងរយៈពេល ១៥ថ្ងៃ ដូចមានចែងក្នុងកថាខណ្ឌខាងលើទេ អ្នកអភិវឌ្ឍន៍អចលនវត្ថុអាចលុបចោលកិច្ចព្រមព្រៀងហើយតាមរយៈកិច្ចព្រមព្រៀងនេះ អ្នកទិញយល់ព្រមអោយអ្នកអភិវឌ្ឍន៍លុបចោលកិច្ចព្រមព្រៀង ហើយតាមកិច្ចព្រមព្រៀងនេះអ្នកទិញយល់ព្រមអោយអ្នកអភិវឌ្ឍន៍រឹបអូសប្រាក់ដែលបានបង់រួចហើយទាំងអស់ ហើយអ្នកអភិវឌ្ឍន៍អចលនវត្ថុមានសិទ្ធិលក់ចំណែកទ្រព្យឯកជននោះទៅអោយអ្នកផ្សេង។"*



Activate Windows
Go to PC settings to a

## ៥២. <u>សិទ្ធិក្នុងការរំលាយកិច្ចព្រមព្រៀងដែលកំណត់ដោយក្រមរដ្ឋប្បវេណី</u>

មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានកំណត់និយមន័យនៃការបំពានកិច្ចសន្យាដែរ។

មាត្រា ៤០៨ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា៖

*"១. ការបំពានកិច្ចសន្យាធ្ងន់ធ្ងរ សំដៅទៅលើករណីដែលភាគីម្ខាងមិនអាចសម្រេចនូវគោលបំណងនៃកិច្ចសន្យាបាន ដោយសារការបំពានរបស់ភាគីម្ខាងទៀត។ ត្រូវចាត់ទុកថាមានការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ក្នុងករណីដូចខាងក្រោម៖*

*ក. ភាគីម្ខាងបានដាស់តឿនភាគីម្ខាងដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ដោយកំណត់រយៈពេលសមរម្យដើម្បីអោយអនុវត្តកាតព្វកិច្ចហើយ កាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុង រយៈពេល។*

*ខ. ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ក្នុងករណីដែលគោលបំណងនៃកិច្ចសន្យាមិនបានសម្រេចសោះបើភាគីមិនអនុវត្តកាតព្វកិច្ចតាមកាលកំណត់។*

*គ. ភាគីមិនអាចអនុវត្តករណីកិច្ចផ្តល់តាមការលើកឡើងរបស់ខ្លួនបានទេ។*

*ឃ. ការបំពានកិច្ចសន្យាមានភាពហួសហេតុ ដែលធ្វើអោយបាត់បង់នូវទំនុកចិត្តរវាងគូភាគី ហើយមិនអាចជឿជាក់ថា នឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន។"*

បើផ្អែកលើមាត្រា ៤០៨ ត្រង់ចំនុច១.ក និង ឃ ក៏ឆ្លើយតបទៅនឹងស្ថានភាពរបស់លោកនាពេលបច្ចុប្បន្នព្រោះថា លោកមិនបានធ្វើការបង់ប្រាក់ជូនគម្រោងភីអរសត្រីស្កាល់ ទោះបីជាគម្រោងភីអរសត្រីស្កាល់បានព្យាយាមជូនដំណឹងអោយមកធ្វើការបង់ប្រាក់ក៏ដោយ។ កត្តានេះដែលនេះធ្វើអោយគម្រោងភីអរសត្រីស្កាល់បាត់បង់ទំនុកចិត្ត ហើយមិនអាចជឿជាក់ថាលោកនឹងអនុវត្តកាតព្វកិច្ចនាអនាគតបាន។

ចំពោះនីតិវិធីនៃការរំលាយកិច្ចសន្យា ក៏បានកំណត់ផងដែរក្នុង មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី ដែលបើកសិទ្ធិអោយអ្នកមានសិទ្ធិរំលាយធ្វើការរំលាយដោយមិនចាំបាច់ទៅតុលាការ។

មាត្រា ៤០៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា៖

*"១. ភាគីម្ខាងដែលមានសិទ្ធិរំលាយ អាចរំលាយកិច្ចសន្យា ដោយបង្ហាញឆន្ទៈរំលាយចំពោះភាគីម្ខាងទៀតបាន។ ការបង្ហាញឆន្ទៈរំលាយនេះអាចធ្វើឡើងក្រៅតុលាការបាន"*

## គ. <u>សន្និដ្ឋាន</u>

ផ្អែកតាមការរៀបរាប់ខាងលើ គម្រោងភីរេសត្រីស្តាល់ មានសិទ្ធិគ្រប់គ្រាន់ក្នុងការរំលាយកិច្ចព្រមព្រៀងទិញលក់ខុនដូ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ គិតចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ហើយគម្រោងភីរេសត្រីស្តាល់ សម្រេចធ្វើការរឹបអូសយកប្រាក់ដែលលោកបានបង់រួចចំនួន ២០,៤៦២ ដុល្លារអាមេរិក (ម្ភៃពាន់ បួនរយ ហុកសិបពីរ ដុល្លារអាមេរិក) ស្របតាមប្រការ ១២.២ និងសម្រេចធ្វើការដាក់លក់ចំណែកឯកជនលេខ ៦០១ ជូនអ្នកដទៃ។

ខ្ញុំបាទសង្ឃឹមយ៉ាងមុតមាំថា លោក នឹងយល់អំពីហេតុផលខាងលើ ហើយសូមលោកយោគយល់ថា នេះគឺជាជម្រើសតែមួយគត់សម្រាប់ស្ថានភាពបច្ចុប្បន្នដែលគម្រោងភីរេសត្រីស្តាល់ ត្រូវធ្វើ។

ក្នុងករណីដែល លោក មានចម្ងល់ពាក់ព័ន្ធ នឹងលិខិត ជូនដំណឹងនេះ សូមលោក ធ្វើការទាក់ទងមកខ្ញុំបាទតាមរយៈទូរស័ព្ទលេខ ០៧៧ ៣៥ ៦៥ ៨៨, ០៩៦ ៥៥ ៥៥ ០៦៧។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨

មេធាវីតំណាងដោយអាណត្តិ

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

[redacted]



Activate Wir
Go to PC setting